អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-May-2013, 12:00
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅជំណាក់កាលដំបូង**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៤នាទី**

**សវនាការលើកទី១៨១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូ មណី

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

កញ្ញា មីរីអ៊ាម ម៉ាហ្វេសាន់ទិ
*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្មី

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោក ប៉ាស្កាល់ អូប៊ីង
*(Mr. Pascal AUBOIN)*

លោកស្រី បេនី យេ *(Ms. Ms. Beini YE)*

លោកស្រី អេលីន័រ ហ្វេណាន់ដេស
*(Ms. Elenor FERNANDEZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ល សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ច័ន្ទ តារាស្មី | ខ្មែរ |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ឡោ ជុនធី | ខ្មែរ |
| លោកស្រី បេនី យេ | អង់គ្លេស |
| លោក ព្រុំ ស្ទិ៍ (TCW-548) | ខ្មែរ |
| លោក ហ្វីលីព ហ្ស៊ែល្សាន-ហ្គោហ្វ៊ែស (TCW-277) | បារាំង |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ព្រំ ស៊ុំ** (TCW-548)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ២
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្ដើមពី ....................ទំព័រ ៦
សួរដោយលោក ខេល លីសាក់ ផ្ដើមពី ....................ទំព័រ ១៨
សួរដោយលោក ពេជ អង្គ ផ្ដើមពី ....................ទំព័រ ៣៧
សួរដោយលោកស្រី បេនី យេ ផ្ដើមពី ....................ទំព័រ ៤០


**ការសួរសំណួរទៅសាក្សី៖ លោក ហ៊ីលីព ហ្ស៊ីលហ្វាន-ហ្គោហ្វែស** (TCW-277)


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ៤៣
សួរដោយលោក អាកទួរ វែកគែន ផ្ដើមពី ....................ទំព័រ ៤៦
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ....................ទំព័រ ៥៩
សួរដោយលោក លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ....................ទំព័រ ៧០
សួរដោយលោក ច័ន្ទ តាារស្មី ផ្ដើមពី ....................ទំព័រ ៨១
សួរដោយលោក ឡោ ជុនធី ផ្ដើមពី....................ទំព័រ ៨៨
សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្ដើមពី ....................ទំព័រ ៩១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៣០]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅព្រឹកនេះ ដូចអង្គជំនុំជម្រះបាន ជម្រាបជូនភាគីនិងសាធារណជនរួចហើយកាលពីម្សិលមិញថា អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់ សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-548។ ហើយនៅថ្ងៃនេះគឺនៅរសៀលយើងនឹងធ្វើសវនាការ ស្ដាប់សក្ខីកម្មសាក្សីតាមប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង។ អ៊ីចឹងសាក្សីរូបនេះ យើងគ្រោងធ្វើ១ថ្ងៃ ប៉ុន្តែដោយសារនៅរសៀល យើងធ្វើសក្ខីកម្ម -- ស្ដាប់សក្ខីកម្មសាក្សីតាមប្រព័ន្ធសោតទស្សន៍។ ដូច្នេះ សាក្សីរូបនេះយើងនឹងរយៈពេលពីរព្រឹក គឺព្រឹកថ្ងៃនេះ ហើយនិងព្រឹកថ្ងៃស្អែក។

ក្រឡាបញ្ជីសវនាការ លោក ដាវ អានសាន ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការព្រឹកនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន នៅក្នុងសវនាការនាពេលព្រឹកនេះ គ្រប់ភាគីទាំងអស់នៃរឿងក្ដីមាន វត្តមាន លើកលែងលោក សុន អរុណ គាត់អវត្តមានដោយសារមានមូលហេតុសុខភាព។ ហើយដោយ ឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការតាមសេចក្ដីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

សម្រាប់សវនាការនាព្រឹកនេះ ដូចតាមការគ្រោងទុកនិងការជូនដំណឹងរបស់លោកប្រធាន សាក្សី ដែលមានរហស្សនាម TCW-548 បានត្រៀមខ្លួនរួចជាស្រេចនៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពី អង្គជំនុំជម្រះ។ សាក្សីរូបនេះបានធ្វើសម្បថរួចហើយកាលពីថ្ងៃម្សិលមិញ ថ្ងៃទី២០ ឧសភា នៅចំពោះ មុខលោកតាដំបងដែក នៃ អ.វ.ត.ក យើងនេះ។

[០៩:០៦:៥១]

សាក្សីរូបនេះបានបញ្ជាក់ផងដែរថា គាត់តាមសមត្ថភាពដែលគាត់បានដឹង គាត់អាចដឹង គាត់មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីរ ឬភាគីដើមបណ្ដឹងណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿងនេះទេ។ ហើយសាក្សីរូបនេះក៏មិនមានមេធាវីប្រឹក្សាផងទេ ហើយសម្រាប់សវនាការនៅព្រឹកនេះ យើងមិនមានសាក្សីបម្រុងទេ។

សម្រាប់សវនាការនារសៀលនេះវិញគឺ ការស្ដាប់សក្ខីកម្មសាក្សី TCW-277 ពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍។ សាក្សីនេះក៏បានបញ្ជាក់ផងដែរថា តាមសមត្ថភាពដែលគាត់អាចដឹង គាត់មិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីរ ក៏ដូចជាដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នោះទេ។ ដោយឡែកគាត់នឹងធ្វើសម្បថនៅមុនពេលធ្វើសក្ខីកម្ម។

អ្នកបច្ចេកទេសខាងសោតទស្សន៍ក៏បានបញ្ជាក់ផងដែរ បានរៀបចំផ្នែកបច្ចេកទេសសម្រាប់ការផ្ដល់សក្ខីកម្មពីចម្ងាយរួចរាល់ហើយផងដែរ។ សូមចប់សេចក្ដីរាយការណ៍លោកប្រធាន សូមអរគុណ។

[០៩:០៨:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ដាវ អានសាន។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 548 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:១៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្ដីលោកសាក្សី! តើលោកឈ្មោះអី?

**លោក ព្រំ ស៊ូ៖**

**ឆ៖** ខ្ញុំសូមគោរពលោកប្រធាន។ ខ្ញុំបាទឈ្មោះ ព្រំ ស៊ូ។

**ស៖** អរគុណ។ លោក ព្រំ ស៊ូ ហើយក្រៅពីឈ្មោះ ព្រំ ស៊ូ តើលោកមានឈ្មោះហៅក្រៅផ្សេងទៀតដែរឬទេ?

**ឆ៖** ឈ្មោះកាលនៅរៀនឈ្មោះ ស៊ុន លឿន។

**ស៖** អរគុណលោក ព្រំ ស៊ូ។ តើលោកកើតនៅថ្ងៃ ខែ ឆ្នាំណា?

**ធ៖** ខ្ញុំកើតនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ១៩៥០។

**ស៖** បាទ អរគុណ។ ហើយសព្វថ្ងៃនេះលោកមានទីលំនៅ នៅទីកន្លែងណា?

**ធ៖** ខ្ញុំមានទីលំនៅ នៅសៀមរាប ភូមិ--

**ស៖** បាទ អរគុណលោក ព្រំ ស៊ូ។ ហើយតើប្រកបមុខរបរ រកស៊ីធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ធ៖** សព្វមិនមានមុខរបរអីទេ ខ្លួនជាពិការកូនចិញ្ចឹម ហើយនិងមានប្រាក់សោធននិវត្តន៍ខ្លះ។

**ស៖** លោកជាមន្ត្រីចូលនិវត្តន៍ហើយ អ៊ីចឹងមែនទេ?

[០៩:១០:៥៦]

**ធ៖** បាទ ខ្ញុំមន្ត្រីចូលនិវត្តន៍។

**ស៖** បាទ អរគុណ។ ហើយលោក ព្រំ ស៊ូ តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណាដែរ?

**ធ៖** ខ្ញុំបាទកើតនៅភូមិរលួស ឃុំស្វាយចេក ស្រុកថ្មពួក ខេត្តបាត់ដំបង។

**ស៖** អរគុណ។ តើលោកអាចប្រាប់ដល់អង្គសវនាការបានដែរទេថាឪពុករបស់លោកឈ្មោះអី? ម្តាយរបស់លោកឈ្មោះអី? ប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ធ៖** ឪពុករបស់ខ្ញុំឈ្មោះ ឆុង ឈុន, ម្តាយឈ្មោះ ហួត មន, ប្រពន្ធឈ្មោះ រឹម សំអាង, មានកូនបួននាក់។

**ស៖** បាទ អរគុណ។ ហើយលោក ព្រំ ស៊ូ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ ហើយក៏មិនជាប់ញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបដែរ គឺលោក នួន ជា និងលោក ខៀវ សំផន។ តើជាការពិតមែនដែរឬទេ?

**ធ៖** បាទ ហ្នឹងគឺជាការពិត។

**ស៖** បាទ អរគុណ។ ហើយក្រឡាបញ្ជី -- របាយការណ៍របស់ក្រឡាបញ្ជីសវនាការដដែលក៏បានរាយការណ៍ថា លោកបានធ្វើសម្បថរួចហើយមុននឹងចូលមកកាន់បន្ទប់សវនាការនាពេលនេះ។ តើលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែកនៅក្បែរសាលសវនាការនេះរួចហើយឬនៅ?

[០៩:១៣:០០]

**ធ៖** បាទ ក្រឡាបញ្ជីបាននាំទៅធ្វើសម្បថនៅតាដំបងដែករួចហើយ។

**សៈ** បាទ អរគុណ។ ហើយលោក ព្រំ ស៊ូ ក្នុងនាមលោកជាសាក្សីដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលនេះ អង្គជំនុំជម្រះសូមជម្រាបលោកអំពីសិទ្ធិនិងករណីយកិច្ចរបស់លោកដូចខាងក្រោម៖

អំពីសិទ្ធិ, លោក ព្រំ ស៊ូ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះលោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរណាមួយ ឬការធ្វើអំណះអំណាងណាមួយឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

[០៩:១៣:៥១]

អំពីករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែក្នុងករណីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង លោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ នេះគឺជាសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកជាសាក្សី។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចនេះដែរឬទេ?

**ឆៈ** បាទ ខ្ញុំស្ដាប់បាន ហើយនិងយល់។

**សៈ** បាទ អរគុណ។ ហើយលោក ព្រំ ស៊ូ តើលោកដែលធ្លាប់ផ្ដល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ? ហើយប្រសិនដែលបានធ្វើ តើប្រព្រឹត្តនៅប៉ុន្មានលើក? ហើយធ្វើនៅទីកន្លែងណា? នៅពេលណា?

[០៩:១៥:០៣]

**ឆៈ** ខ្ញុំបាទធ្វើសម្ភាសជាមួយបុគ្គលិកស៊ើបអង្កេតនៅខេត្តសៀមរាប នៅឆ្នាំ២០០៩ ហើយមានឯកសារនៅនឹងមុខនេះស្រាប់។

**សៈ** ធ្វើប៉ុន្មានលើកដែរ? តែមួយលើក ឬក៏ពីរលើក?

**ឆៈ** ធ្វើតែមួយលើកទេ ព្រឹកល្ងាច។

**សៈ** បាទអរគុណ។ ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះតើលោកបានពិនិត្យមើល

ឬបានអាននូវកំណត់ហេតុស្តាប់សក្ខីកម្មរបស់លោកដែលបានធ្វើជាមួយអ្នកស៊ើបអង្កេតកន្លងមកដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានមើល បានអានត្រឹមត្រូវហើយនិងច្បាស់លាស់។

[០៩:១៦:១៧]

**ស៖** បើតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំថាលោកអាចបញ្ជាក់បានដែរទេថាកំណត់ហេតុស្តាប់សក្ខីកម្មរបស់លោកដែលលោកបានអាន បានមើលដើម្បីរំឭកការចងចាំនោះពិតជាត្រឹមត្រូវ និងស៊ីសង្វាក់គ្នាស្របគ្នានឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតកាលពីឆ្នាំមួយពាន់ -- ២០០៩នោះដែរឬទេ?

**ឆ៖** បាទជាការត្រឹមត្រូវ បើបានខ្ញុំចុះហត្ថលេខាលើកំណត់ហេតុនេះហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយអង្គជំនុំជម្រះសូមរំឭកបញ្ជាក់លោក ព្រំ ស៊ូ បន្ថែមបន្តិចថាក្នុងការឆ្លើយតបហ្នឹង សូមលោកបង្អង់បន្តិចដើម្បីឱ្យរងចាំរហូតដល់ក្បាលមេក្រូហ្វូនប្រព្រឹត្តិការណ៍ ដោយឱ្យភ្លើងសញ្ញាក្រហមនៅក្បាលមេក្រូហ្វូន ឬក៏នៅខាងក្រោមនេះជាសញ្ញាថាក្បាលមេក្រូហ្វូនប្រតិបត្តិការហើយ។ ដូច្នេះលោកអាចចាប់ផ្តើមនិយាយ ហើយឆ្លើយតបទៅនឹងសំណួរផ្សេងៗដើម្បីឱ្យប្រព័ន្ធសំឡេងរបស់លោកចូលក្នុងប្រព័ន្ធផ្សព្វផ្សាយសំឡេងចែកចាយជូនដល់ភាគីពាក់ព័ន្ធក៏ដូចជាសាធារណជន។ ជាពិសេសចំពោះអង្គភាពបកប្រែភាសា ដើម្បីឱ្យគាត់បានបកប្រែភាសាផ្សេងៗទៀត។ ហើយអ្នកបច្ចេកទេសនឹងបញ្ជានូវក្បាលមេក្រូហ្វូននេះដោយសម្រួលឱ្យការឆ្លើយរបស់លោកហ្នឹងបានពេញលេញ ហើយសំណួរក៏បានពេញលេញដោយសារមានការបកប្រែ។ អ៊ីចឹងមានការដកឃ្លាបន្តិច។

[០៩:១៧:៤៨]

បាទ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដែលត្រូវសួរដេញដោលដល់សាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយអង្គជំនុំជម្រះសូមជម្រាបថាក្នុងការសួរដេញដោលសាក្សីរូបនេះគឺភាគីម្ខាងៗមានរយៈពេលកន្លះថ្ងៃ គឺសហព្រះរាជអាជ្ញារួមនឹងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយព្រឹកនេះ ហើយនិងមួយព្រឹកស្អែកហ្នឹងគឺខាងភាគីការពារក្តី។

បាទ សូមអញ្ជើញ!

**កញ្ញា សុង ឆវ័ន្ត៖**

ចាសសូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមសូមគោរពផងដែរដល់អង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ព្រំ ស៊ូ។ នាងខ្ញុំឈ្មោះ សុង ឆវ័ន្ត ជាតំណាងសហព្រះរាជអាជ្ញាជាតិ ហើយអ្នកដែលអង្គុយនៅក្បែរខ្ញុំនេះ គឺលោក ឌេល លីសាក់ គាត់ជាតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ នាងខ្ញុំទាំងពីរនាក់ថ្ងៃនេះមានសំណួរមួយចំនួនដើម្បីសាកសួរលោកពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងការបទពិសោធន៍របស់លោកដែលបានចូលរួមនៅក្នុងរបបនោះ។ អ៊ីចឹងខ្ញុំចាប់ផ្តើមជាបឋមចង់សួរប្រវត្តិរបស់លោកបន្តិចមុនឆ្នាំ១៩៧៥។ ហើយមុននេះលោកប្រធានក៏បានសួរបញ្ជាក់លោកផងដែរថា លោកបានអាននូវកំណត់ហេតុដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតរួចហើយ។ ប៉ុន្តែខ្ញុំចង់សួរបញ្ជាក់លោកថា តើលោកមានកំណត់ហេតុនេះនៅក្នុងដៃដែរឬទេ ឬក៏លោកត្រូវការកំណត់ហេតុនេះមួយទៀត? តើលោកមានឯកសារហ្នឹងនៅក្នុងដៃទេពេលនេះ?

[០៩:១៩:៣២]

**លោក ព្រំ ស៊ូ៖**

**ឆ៖** ខ្ញុំមានឯកសារនេះនៅក្នុងដៃហើយបាទ។

**ស៖** អ៊ីចឹងខ្ញុំនឹងចាប់ផ្តើមសួរទៅលោក ដោយពេលខ្លះខ្ញុំនឹងយោងទៅលើឯកសារដែលលោកធ្លាប់បានឆ្លើយពីមុនមក។ ហើយសំណួរទី១របស់ខ្ញុំ គឺថានៅក្នុងបទសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីថ្ងៃ២៩ ខែវិច្ឆិកា ឆ្នាំ២០០៩ លោកបានឆ្លើយថា “ប្រហែលជាចុងឆ្នាំ១៩៧១ អង្គការបានចាត់តាំងឲ្យខ្ញុំធ្វើជាអ្នកឃោសនា” គឺនៅត្រង់សំណួរចម្លើយលេខ១។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើគេចាត់តាំងឲ្យលោកធ្វើការអ្វីខ្លះក្នុងឋានៈជាអ្នកឃោសនានៅពេលនោះ?

**ឆ៖** នៅពេលនោះគឺខ្ញុំរស់នៅក្នុងស្រុករវៀង ភូមិស្វាយដំណាក់ ហើយអង្គការត្រូវបានចាត់តាំងក្រុមឃោសនាអប់រំនៅក្នុងមូលដ្ឋាន គឺនៅក្នុងស្រុករវៀង។ ជាពិសេសគឺនៅក្នុងឃុំល្វាក្រសាំង ភូមិតាសែន ដែលជាឃុំនៅដាច់ស្រយាលជាប់នឹងខេត្តកំពង់ធំ ឃុំដាច់ស្រយាលហ្នឹងគឺឃុំដែលចុងគេ ឃុំ

ដែលចុងគេគឺទៅអប់រំប្រជាជនដើម្បីឲ្យមានលំនឹងខាងនយោបាយ កុំឲ្យមានការគេចវេស ឬរត់លួនទៅណាទៅណី។

[០៩:២១:៣៣]

**ស៖** ចាសសូមអរគុណ។ នៅក្នុងចម្លើយនោះលោកបានរំឭកដល់ពាក្យ“អង្គការ” តើ “អង្គការ” ហ្នឹងលោកចង់សំដៅទៅរកអ្នកណាដែរ?

**ឆ៖** អង្គការហ្នឹងគឺសំដៅទៅលើក្រុមដឹកនាំដែលនៅពីលើខ្ញុំដូចជា ក្របខ័ណ្ឌអង្គការតំបន់១០៣។

**ស៖** តើអង្គការមានតែត្រឹមថ្នាក់តំបន់ ឬក៏លោកដឹងថាមានថ្នាក់លើតំបន់ ឬក៏ថ្នាក់ណាផ្សេងទៀតដែរ?

**ឆ៖** តាមខ្ញុំដឹង គឺអង្គការហ្នឹងគឺរចនាសម្ព័ន្ធពីថ្នាក់លើរហូតមកដល់ថ្នាក់មូលដ្ឋាន ហ្នឹងគឺនៅថ្នាក់លើមានអង្គការមជ្ឈិម ហើយនៅតទៅទៀតនោះមានអង្គការភូមិភាគ ហើយនិងអង្គការតំបន់។ នេះតាមដែលខ្ញុំយល់។

**ស៖** ចាសសូមអរគុណ។ ហើយនៅពេលដែលលោកបម្រើការងារជាអ្នកឃោសនានោះលោកធ្លាប់បានឮគេហៅថាមានសហករណ៍ដែរឬទេពេលនោះ?

**ឆ៖** ពេលនោះនៅក្នុងតំបន់១០៣ ខេត្តព្រះវិហារ គឺគេមិនហៅសហករណ៍ទេ គេហៅសហគមន៍។ នៅសហគមន៍ គឺប្រជាជនរួបរួមគ្នាទៅ ធ្វើការជាមួយគ្នា ធ្វើស្រែ ធ្វើចម្ការជាមួយគ្នាទៅ ដាំបាយហូបរៀងៗខ្លួន ក៏ប៉ុន្តែធ្វើស្រែនៅជាមួយគ្នា។ នេះហៅថាសហគមន៍។ បន្តក្រោយមកទៀតអាហ្នឹងមានការប្រែប្រួលពីសហគមន៍មកសហករណ៍។ ដល់សហករណ៍នោះហូបបាយរួមហើយ។ នេះខ្ញុំយល់ប៉ុណ្ណឹង។

[០៩:២៣:៤៥]

**ស៖** ចុះលោកដឹងទេថាតើគេបង្កើតសហករណ៍ឡើងក្នុងឆ្នាំណាដែរ?

**ឆ៖** សហករណ៍តាមដែលខ្ញុំចាំប្រហែលជាឆ្នាំ១៩៧៣។ ឯសហគមន៍នោះគឺពីឆ្នាំ១៩៧១, ៧២។

**ស៖** ហើយលោកដឹងទេថា អ្នកណាជាអ្នកបញ្ជាឲ្យបង្កើតសហករណ៍នៅក្នុងកន្លែងដែលលោកធ្វើការពេលនោះ?

**ឆ៖** អ្នកបញ្ជាគឺមានតែគណៈតំបន់ ហើយនិងគណៈស្រុក ដែលគេបញ្ជារៀបចំ។

**ស៖** ចាសសូមអរគុណ។ នៅក្នុងបទសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតដដែល ហើយនៅត្រង់ចម្លើយដដែល លោកបានលើកឡើងថា “នៅក្នុងឆ្នាំ១៩៧២ លោកត្រូវបានអង្គការបញ្ចូលជាជនបង្គោល ហើយនៅឆ្នាំ១៩៧៣ លោកបានចូលជាបក្ខជននៅមន្ទីរអន្លង់ស្វាយ ក្រោមអធិបតីភាពឈ្មោះ ហង្ស ដែល ជាអនុប្រធានតំបន់ ១០៣។ ខ្ញុំចង់សួរលោកបញ្ជាក់ថាតើលោកស្គាល់ឈ្មោះ ហង្ស ហ្នឹងនៅពេលណា? ហើយហេតុអ្វីបានជាស្គាល់ ឈ្មោះហង្ស?

**ឆ៖** ឈ្មោះ ហង្ស នេះគឺជាកម្មាភិបាលដែលទៅដល់ស្រុករវៀងនេះមុនគេ។ ហើយក៏គាត់នៅដឹកនាំនៅកន្លែងនោះទៅដែលជាអនុប្រធានតំបន់ ១០៣ ព្រះវិហារនោះ។

**ស៖** លោកមានចាំទេ ថាលោកស្គាល់គាត់នៅក្នុងឆ្នាំណាដែរពេលនោះ?

**ឆ៖** ខ្ញុំស្គាល់គាត់ប្រហែលជាឆ្នាំ១៩៧១ ពេលដែលលោក ហ៊ូ យន់ ទៅធ្វើមីទ្ទិងនៅក្នុងវត្តរវៀង។

**ស៖** ហើយពេលហ្នឹងមានអ្នកណាណែនាំឲ្យលោកស្គាល់ឈ្មោះ ហង្ស ហ្នឹង ឬក៏ហេតុអ្វីបានជាលោកស្គាល់ឈ្មោះ ហង្ស នៅពេលនោះ នៅឆ្នាំ៧១នោះ?

**ឆ៖** ស្គាល់ឈ្មោះ ហង្ស ហ្នឹងគឺដាក់ទៅគឺនៅក្នុងគណៈតំបន់នោះមានប្រជាជនស្គាល់ ហើយក៏គាត់ហៅទៅរៀនសូត្រអីតាមការចាត់តាំងជាអង្គការដឹកនាំនៅក្នុងមូលដ្ឋានហ្នឹង។

**ស៖** ចាស សូមអរគុណ។ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់បំភ្លឺបន្តិចទាក់ទងទៅនឹងតំបន់១០៣។ តើតំបន់ ១០៣ គ្របដណ្តប់កន្លែងណាខ្លះនៅពេលនោះ?

[០៩:២៧:១៧]

**ឆ៖** តំបន់១០៣ គឺគ្របដណ្តប់ទៅលើភូមិសាស្ត្រខេត្តព្រះវិហារទាំងមូល ហើយនិងខេត្តស្ទឹងត្រែងខាងលិចទន្លេមេគង្គ មានស្រុកថាឡាបរិវ៉ាត់ ស្រុកសៀមបូក ស្រុកព្រះនង្គ័ល។

**ស៖** លោកនៅចាំទេថាទាំងអស់សរុបទៅមានស្រុកប៉ុន្មាននៅក្នុងតំបន់ ១០៣ហ្នឹង?

**ឆ៖** នៅក្នុងតំបន់១០៣ មានស្រុក១៣ ពីមុនវាមិនមានដល់ប៉ុណ្ណឹងទេ ដល់ក្រោយ៧០មករៀបចំមានស្រុក១៣។

**ស៖** ចុះតំបន់១០៣ហ្នឹងស្ថិតនៅក្រោមភូមិភាគណាដែរ ឬក៏តំបន់ហ្នឹងជាតំបន់ស្វយ័ត?

**ឆ៖** តំបន់ ១០៣ជាតំបន់ ស្វយ័ត ឡើងទៅមជ្ឈិមផ្ទាល់តែម្តង។ មិនទាន់មានភូមិភាគទេទាល់ក្រោយមកបានមានភូមិភាគ។

 

[០៩:២៨:៣៤]

**ស៖** ចាស សូមអរគុណ។ នៅត្រង់សំណួរចម្លើយទី១ នៃបទសម្ភាសន៍របស់លោកដដែល លោកបានលើកឡើងថា លោកត្រូវបានអង្គការចាត់តាំងឲ្យមកធ្វើការនៅមន្ទីរពាណិជ្ជកម្មតំបន់១០៣ នៅចុងឆ្នាំ១៩៧៤។ ខ្ញុំចង់សួរលោកថា នៅមុខខែមេសា ឆ្នាំ១៩៧៥ តើមន្ទីរពាណិជ្ជកម្មរបស់តំបន់ ១០៣មានតួនាទីអ្វីខ្លះពេលនោះ?

**ឆ៖** នៅមុនថ្ងៃ១៧ មេសា ១៩៧៥ តួនាទីរបស់មន្ទីរពាណិជ្ជកម្ម១០៣ គឺមានភារកិច្ចទទួលខុសត្រូវដោះស្រាយជីវភាពប្រជាជននៅក្នុងតំបន់នោះទាំងមូល។ បញ្ហាទី១ សំខាន់បំផុតគឺបញ្ហាអំបិល។ បញ្ហាទី២ គឺបញ្ហាថ្នាំពេទ្យ។ បញ្ហាទី៣ គឺបញ្ហាសម្លៀកបំពាក់។

**ស៖** ចាស សូមអរគុណ។ មុននឹងចូលដល់ប្រធានថ្មី ចង់សួរបញ្ជាក់លោកថា នៅក្នុងអំឡុងចាប់ពីឆ្នាំ៧១ ដល់ឆ្នាំ១៩៧៥ តើលោកមានធ្លាប់បានជួបថ្នាក់ដឹកនាំ ឬក៏មេដឹកនាំរបបខ្មែរក្រហមណាខ្លះដែរឬទេ តាមរយៈទស្សនកិច្ច ឬក៏បទសុន្ទរកថាជាដើមរបស់គាត់នៅក្នុងតំបន់របស់លោកពេលនោះ?

**ឆ៖** គឺពីឆ្នាំ១៩៧០ ដល់ ៧៥ គឺខ្ញុំមិនដែលបានជួបអង្គការថ្នាក់ដឹកនាំផ្ទាល់ទេ ក៏ប៉ុន្តែធ្លាប់ដឹងដំណឹង គឺមានការធ្វើដំណើរឆ្លងកាត់អីខ្លះ ព្រោះថ្នាក់ដឹកនាំគឺមានដូចជាលោក ខៀវ សំផន គាត់ទៅបានប្រពន្ធនៅស្រុករវៀង ឃុំស្រែធំ។ ហើយឆ្នាំ១៩៧៣ហ្នឹង គឺសម្តេចព្រះ សីហនុ ហើយនិងគណៈប្រតិភូមួយចំនួនហ្នឹងបានធ្វើដំណើរពីស្ទឹងត្រែងមកឆ្លងកាត់ព្រះវិហារមកដល់សៀមរាប ដោយអមដំណើរដោយលោក ខៀវ សំផន ហើយនិងភរិយា។ អាហ្នឹងខ្ញុំដឹងតែប៉ុណ្ណឹង។ អត់បានជួបទេ គ្រាន់តែដឹង។

[០៩:៣១:៤៥]

**ស៖** លោកអាចបញ្ជាក់បានទេថា លោកដឹងដោយរបៀបណា? តើអ្នកណាជាអ្នកប្រាប់លោក ឬក៏មានព័ត៌មានហ្នឹងបានមកពីណាដែរ?

**ឆ៖** ព័ត៌មាននេះគឺដឹងពីមូលដ្ឋានដែលនៅជិតៗហ្នឹង ដូចជានៅស្រុករវៀង នៅស្រុកសង្គមថ្មី នៅស្រុកគូលែន ដែលឆ្លងកាត់មកនោះ។

**ស៖** ចាស អរគុណ។ សំណួរចុងក្រោយមុននឹងចូលដល់ប្រធានបទថ្មី។ តើលោកធ្លាប់បានឃើញលោក ខៀវ សំផន មុនខែមេសា ឆ្នាំ១៩៧៥ ឬក៏នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលហ្នឹង គឺចាប់ពី៧៥ ដល់ ៧៩ ដែរឬទេ? ធ្លាប់បានឃើញផ្ទាល់ទេ?

**ឆ៖** ខ្ញុំមិនដែលបានជួបលោក ខៀវ សំផន ផ្ទាល់ទេ សូម្បីតែគាត់មានគ្រួសារនៅស្រុករវៀង

ហ្នឹង ក៏មិនដែលជួបផ្ទាល់ដែរ។ ក៏ប៉ុន្តែជាព័ត៌មានដឹងតាំងពីខ្ញុំនៅរៀន ស្គាល់តាំងពីខ្ញុំនៅរៀនណោះ។ គាត់ជាបញ្ញាជនស្រុកខ្មែរមួយរូបដែលមានសញ្ញាប័ត្រ បណ្ឌិតច្បាប់នៅស្រុកបារាំង។

[០៩:៣៣:១៧]

**ស៖** ចាសអរគុណ។ ខ្ញុំនឹងចូលដល់ប្រធានបទមួយទៀតពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកនៅកន្លែងណា ពេលនោះ?

**ឆ៖** នៅថ្ងៃ១៧ មេសា ១៩៧៥ ខ្ញុំនៅមន្ទីរពាណិជ្ជកម្មតំបន់ព្រះវិហារ នៅក្នុងស្រុករវៀង។

**ស៖** ចាស សូមអរគុណ។ នៅត្រង់សំណួរចម្លើយទី១៧ នៃបទសម្ភាសន៍ដដែល លោកបាន -- គេបានសួរលោកថា "តើប្រជាជនដែលចូលមករស់នៅថ្មីក្នុងតំបន់១០៣ ភាគច្រើនជាប្រជាជនជម្លៀសមកពីទីណាខ្លះ?" ហើយលោកបានឆ្លើយថា ដកស្រង់ "មានប្រជាជនមកពីភ្នំពេញ និងនិស្សិតខ្មែរដែលត្រឡប់មកពីប្រទេសបារាំង អាល្លឺម៉ង់ ជាដើម"។ បញ្ចប់ការដកស្រង់។ ចង់សួរលោកថា តើលោកបានឃើញប្រជាជនថ្មី ទៅដល់តំបន់១០៣នៅពេលណាដែរ?

**ឆ៖** ខ្ញុំបានឃើញការជម្លៀសប្រជាជនពីភ្នំពេញ គឺនៅខេត្តកំពង់ធំ ដែលកាលនោះខ្ញុំមានភារកិច្ចដឹកជញ្ជូនស្បៀងពីខេត្តព្រះវិហារមកចាំទទួលអ្នកដែលជម្លៀសហ្នឹងនៅកំពង់ធំ។ បើកអង្ករបើកអីរួចបានយកត្រាក់ទ័រ យកឡានអីមកដឹកទៅចែកជូនតាមសហករណ៍នៅក្នុងតំបន់១០៣ហ្នឹង។

**ស៖** ចង់សួរលោកបញ្ជាក់រឿងពេលវេលា ថាតើលោកបានឃើញប្រជាជនថ្មី ដែលថាជម្លៀសមកដល់តំបន់១០៣ នៅពេលណា? លោកចាំពេលវេលាទេ?

[០៩:៣៥:៥០]

**ឆ៖** ខ្ញុំមិនបានចាំខែថ្ងៃទេ ក៏ប៉ុន្តែគឺប្រជាជនដែលជម្លៀសមកដល់កំពង់ធំដឹកតាមកប៉ាល់ ដឹកតាមអីមកគឺខ្ញុំមកទទួលនៅកន្លែងកំពង់ធំនោះគឺដូចនៅអូរតែលស្ទឹងសែនសព្វថ្ងៃ។

**ស៖** តើលោកបានដឹងជាមុនទេថា ប្រជាជនថ្មីទាំងនោះត្រូវគេបញ្ជូនមកតំបន់១០៣?

**ឆ៖** ខ្ញុំអត់បានដឹងជាមុនទេ ក៏ប៉ុន្តែនេះគឺដល់ហៅថាមានផែនការអង្គការតំបន់នេះ គឺប្រគល់ឲ្យភារកិច្ច និងឲ្យពាណិជ្ជកម្មហ្នឹងមកដោះស្រាយស្បៀង ហើយនិងដោះស្រាយដឹក មធ្យោបាយដឹកជញ្ជូនហ្នឹងដឹកទៅតំបន់១០៣នោះ។

**ស៖** សំណួរដែលហ្នឹង អ្នកស៊ើបអង្កេតសួរលោកថា "ភាគច្រើនប្រជាជនគេជម្លៀសមកពីទីណា?" ហើយលោកឆ្លើយថា "មកពីភ្នំពេញ"។ អីចឹងសំណួរខ្ញុំចង់ដឹងថា តើមូលហេតុអ្វីបានជាលោក

ដឹងថាភាគច្រើននៃអ្នកជម្លៀសទាំងនោះមកពីទីក្រុងភ្នំពេញ?

**ឆ៖** ខ្ញុំដឹងមកពីទីក្រុងភ្នំពេញដោយសារខ្ញុំមកទទួលៗនៅភ្នំពេញ សុទ្ធតែអ្នកទៅពីភ្នំពេញហ្នឹង។

**ស៖** តើមានប្រជាជនដែលជម្លៀសមកពីទីក្រុងភ្នំពេញហ្នឹងច្រើននាក់ទេ? ប្រហែលប៉ុន្មាននាក់? ប៉ុន្មានគ្រួសារដែរពេលនោះ?

**ឆ៖** តាមដែលខ្ញុំស្មានមិនដឹងតួលេខច្បាស់លាស់ទេ ក៏ប៉ុន្តែអាចច្រើន។ ប្រហែលជា៣.០០០ គ្រួសារ -- ប្រហែល ៣.០០០នាក់ទេ។

[០៩:៣៨:០៩]

**ស៖** ចំនួនប្រហែល ៣.០០០នាក់ហ្នឹង តែប្រជាជនដែលគេជម្លៀសមកពីទីក្រុងភ្នំពេញទេ ឬក៏ប្រជាជនមកពីកន្លែងផ្សេងដែរ?

**ឆ៖** អត់មានប្រជាជនមកពីកន្លែងផ្សេងទេ គឺមកពីភ្នំពេញដែលមានហេតុការណ៍ដឹកជញ្ជូនតាមកប៉ាល់ទឹកមកដាក់នៅផែកំពង់ធំ ហើយទទួលមកពីណោះដឹកមកព្រះវិហារតែម្តង អត់មានកន្លែងណាចូលទៅ។ ដូចកំពង់ធំជម្លៀសពីទីក្រុងកំពង់ធំ ខេត្តកំពង់ធំ ឲ្យទៅតាមស្រុក តាមមូលដ្ឋានរបស់គេតាមស្រុកកំពង់ធំ។

**ស៖** ចាស សូមអរគុណ។ ចុះនៅក្នុងអំឡុងពេលដែលមានការជម្លៀសប្រជាជននោះ តើលោកដឹងទេថា កម្មាភិបាលនៅតំបន់១០៣ ត្រូវបានគេណែនាំឲ្យធ្វើយ៉ាងម៉េចដែរចំពោះប្រជាជនដែលត្រូវបានគេជម្លៀសមកនោះ?

**ឆ៖** ចំពោះការដែលទទួលប្រជាជនដែលជម្លៀសមកគឺខាងអង្គការ១០៣ គឺបានណែនាំថាឲ្យទៅទទួល ហើយចែកស្បៀង ដោះស្រាយស្បៀងៗ ម្ហូបអីមិនមានទេ មានតែអង្ករ និងអំបិលហ្នឹង ហើយនិងដឹកជញ្ជូនមកឲ្យបានស្រួលបួលដល់១០៣ហ្នឹង ដល់ព្រះវិហារនេះ ឲ្យបានស្រួលបួល ទទួលខុសត្រូវខ្ពស់ក្នុងការដឹកជញ្ជូននេះ។ ហើយទៅដល់ណោះហើយគឺប្រគល់ឲ្យស្រុកគេ។ បញ្ចប់ភារកិច្ចរបស់ហើយអង្គភាពពាណិជ្ជកម្មហើយ។

[០៩:៤០:០៤]

**ស៖** លោកថាអង្គការ១០៣ តើមាននរណាខ្លះ ឬកមានឈ្មោះអ្វីនៅក្នុងអង្គការ១០៣ហ្នឹងដែលដាក់បញ្ជាឲ្យរៀបចំទទួលដូច្នេះ?

**ឆ៖** អង្គការ១០៣ ក្នុងគណៈតំបន់ វាមានបីបួននាក់។ តែអ្នកដែលនាំ ណែនាំហៅឲ្យទទួលជន

ដែលជម្លៀសទៅពីទីក្រុងភ្នំពេញ គឺមានឈ្មោះ ហង្ស ហ្នឹងបានណែនាំខាងពាណិជ្ជកម្មហ្នឹងគឺឲ្យមកទទួល ហើយរៀបចំដឹកជញ្ជូន។

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** សូមទោស។ សម្ភារៈ និងរបស់របរផ្គត់ផ្គង់ដែលរៀបចំសម្រាប់ទទួលប្រជាជនប្រហែល ៣.០០០នាក់ហ្នឹង តើគ្រប់គ្រាន់ទេពេលនោះ?

[០៩:៤១:១៥]

**ឆ៖** សម្ភារៈដែលមកទទួលហ្នឹងគឺជាអង្ករមានគ្រប់គ្រាន់ ហើយជាអំបិលមានគ្រប់គ្រាន់ ហើយ និងមធ្យោបាយដឹកជញ្ជូនក៏មានគ្រប់គ្រាន់ដែរ។ មានត្រាក់ទ័រ មានឡានអីៗហ្នឹង។

**ស៖** ចុះចំពោះរូបលោកផ្ទាល់ តើលោកធ្លាប់បានដឹង ឬទទួលព័ត៌មានអ្វីខ្លះទាក់ទងនឹងមូលហេតុ ហេតុអ្វីបានជាមានការបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេពេលនោះ?

**ឆ៖** តាមទស្សនៈដែលខ្ញុំដឹង តាមវិភាគនោះគឺបញ្ហាទីក្រុងភ្នំពេញហ្នឹង គឺដែលរំដោះហើយហ្នឹង គឺមួយ គិតគូរពីបញ្ហាសន្តិសុខ។ ក្រោយសង្គ្រាម យើងមើលមិនឃើញអាការដែលវាយបកមកវិញរបស់អាមេរិកទេ។ អាចថាវាមានការវាយបកដោយកប៉ាល់ហោះដោយអីហ្នឹង ម្យ៉ាងទៅ។ ទី២ ទៀតគឺថា ទីក្រុងភ្នំពេញក៏មិនអាចដោះស្រាយស្បៀងដោយខ្លួនឯងបាន តាមមាគ៌ាឯករាជ្យម្ចាស់ការរបស់កម្ពុជាប្រជាធិបតេយ្យ។ អានេះខ្ញុំយល់បានពីរប៉ុណ្ណឹង។

**ស៖** ចាសសូមអរគុណ។ នៅត្រង់សំណួរដដែល លោកបានរំឭកថានិស្សិតខ្មែរដែលត្រឡប់មកពីប្រទេសបារាំង អាល្លឺម៉ង់ជាដើម។ ខ្ញុំចង់សួរបញ្ជាក់លោកថា នៅពេលដែលនិស្សិតខ្មែរទាំងនោះ មកដល់តំបន់១០៣ តើពួកគេមកដំណាលគ្នាជាមួយនឹងប្រជាជនដែលគេជម្លៀសមកពីភ្នំពេញ ឬក៏ពួកគេមកតាមក្រោយ?

[០៩:៤២:៤៨]

**ឆ៖** តាមដែលខ្ញុំដឹង គឺពួកនិស្សិតដែលមកពីបកបរទេស គឺមកជាបន្តបន្ទាប់តាមក្រោយមក មិនមែនមកជាអង្គភាពអីធំដុំទេ។ ម្តង១០ ម្តង២០នាក់អីហ្នឹង។ តាមអង្គការរៀបចំចាត់តាំងឲ្យទៅនៅតំបន់១០៣នោះ។

**ស៖** ចាសសូមអរគុណ។ ពាក់ព័ន្ធទៅនឹងប្រជាជនដែលគេជម្លៀសមកទីក្រុងភ្នំពេញ និងនិស្សិតខ្មែរនៅពេលដែលមកដល់តំបន់១០៣ តើគេតម្រូវឲ្យពួកគេផ្តល់ប្រវត្តិរូប ឬក៏ជីវប្រវត្តិផ្ទាល់ខ្លួនដែរឬទេ?

**ឆ៖** នៅខាងខ្ញុំអត់បានដឹងទេ គឺគេឲ្យទៅតាមសហករណ៍ ហើយនិងស្រុក។ រីឯការធ្វើប្រវត្តិរូបអីៗហ្នឹង គឺគេធ្វើតាមស្រុក ឬក៏ស្រុកតំបន់ ឲ្យនៅតំបន់។

**ស៖** ចាសសូមអរគុណ។ ពាក់ព័ន្ធទៅនឹងប្រជាជនថ្មីដែលត្រូវបានគេបញ្ជូនមកតំបន់១០៣ នៅក្នុងបទសម្ភាសន៍របស់លោកជាមួយនឹងអ្នកស៊ើបអង្កេតនៅត្រង់សំណួរចម្លើយលេខ១៧នេះដដែល លោកបានបញ្ជាក់ថា ខ្ញុំសូមដកស្រង់ “ពួកអ្នកដែលគេជម្លៀសមកនេះ ធ្វើការតាមសហករណ៍ផ្សេងៗ និងអ្នកដែលមានជំនាញមួយចំនួនគេឲ្យទៅនៅខាងរោងជាង ដូចជាជាងក្រឡឹងជាដើម។ ប្រជាជនថ្មីទាំងនោះភាគច្រើនស្លាប់ដោយខ្វះចំណីអាហារ និងជំងឺ”។ បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំសួរទៅលោក ថាតើមូលហេតុអ្វីបានជាប្រជាជនថ្មីភាគច្រើនបានស្លាប់ដោយសារខ្វះចំណីអាហារ ឬដោយសារជំងឺយ៉ាងដូច្នេះ?

[០៩:៤៥:៤៥]

**ឆ៖** សភាពការណ៍នេះគឺខ្ញុំដឹងតាមមើលឃើញនឹងភ្នែករបស់ខ្លួនឯងទេ គឺចែកទៅតាមសហករណ៍មិនទាន់មានពិសោធន៍។ ដូចជាសហករណ៍បោះប៊ុ ដែលនៅជាប់នឹងរវៀងហ្នឹង គឺយកប្រជាជនហ្នឹងដែលឲ្យទៅសហករណ៍ហ្នឹង សហករណ៍ហ្នឹងឲ្យទៅធ្វើភូមិថ្មីនៅនឹងគេហៅថា បុសសៀមហ្នឹង គឺនៅដោយមួយក្រុមគាត់ហ្នឹងទៅ។ ដូច្នេះគឺមាន -- ហៅថាការដោះស្រាយស្បៀងវាអត់មានមូលដ្ឋានអីគឺចម្ការក៏កាប់ថ្មី ស្រែក៏ធ្វើថ្មី ដូច្នេះស្បៀងវាខ្វះខាត។ បើនៅក្នុងភូមិចាស់ៗគេនេះគឺជីវភាពដូចភូមិចាស់ៗវាដូចចាស់ន៉ុងដែរ វាមានស្រូវអង្ករ មានដំណាំដំណោចរបស់គេទៅ ហូចចុកទាំងអស់គ្នាទៅ។ អាហ្នឹងគឺមិនមានទេ គឺដូចជានៅភូមិបុសសៀមហ្នឹង ឃើញថាភូមិន៉ុងគឺមានការស្លាប់។ ដល់ដកពិសោធន៍ទៅគឺថារស់នៅដោយឯករាជ្យខ្លួនឯង វាមិនម្ចាស់ការ បានបញ្ចូលមកនៅក្នុងភូមិចាស់វិញ បញ្ចូលក្នុងសហករណ៍នៅភូមិចាស់ហ្នឹងរស់នៅជាមួយប្រជាជនចាស់ៗនៅន៉ុងវិញ។ អាហ្នឹងសូមមានយោបល់ប៉ុណ្ណឹង។

**ស៖** ចង់សួរបញ្ជាក់លោកថា ភាគច្រើននៃអ្នកដែលខ្វះចំណី ឬដោយសារ -- ស្លាប់ដោយសារជំងឺហ្នឹងគឺភាគច្រើនបំផុតហ្នឹងសុទ្ធតែប្រជាជនថ្មី ឬក៏មានលាយឡំនឹងប្រជាជនចាស់ដែរ?

[០៩:៤៧:៣៧]

**ឆ៖** បញ្ហាជំងឺន៉ុងគឺ ជាទូទៅវាអត់មានរើសចាស់រើសថ្មីអីទេ នៅក្នុងកាលៈទេសៈដែលយើងហៅថាដាច់ផ្លូវ ដោះស្រាយថ្នាំសង្កូវមិនទាន់ នៅមានថ្នាំបុរាណថ្នាំអីៗហ្នឹងដោះស្រាយវាមិនទាន់។ ប្រជាជនចាស់ក៏ឈឺ ប្រជាជនថ្មីក៏ឈឺ ហើយជាពិសេសគឺប្រជាជនថ្មីហៅថាទទួលជីវភាពថ្មីវាមានការ

ប្រែប្រួលជីវភាព ដូច្នេះវាច្រើនជាងប្រជាជនចាស់។ ប្រជាជនចាស់វាមានហៅថា *អីមីទីតេ* របស់គេនៅក្នុងខ្លួនទៅវាហៅថា វាស្រាលជាង។

**ស៖** ចាស សូមអរគុណ។ ខ្ញុំនឹងចូលដល់ប្រធានបទថ្មីមួយទៀតពាក់ព័ន្ធទៅនឹងមន្ទីរពាណិជ្ជកម្មតំបន់១០៣ ពីតួនាទីរបស់លោកនៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ នៅបទសម្ភាសន៍របស់លោកជាមួយនឹងអ្នកស៊ើបអង្កេត ត្រង់សំណួរចម្លើយទី២ លោកថា ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ -- គេសួរលោក ថាលោកធ្វើការនៅមន្ទីរ -- នៅកន្លែងណា? ហើយលោកបានឆ្លើយថា នៅមន្ទីរពាណិជ្ជកម្មតំបន់១០៣។ ខ្ញុំចង់សួរលោកថា នៅមន្ទីរពាណិជ្ជកម្មតំបន់១០៣ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកមានមុខងារ ឬតួនាទីអ្វីខ្លះ?

[០៩:៤៩:១៩]

**ឆ៖** តួនាទីរបស់ខ្ញុំនៅក្នុងអង្គភាពពាណិជ្ជកម្មហ្នឹង គឺដែលខ្ញុំរបួសហើយចេញពីពេទ្យទៅអង្គការឲ្យទៅនៅកន្លែងពាណិជ្ជកម្ម រឿងការងារមិនសូវធ្ងន់ធ្ងរ។ បញ្ហាទី១ គឺមើលឃ្លាំង គឺបញ្ជី១០០។ បញ្ហាទី២ គឺចែកចាយសម្ភារៈទៅតាមស្រុកមួយៗ។

**ស៖** មុននេះលោកឆ្លើយអំពីតួនាទីរបស់លោក។ ចុះតួនាទីជារួមរបស់មន្ទីរពាណិជ្ជកម្ម១០៣ហ្នឹងតើតួនាទីស្នូល ឬសំខាន់របស់គេហ្នឹងធ្វើអ្វីដែរ?

**ឆ៖** តួនាទីស្នូលរបស់ពាណិជ្ជកម្ម ១០៣នេះគឺបញ្ហាដល់រំដោះហើយ ៧៥ ហើយនេះគឺ មានមួយក្រុមមកនៅប្រមូលសម្ភារៈខោអាវអីហ្នឹង ប្រមូលសម្ភារៈប្រើប្រាស់អីដែលជាថានឆ្នាំងអីពីភ្នំពេញដឹកជញ្ជូនទៅក្នុងតំបន់។ បញ្ហាដែលសំខាន់គឺដឹកជញ្ជូនទៅដល់តំបន់ទៅ ដល់តំបន់ទៅបានមានការរៀបចំចែកចាយតាមស្រុកនោះមានខោអាវចាស់ៗ ដែលមកពីភ្នំពេញ ហើយសម្ភារៈប្រើប្រាស់ដូចថានឆ្នាំងអីយកទៅចែកចាយទៅតាមស្រុក ស្រុកគេចែកទៅសហករណ៍ទៀត។

**ស៖** ចុះប្រភេទសម្ភារៈ និងសម្លៀកបំពាក់ទាំងអស់ហ្នឹងគេចែកចាយទៅតាមស្រុកណាខ្លះដែរ?

**ឆ៖** សម្ភារៈទាំងអស់ដែលប្រមូលបានពីភ្នំពេញទៅគឺទៅចែកចាយគ្រប់ស្រុក ហើយស្រុកគេចែកទៅតាមសហករណ៍ទៀត។ មានចំនួនប្រជាជនរបស់គេ ទៅតាមស្រុកតិច ស្រុកច្រើន។ ស្រុកខ្លះច្រើនឲ្យច្រើនទៅ ស្រុកខ្លះតិចឲ្យតិចទៅ។

**ស៖** ចុះអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការកំណត់ចំនួនសម្ភារៈដែលត្រូវចែកចាយទៅតាមស្រុកហ្នឹង?

[០៩:៥១:០២]

**ឆ៖** ចំនួនសម្ភារៈដែលចែកចាយទៅក្នុងស្រុកគឺតាមរបបពិគ្រោះពិភាក្សាគ្នាពីប្រធានមន្ទីរមក ដល់ក្នុងក្រុមរបស់ខ្ញុំដែលនៅប្រចាំការហ្នឹង ហើយនិងមានកិច្ចការណាធំៗគឺការណែនាំមកពីតំបន់។

**ស៖** ចុះលោកដឹងទេថា តើតំបន់ ១០៣ហ្នឹងត្រូវទាក់ទងទៅថ្នាក់ដឹកនាំណាមួយទេ នៅទីក្រុង ភ្នំពេញដើម្បីទទួលបានសម្ភារៈទៅចែកចាយនៅតាមស្រុកនីមួយៗនោះ?

**ឆ៖** តំបន់១០៣ មានអ្នកទាក់ទងមកមានមួយក្រុមមកទាក់ទងជាមួយមជ្ឈិម។ អ្នកដែលមជ្ឈិម ហ្នឹងគឺមានដែលចែកចាយឲ្យទៅ១០៣ហ្នឹងគឺមានតាមខ្ញុំដឹងឮតែឈ្មោះទេ គឺមាន ឈ្មោះ ប៉ង់ ហើយនិង ប៉ូលិសហ្នឹងគឺមានឈ្មោះ គី តែប៉ុណ្ណឹង។

**ស៖** លោកសាក្សី តើមានពេលវេលាណាមួយ នៅក្នុងឆ្នាំណាមួយនោះលោកធ្លាប់បានធ្វើជា អនុប្រធានមន្ទីរពាណិជ្ជកម្មនៅតំបន់១០៣ ដែរឬទេ?

[០៩:៥៣:៤៨]

**ឆ៖** ខ្លួនខ្ញុំផ្ទាល់មិនដែលបានទទួលតួនាទីជាអនុប្រធានមន្ទីរពាណិជ្ជកម្មទេ មានតែសមាជិក ទទួលខុសត្រូវឃ្លាំង ទទួលខុសត្រូវចែកចាយហ្នឹង។ សមាជិកវាមានដឹកជញ្ជូនមាននៅឃ្លាំង។ រីឯ ប្រធាន អនុប្រធានអាហ្នឹងសម្រាប់ចាត់ចែងរួមហ្នឹង វាមានឈ្មោះ អៀន ហើយឈ្មោះ រិទ្ធ។

**ស៖** តើឈ្មោះ រិទ្ធ ហ្នឹងគាត់មានតួនាទីឋានៈអ្វីដែរនៅពេលនោះ?

**ឆ៖** ឈ្មោះ រិទ្ធ ហ្នឹងគាត់មានតួនាទីជាអនុប្រធាន។ ហើយគាត់នៅគ្រប់គ្រងទាំងអស់ ទាំងដឹក ជញ្ជូន ទាំងកន្លែងឃ្លាំង ទាំងការចាត់ចែង ទាំងអស់នៅជាមួយ អៀន ដែលជាប្រធាន គឺអ្នកទទួលខុស ត្រូវខ្ពស់នៅក្នុងមន្ទីរពាណិជ្ជកម្ម។ ទៅលើទៀតគឺមានឈ្មោះ ហង្ស។

**ស៖** គ្រាន់តែចង់សួរលោកបញ្ជាក់ថា ឈ្មោះ រិទ្ធជា អនុប្រធាន, អ៊ីចឹងឈ្មោះ ហង្ស ជាប្រធាន នៅពេលនោះ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** ឈ្មោះ រិទ្ធ នៅក្នុងក្របខ័ណ្ឌអនុប្រធានពាណិជ្ជទេ។ អៀន នោះ ជាប្រធាន។ ហង្ស នោះ ក្របខ័ណ្ឌតំបន់។

[០៩:៥៥:៣០]

**ស៖** សូមឲ្យលោកបញ្ជាក់ម្តងទៀតថា តើប្រធានមន្ទីរពាណិជ្ជកម្ម១០៣ហ្នឹងមានឈ្មោះអ្វី?

**ឆ៖** ប្រធានមន្ទីរពាណិជ្ជកម្ម១០៣ ឈ្មោះ អៀន។

**សះ** តើឈ្មោះ ភៀន ហ្នឹងគាត់ធ្វើជាប្រធាននៅមន្ទីរពាណិជ្ជកម្ម១០៣ហ្នឹង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យរហូត ឬក៏មានអ្នកឡើងមកជំនួសដែរ?

**ឆះ** ខ្ញុំសូមបញ្ជាក់ពីដើមគឺឈ្មោះ ភៀន ហ្នឹងកាលពីមុននោះគឺគាត់នៅខាងពាណិជ្ជកម្មខាង ក-១ នៅជាប់ជាមួយនឹងប្រធាន ឈ្មោះ បងម៉ាន។ ក្រោយពី បងម៉ាន ស្លាប់ទៅហ្នឹងក៏បានប្រមូលគ្នាមកនៅពាណិជ្ជកម្មនៅរវៀងទាំងអស់គ្នា។ គាត់ធ្វើជាប្រធានហ្នឹង។ ដូច្នេះអត់មានក-១ អត់មានខ-២ អត់គ-៣ អីទៀតទេ។ នៅតំបន់១០៣ តែមួយ។

**សះ** ចាស សូមអរគុណ។ ចង់ឲ្យលោកបញ្ជាក់ថា ទីតាំងមន្ទីរពាណិជ្ជកម្មនៅតំបន់១០៣ ហ្នឹងគឺស្ថិតនៅកន្លែងណាដែរ?

[០៩:៥៧:៣០]

**ឆះ** ទីតាំងពាណិជ្ជកម្ម១០៣ស្ថិតនៅក្នុងស្រុងរវៀង ទីរួមស្រុករវៀងតែម្តង។

**សះ** តើមានចម្ងាយប៉ុន្មានពីមន្ទីរពាណិជ្ជកម្ម១០៣ហ្នឹងទៅមន្ទីរតំបន់?

**ឆះ** តាមខ្ញុំស្មានគឺមិនមានអីវាស់វែងទេ គឺប្រហែលជា១៥គីឡូម៉ែត្រ។ មន្ទីរតំបន់នៅទម្លាប់ហើយនិងមន្ទីរពាណិជ្ជកម្មនៅរវៀង។

**សះ** ពាក់ព័ន្ធជាមួយនឹងការប្រជុំ តើបុគ្គលិកនៅៗក្នុងមន្ទីរពាណិជ្ជកម្ម១០៣ហ្នឹងធ្លាប់ចូលរួមប្រជុំជាប្រចាំជាមួយខាងមន្ទីរតំបន់ដែរឬទេ?

**ឆះ** ខាងមន្ទីរពាណិជ្ជកម្មតំបន់ធ្លាប់បានរួមជាមួយ ប្រជុំជាមួយតំបន់ជាសន្និបាត ជាប្រជុំពិសេសដូចមន្ទីរផ្សេងៗដែរ។

**សះ** តើសន្និបាត ឬក៏ការប្រជុំផ្សេងៗហ្នឹង ធ្វើឡើងជាញឹកញាប់ទេ? ប៉ុន្មានសប្តាហ៍ ឬប៉ុន្មានខែប៉ុន្មានដងដែរក្នុង១ឆ្នាំ? លោកចាំបានទេ?

[០៩:៥៩:២០]

**ឆះ** តាមដែលខ្ញុំចាំបាន គឺសន្និបាតអាចធ្វើគឺប្រហែលជា៣ខែម្តង។ ហើយនៅមានប្រជុំពិសេសអីទៀត តាមការកោះហៅរបស់ប្រធានតំបន់។

**សះ** ចុះគណៈស្រុកបានចូលរួមក្នុងការប្រជុំ ឬសន្និបាតហ្នឹងទេ?

**ឆះ** ពេលសន្និបាតគឺហៅប្រជុំទាំងអស់ ទាំងស្រុក គ្រប់ស្រុកហ្នឹង ហើយនិងគ្រប់មន្ទីរហើយនិងផ្នែកយោធាតាមព្រំដែនហ្នឹងមកធ្វើសន្និបាត។

**ស៖** ចុះជាទូទៅការប្រជុំហ្នឹងនិយាយអំពីអីដែរ ប្រធានបទនៃការប្រជុំពិសេសឬសន្និបាតហ្នឹង?

**ឆ៖** ខ្លឹមសារប្រជុំ ហើយនិងសន្និបាតហ្នឹង ខ្លឹមសារទី១ ហ្នឹងគឺប្រជុំអនុវត្ត បីតោនកន្លះ ប្រាំពីតោន តាមភារកិច្ចរៀងៗខ្លួន។ គឺពាក្យថា បីតោនកន្លះ ប្រាំពីរតោននោះ គឺដើម្បីសម្រុកឲ្យបានលទ្ធផលល្អ ជាយោធាក៏ដោយយោធាទៅ ដោយភារកិច្ច៣តោនកន្លះ ប្រាំពីរតោនទៅ ខំការពារតាមព្រំដែនទៅ។ ស្រុកខំដឹកនាំបង្កបង្កើនផលឲ្យបាន បីតោនកន្លះ ប្រាំពីរតោនទៅ ហើយមន្ទីរផ្សេងៗក៏សាធារណការពាណិជ្ជកម្មអីបែបចលនា៧តោន គឺខំធ្វើការឲ្យអស់លទ្ធភាព។ ហ្នឹងយល់ប៉ុណ្ណឹង។

[១០:០១:២១]

**ស៖** ចាស សូមអរគុណ។ ចុះមន្ទីរពាណិជ្ជកម្មតំបន់១០៣ មានការិយាល័យរបស់ខ្លួនប្រចាំនៅទីក្រុងភ្នំពេញទេ តាមដែលលោកដឹង?

**ឆ៖** តាមដែលខ្ញុំដឹងគឺមានស្នាក់ការមួយនៅភ្នំពេញ នៅជិតមាត់ទន្លេហ្នឹង។ មានមួយក្រុមនោះនៅធ្វើការសម្រាប់ដឹកជញ្ជូនអីវ៉ែអីវ៉ាន់ដាក់តាមកប៉ាល់ ដាក់តាមឡាន ដឹកជញ្ជូនទៅ១០៣នោះ។

**ស៖** ចុះលោកធ្លាប់មកដល់ស្នាក់ការនៅទីក្រុងភ្នំពេញហ្នឹងទេ?

**ឆ៖** ខ្ញុំធ្លាប់មកដល់ម្តង គឺដឹកអ្នករបួសមក គឺពេលចូលឆ្នាំអីហ្នឹងគឺមិនមាននរណាជូនអ្នករបួសមក ជូនឡានមក ខ្ញុំជូនមក ដាក់អ្នករបួសហ្នឹងមកដាក់នៅពេទ្យ១៧មេសា។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំចង់សួរលោកថា តើកម្មាភិបាលនៅតំបន់១០៣ណាខ្លះតាមដែលលោកដឹង ដែលធ្លាប់ត្រូវបានគេចាត់តាំងឲ្យមកធ្វើការនៅមន្ទីរពាណិជ្ជកម្មនៅទីក្រុងភ្នំពេញ ឬស្នាក់ការនៅភ្នំពេញនេះ?

**ឆ៖** តាមខ្ញុំដឹងកម្មាភិបាលដែលនៅប្រចាំការនៅភ្នំពេញនេះគឺគេចាប់អស់ហើយ ហើយមាននៅសល់ម្នាក់នេះគឺដូចជាមិនងាប់នៅក្នុងគុកទេ ហើយដល់ ៧៩នោះបានដោះលែងវិញ គឺមានបងថ្លៃ ឬក៏ប្អូនថ្លៃលោក ខៀវ សំផន នេះ ផុតពីនោះគេបាត់រូបអស់ហើយ បាត់ខ្លួនអស់ហើយ។

[១០:០៣:៣០]

**ស៖** ចុះលោកស្គាល់ឈ្មោះអ្នកដែលបាត់ខ្លួនអស់ទាំងនោះទេ? ហើយបងថ្លៃរបស់លោក ខៀវ សំផន ដែលលោករំឭកដល់ហ្នឹងមានឈ្មោះអ្វីដែរ?

**ឆ៖** បងថ្លៃលោក ខៀវ សំផន ដែលនៅរស់នោះ ចេញពីគុកនៅរស់ឈ្មោះ ឈន ហើយ អ្នកដែលផ្សេងៗទៀតហ្នឹងដែលស្លាប់អីដូចឈ្មោះ ពេញ នេះក៏បាត់ខ្លួនដែរ ហើយនិង ខ្ញុំចាំមិនអស់ដែរ។

ចាំបានតែឈ្មោះ ពេញ មួយហ្នឹងបាទ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស លោកសាក្សី សូមអរគុណ។ លោកប្រធាន ខ្ញុំសូមបញ្ចប់ការសាកសួរ ហើយសូមផ្ទេរវេទិកាបន្តឲ្យសហការីអន្តរជាតិរបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

[១០:០៤:៣៩]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សួស្តីលោក ព្រំ ស៊ូ! ខ្ញុំសូមសួរបន្តទៅលើអ្វីដែលលោកបានលើកឡើង។ លោកបានបញ្ជាក់ថា លោកមកមន្ទីរនៅភ្នំពេញម្តង ដើម្បីមកដឹកមនុស្សរបួស។ តើលោកអាចជម្រាបទេ តើនៅក្នុងឆ្នាំណាដែរ? ហើយហេតុអ្វីបានជាលោកមកដឹកមនុស្សឈឺនៅមន្ទីរភ្នំពេញ?

**លោក ព្រំ ស៊ូ៖**

**ឆ៖** តាមខ្ញុំចាំនោះ គឺថ្ងៃចូលឆ្នាំ ព្រោះថ្ងៃចូលឆ្នាំ គេអ្នកផ្សេងៗគេជាប់រវល់ចូលឆ្នាំ ចូលអីទៅបានខ្ញុំមានឱកាសហ្នឹងគឺជូនពេទ្យនោះមក។ ពេទ្យនោះឈ្មោះពេទ្យ ឆន។ ជូនមក នាំអ្នករបួសហ្នឹងមក ហើយមកឆ្នាំ១៩៧៥ហ្នឹងឯង ក្រោយរំដោះហើយ ផ្លូវទៅមានអីផង ជាប់ឡានតាមផ្លូវអីហ្នឹងមកជាមួយពេទ្យឈ្មោះពេទ្យ ឆន។ ខ្ញុំមកដល់ណេះ គឺប្រគល់ឲ្យគេនេះទៅ គេនាំទៅពេទ្យ១៧មេសា។

[១០:០៦:១១]

**ស៖** តើមនុស្សទាំងអស់នោះរបួសនោះដោយរបៀបណាដែរ?

**ឆ៖** តាមដែលខ្ញុំចាំនោះ អ្នករបួសនោះដូចជាគេហៅថា វាលកាំភ្លើង ឬអីដោយខ្លួនឯង មិនមែនក្នុងសមរភូមិប្រយុទ្ធទេ។ ហើយចាំបាច់ត្រូវតែដឹកមក។

**ស៖** ខ្ញុំចង់សុំសួរបន្តទៅនឹងសំណួរដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ និងខ្សែសង្វាក់គ្រប់គ្រងនៅតំបន់១០៣ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោកបានបញ្ជាក់ថា ហង្ស គឺជាលេខាតំបន់១០៣ ក្រោយ បងម៉ន ស្លាប់នៅក្នុងឆ្នាំ១៩៧៤។ ហើយលោកនិយាយនៅក្នុងកំណត់ហេតុចៅក្រមស៊ើបអង្កេត

ថា ហង្ស បន្តធ្វើជាលេខារហូតទៅដល់ចុងឆ្នាំ១៩៧៧។ ដូច្នេះខ្ញុំសូមសួរពាក់ព័ន្ធទៅនឹងរយៈកាលដែល ហង្ស គឺជាលេខាតំបន់។

ឯកសារមួយដែលបានទទួលយកមកដាក់ចូលក្នុងពេលជំនុំជម្រះនេះ គឺកំណត់ហេតុចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ គឺកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ទាក់ទងទៅនឹងការងារមូលដ្ឋាន, ឯកសារ E3/232។ បញ្ជីនៃអ្នកចូលរួមនៅក្នុងពេលប្រជុំមាន លេខាប៉ុល ពត, អនុលេខា នួន ជា, ខៀវ សំផន ហៅ ហែម និងអ្នកតំណាងមកពីតំបន់១០៦ ដែលក្នុងនោះមានសមមិត្ត សុខ តំណាងមកពីតំបន់១០៣ មានសមមិត្តហង្ស ចូលរួម។ តើលោកអាចបញ្ជាក់ជូនយើងខ្ញុំដែរឬទេ តើហង្ស នេះជាលេខាតំបន់១០៣ នៅត្រឹមថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែរឬទេ?

[១០:០៩:០៥]

**ឆ៖** តាមខ្ញុំចាំ ឈ្មោះ ហង្ស នេះគឺមានបានចាត់តាំងមុនឆ្នាំ១៩៧៦ ហើយមុន ក្រោយពី បងម៉ាន គាត់ស្លាប់ទៅហ្នឹង គឺចាត់តាំងមិនទាន់មានបញ្ជូនមនុស្សអីទៅទេ គឺចាត់តាំងគាត់ស្ដីទី បន្តមកទើបពេញ សិទ្ធិ ប្រហែលជា៧៥អីហ្នឹង។ ដល់៧៦ហ្នឹង គាត់ជាប្រធានតំបន់ពេញសិទ្ធិហើយ។ ព្រោះបងម៉ាន គាត់ ស្លាប់នៅប្រហែលជាចុងឆ្នាំ១៩៧៤ហ្នឹងឯង។ គាត់មកមើលខ្ញុំរបួសរួច ត្រឡប់ទៅវិញ ក៏ធ្វើឲ្យគ្រោះ ថ្នាក់ទៅ ស្លាប់។

**ស៖** តើលោកបានដឹងដែរឬទេក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ តើលោកដឹងដែរឬទេថា ប្រធាន ឈ្មោះ ហង្ស នេះបានធ្វើដំណើរមកទីក្រុងភ្នំពេញដើម្បីជួបជាមួយនឹងថ្នាក់ដឹកនាំ។ តើលោកដឹងទេ?

**ឆ៖** ការងារមកប្រជុំជាមួយខាងលើ ខាងមជ្ឈិមអីនោះ គឺគាត់មិនបានប្រាប់ទេ គឺគាត់មក ដោយឡែក មាននីរសារគាត់មក បើកឡានបើកអីជូនមក មិនបានប្រាប់កន្លែងអង្គភាពអីទេ។ ជួនកាល គាត់ប្រាប់ឲ្យអ្នកណាទៅនៅស្ដីទីជំនួសគាត់មួយរយៈទៅ គាត់ប្រាប់តែអ្នកនោះឯង។

**ស៖** តើលោកអាចជម្រាបទេ តាមចំនួនប្រហាក់ប្រហែល តើសមមិត្ត ហង្ស នេះអវត្តមានពី តំបន់ដែលគាត់គ្រប់គ្រងនេះញឹកញយប៉ុនណាដែរ?

**ឆ៖** ខ្ញុំភ្លេចមិនបានដែរ អាហ្នឹងគឺជាការងារ ព្រោះពេលនោះលាក់ការណ៍របស់គេ ការងារអ្នក ណា អ្នកនោះដឹង ហើយដល់អ្នកផ្សេងមិនដឹងដែរ។

[១០:១១:៤៥]

**ស៖** ខ្ញុំចង់អានន្ទូវផ្នែកដកស្រង់មួយចេញពីថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ កំណត់ហេតុរបស់

គណៈអចិន្ត្រៃយ៍ ដែលក្នុងនោះសមមិត្ត ហង្ស និយាយអំពីស្ថានភាពនៅតំបន់។ តាមរបាយការណ៍កំណត់ហេតុគឺចំណុច២ ចុច៣។ នៅក្នុងពេលប្រជុំ ហង្ស "បានមានបងប្អូនជាច្រើននៅតាមការដ្ឋានគឺក្តៅខ្លួន និងឈឺ" បញ្ចប់ការដកស្រង់សម្តី។ គាត់ក៏បានរាយការណ៍អំពីស្ថានភាពខ្មាំងនៅក្នុងតំបន់ ដោយលើកឡើងថាដកស្រង់សម្តី "តាមព្រំដែនថៃ ជាពិសេសនៅខេត្តពោធិ៍សាត់ ព្រះវិហារពុំមានសកម្មភាពរបស់ចារកម្មនោះទេ ប៉ុន្តែមានការចាប់ខ្លួនជនជាតិថៃ"។ បន្តមកទៀត ហង្ស បានរាយការណ៍ថា "មនុស្សជាង១០០នាក់ត្រូវបានចាប់ខ្លួន"។ តើលោកបានដឹងដែរឬទេ តើមានអ្វីកើតឡើងចំពោះជនជាតិថៃដែលគេជឿថាជាគិញនោះ នៅពេលដែលគេចាប់ខ្លួនពួកគេបាន? តើមានអ្វីកើតឡើងចំពោះពួកគេដែរ?

[១០:១៣:២០]

**ឆ៖** ខ្ញុំក្តាប់អត់បានដែរ បាទពីការចាប់ខ្លួនជនជាតិថៃ។ គឺដឹងតែមានជនជាតិថៃក្រហាមមកបោះទីតាំងនៅក្នុងស្រុកជាំក្សាន្ត នៅជិតមុំបី ដឹងតែប៉ុណ្ណឹងទេ ការចាប់ខ្លួនជនជាតិថៃអត់មានដឹង។

**សៈ** នៅក្នុងកិច្ចប្រជុំដដែលនោះ ហង្ស បានរាយការណ៍ជូនថ្នាក់ដឹកនាំនៅទីក្រុងភ្នំពេញថាមានមនុស្សជិត១០០នាក់ត្រូវបានចាប់ខ្លួនចាប់តាំងពីខែមករា។ ខ្ញុំចង់ឲ្យលោកមើលចម្លើយរបស់លោកទី១៤ នៅក្នុងកំណត់ស្តាប់ចម្លើយចៅក្រមស៊ើបអង្កេតចំណុច១៤ ដែលលោកឆ្លើយដូចតទៅ "កាលជំនាន់តាហង្ស ជាប្រធានតំបន់ក៏មានចាប់ដែរ ដូចជាគ្រូបង្រៀន អ្នករដ្ឋការ និងកម្មាភិបាលខ្លះ ដែលពាក់ព័ន្ធនឹងនយោបាយ តែតិចតួចទេ"។ បញ្ចប់ការដកស្រង់សម្តី។

តើលោកសំដៅទៅលើនរណាដែរ នៅពេលដែលលោកនិយាយថា អ្នករដ្ឋការនេះ? តើលោកអ្នករដ្ឋការនេះសំដៅលើនរណាដែរ ដែលនៅពេលនោះលោកនិយាយថា ជំនាន់ តាហង្ស នោះជាប្រធានតំបន់នោះមានការចាប់ខ្លួនរដ្ឋការ? អ្នករដ្ឋការនោះគឺជានរណា?

**ឆ៖** តាមខ្ញុំចាំបាន អ្នករដ្ឋការហ្នឹងគឺដូចប្រធានភូមិស្វាយដំណាក់ ឈ្មោះ គង់ ភូមិដែលខ្ញុំនៅហ្នឹងគឺត្រូវចាប់ខ្លួន១៩៧៥ ឬចុង ៧៥ អីនោះឯង។ ហើយតទៀត ទៅមានចាប់គ្រូបង្រៀនដែលជាបុគ្គលិកធ្លាប់ស្គាល់គ្នាជាមួយខ្ញុំអីហ្នឹងគឺនៅឆ្នាំ១៩៧៩ មានចាប់មួយចំនួនដែរ។

[១០:១៥:៥០]

**សៈ** នៅពេលដែលលោកនិយាយថា អ្នកដែលត្រូវបានចាប់ខ្លួនមួយចំនួនគឺជាកម្មាភិបាលខ្លះដែរ ដែលពាក់ព័ន្ធនឹងនយោបាយ។ តើលោកចង់មានន័យថាយ៉ាងម៉េចដែរ នៅពេលដែលលោកនិយាយពាក់ព័ន្ធនឹងនយោបាយ?

**ឆ៖** បញ្ហាពាក់ព័ន្ធនឹងនយោបាយ គឺជានយោបាយអតីតភាពដែលជានៅក្នុងជំនាន់ លន់ នល់ នៅក្នុងរបប លន់ នល់ នោះ អាហ្នឹងចង់សំដៅអ៊ីចឹងទេដែលពាក់ព័ន្ធនឹងនយោបាយនោះគឺនិន្នាការនយោបាយពីលន់នល់នោះមក។

**ស៖** លោកប្រធានខ្ញុំនៅពេលនេះចង់បង្ហាញឯកសារមួយជូនសាក្សី គឺ ឯកសារ E3/874។ គឺសារទូរលេខ ពីហង្ស ចុះថ្ងៃ១៨ ខែកក្កដា ឆ្នាំ៧៦ ផ្ញើជូនបងជាទីស្នេហា ចម្លងជូនបង នួន, បងវ៉ាន់ មន្ទីរ និងឯកសារ។ ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះជូនសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។

[១០:១៧:៥៤]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីផ្នែកនៅក្នុងឯកសារដែលខ្ញុំចង់ឲ្យលោកពិនិត្យមើលគឺចំណុចទីពីរជាពិសេស នៅចំណុចចាប់ផ្តើម គឺនិយាយអំពីរបាយការណ៍ពាក់ព័ន្ធទៅនឹង អឿន ដែលបានលើកឡើងដូចតទៅ: នៅថ្ងៃ១៤ ខែកក្កដា នៅពេលប្រធានទៅភ្នំពេញពេលអង្គភាពពាណិជ្ជនៅការដ្ឋានទំនប់ខ្វាំង វានៅផ្ទះ។ វាគំរាមរំលោភសេពកាមគ្រួសារយុវជននៅអង្គភាពពាណិជ្ជចំនួនប្រាំនាក់ ដែលសុទ្ធតែមានផ្ទៃពោះ។ ពេលនោះយុទ្ធជនម្នាក់បានទាន់ អាអឿន កំពុងចាប់គ្រួសារខ្លួន ក៏រត់ទៅរាយការណ៍ជូនមិត្តយើងក្នុងគណៈកម្មាធិការពាណិជ្ជ “បងប្អូនចាប់អាអឿនបាន”។ តាមការវិភាគរបស់ប្រធាននិងខាងគណៈពាណិជ្ជ--

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាមានការជំទាស់តវ៉ាពីមេធាវីការពារក្តីលោក ខៀវ សំផន។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន។

[១០:១៩:២០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសុំស្នើឲ្យតំណាងសហព្រះរាជអាជ្ញាគួរពិនិត្យទៅលើដំណើរការនីតិវិធីបង្ហាញឯកសារជាលក្ខណៈធម្មតា គឺឲ្យសាក្សីឆ្លើយថា ស្គាល់ឯកសារ ឬក៏ធ្លាប់បាន

អានឯកសារនេះពីមុនមកឬទេ មុននឹងតំណាងសហព្រះរាជអាជ្ញាបង្ហាញខ្លឹមសារតាមការដកស្រង់ដ៏វែងអន្លាយរបស់តំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះដើម្បីឲ្យស្របតាមនីតិវិធីដែលបានអនុវត្តកន្លងមក។ សូមអរគុណ។

**លោក ខេល លីសាក់៖**

លោកប្រធានខ្ញុំសូមឆ្លើយតប។ អញ្ញត្រកម្មមួយដែលយើងបានបង្កើតឡើង ជាពិសេសទៅលើឯកសារដែលយើងបានដាក់ ជាពិសេសទៅនឹងចំណុចដែលសាក្សីបានឆ្លើយរួចមកហើយ។ ដូច្នេះសាក្សីនោះគឺមានសិទ្ធិក្នុងការពិនិត្យ ឬផ្តល់សក្ខីកម្មទៅលើរបាយការណ៍ព័ត៌មានដែលពាក់ព័ន្ធទៅនឹងចំណុចទាំងឡាយដែលគាត់បានដឹង។ នេះជារបាយការណ៍មួយដែលពាក់ព័ន្ធទៅនឹងហេតុការណ៍កើតឡើងនៅក្នុងតំបន់១០៣។ ហើយក្រោមការណែនាំរបស់លោកប្រធាន គឺថាយើងអនុញ្ញាតឲ្យសាក្សីផ្តល់សក្ខីកម្មអំពីរបាយការណ៍និងសារទូរលេខដែលពួកគាត់នេះមានការពាក់ព័ន្ធ ឬបានដឹងទៅលើបញ្ហាឯកសារសារទូរលេខទាំងអស់នោះ។

[១០:២០:៤៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក អាកទូរ វែកកែន៖**

បាទ ដោយសង្ខេបទេ សាក្សីហ្នឹងអម្បាញ់មិញគាត់ជំទាស់ថា គាត់មិនមែនជាអ្នកទទួលខុសត្រូវនៃមន្ទីរពាណិជ្ជកម្មនោះទេ។ ហើយបើសិនជាគ្រាន់តែសួរគាត់អំពីព្រឹត្តិការណ៍ដែលមាននៅក្នុងឯកសារនេះ អ៊ីចឹងសហព្រះរាជអាជ្ញាអាចធ្វើបាន ប៉ុន្តែអ្វីដែលយើងជំទាស់នោះគឺថាគេបង្ខំឲ្យគាត់ទទួលស្គាល់ឯកសារមួយដែលគាត់អាចថាគាត់មិនស្គាល់ ហើយមិនព្រមសួរគាត់ថាតើគាត់ស្គាល់ឯកសារនោះដែរឬក៏អត់នោះ។

**លោក ខេល លីសាក់៖**

លោកប្រធាន សំណួរដែលអានជូនសាក្សីនេះ គឺវាត្រង់ផ្នែកនៅក្នុងឯកសារ ហើយយើងសួរថាតើគាត់ស្គាល់ទៅលើ ឬក៏បានដឹងប្រហាក់ប្រហែលទៅនឹងចំណុចដែលយើងបានអានជូនគាត់ដែរឬទេ? យើងមិនចង់ឲ្យសាក្សីនេះគឺអានទាំងស្រុងទៅលើឯកសារនេះ។ យើងគ្រាន់តែណែនាំ និងអានឲ្យសាក្សីបានដឹង ថាតើគាត់បានដឹងដែរឬទេ ហើយវាពាក់ព័ន្ធទៅនឹងប្រធានរបស់គណៈពាណិជ្ជដែលគាត់លើក -

- សាក្សីបានលើកឡើងថា មួយនេះគឺជាប្រធានតំបន់ដែលគាត់ធ្លាប់រស់នៅ។

[១០:២២:០៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:២២:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ឃើញថាបញ្ហានេះវាជាលក្ខណៈផ្សេងដោយឡែកមួយ ដែលវាពាក់ព័ន្ធទៅនឹងការបំពេញងាររបស់សាក្សីដែរ ទោះបីសាក្សីមិនមែនជាប្រធានក៏ដោយ ប៉ុន្តែជាសាក្សីនេះ រូបនេះក៏ជាអ្នកធ្វើការនៅមន្ទីរពាណិជ្ជដែលមានការពាក់ព័ន្ធទៅនឹងខ្លឹមសារនៃសារទូរលេខនេះដែរ ដែលអង្គជំនុំជម្រះត្រូវការស្តាប់នូវការផ្តល់នូវមតិយោបល់លើបញ្ហាដែលតំណាងសហព្រះរាជអាជ្ញាដកស្រង់មកសួរដើម្បីឲ្យសាក្សីឆ្លើយតបនេះ។ ដូច្នេះគឺអង្គជំនុំជម្រះអនុញ្ញាត។ សូមលោកតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរចំពោះសាក្សីរូបនេះទៀតចុះ នូវផ្នែកដែលពាក់ព័ន្ធ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

[១០:២៣:៥១]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** យើងខ្ញុំសូមបន្តទៀតលោកសាក្សី។ ខ្ញុំកំពុងតែអានត្រង់ផ្នែកមួយនៅក្នុងចំណុចកណ្តាលនៃចំណុចទី២។ តាមកាលវិភាគរបស់តំបន់ និងខាងគណៈពាណិជ្ជ ភឿន នេះអាចគោរពតាមមាគ៌ាសង្គមបាន។ ហើយនៅចុងក្រោយ កថាខណ្ឌចុងក្រោយ គឺខ្ញុំសូមដកស្រង់សម្តី “មនុស្សគ្រប់គ្នាគឺផ្តល់យោបល់ដូចគ្នាទៅលើប្រធានគណៈពាណិជ្ជនោះ។ ដែលថា ភឿន នេះលែងមានជំហរបដិវត្តន៍ គ្មានមធ្យោបាយណាកែប្រែគាត់នោះទេ។ ដូច្នេះគាត់ហ្នឹងអាចនៅតែក្បត់យើងបន្តទៀត។ ក្រៅពីបញ្ហាការក្បត់មាគ៌ាបដិវត្តន៍ បញ្ហាមួយគឺថាយើងត្រូវរកជនក្បត់ និងដកចេញ។ របាយការណ៍នេះគឺបានបញ្ចប់ស្នើសុំយោបល់ពីបក្សអំពីបញ្ហានេះ”។ ខ្ញុំចង់សុំសួរសំណួរទៅកាន់លោក តើលោកនឹកឃើញអំពីហេតុការណ៍នេះដែរឬទេ? ហើយលោកអាចជួយជម្រាប តើ ភឿន នេះជានរណាដែរ?

**ឆ៖** ខ្ញុំសូមជម្រាប ដូចខ្ញុំបានបញ្ជាក់ហើយគឺមិនមែនឈ្មោះ ភឿន ទេ គឺឈ្មោះ ភៀន ជាជនជាតិដែលធ្វើប្រធានពាណិជ្ជនេះ។ ហើយពេលដែលមានការចាប់ឈ្មោះ ភៀន នេះគឺខ្ញុំបានត្រូវទៅនៅ

ធ្វើស្រែនៅស្រែសាវ៉ាន់ហើយ។ គឺដោយការសម្រិតសម្រាំងសមាសភាព បើយើងសមាសភាពមិនល្អជាអតីតគ្រូបង្រៀនផងអីទៅ គេឲ្យទៅធ្វើស្រែនៅស្រែសាវ៉ាន់។ ដូច្នេះមានដឹងហ្នឹងខ្លះដែរ គឺនៅកន្លែងពាណិជ្ជនេះគឺមានអនុប្រធាននេះគឺបានចាប់ បងភៀន នេះយកទៅដាក់នៅមន្ទីរសន្តិសុខតំបន់កន្លែង បងហុងនេះ។ ដូច្នេះជាដើម ដំណើរដើមទងនេះគឺ មកពី បងរិទ្ធ នោះទេដែលដឹងរឿងរ៉ាវអីនៅក្នុងកន្លែងមន្ទីរពាណិជ្ជនៅវៀងនេះ។ បងហុង ក៏នៅធ្វើសេចក្ដីរាយការណ៍ទៅមជ្ឈិម ដើម្បីសុំយោបល់ពីមជ្ឈិមអីប៉ុណ្ណឹងទេ តាមខ្ញុំយល់។ នេះគឺប៉ុណ្ណឹងទេ។

[១០:២៦:៤៦]

**ស៖** ដើម្បីឲ្យយើងខ្ញុំយល់ច្បាស់ បុគ្គលមួយដែលមានឈ្មោះនៅក្នុងរបាយការណ៍នេះ គឺបុគ្គលដែលឈ្មោះ ភៀន ដែលជាប្រធានគ្រប់គ្រងតាមតំបន់នោះ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** នោះគឺជាការត្រឹមត្រូវហើយ ព្រោះ ភៀន នោះជាប្រធានហើយ។

**ស៖** តើលោកចាំទេ មានអ្វីកើតឡើងចំពោះ ភៀន ក្រោយមានរបាយការណ៍នេះបានបញ្ជូនដល់ថ្នាក់ដឹកនាំនៅឯទីក្រុងភ្នំពេញនោះ?

**ឆ៖** ក្រោយពីចាប់ខ្លួនទៅដាក់កន្លែងសន្តិសុខហើយនេះ ក្រោយពីរាយការណ៍នេះ គឺបាត់ឈ្មោះ ភៀន នេះ បាត់រូបឈ្មោះ ភៀន នេះតែម្ដង។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមបន្តចូលទៅដល់ឯកសារមួយទៀត ក៏ប៉ុន្តែខ្ញុំអាចបន្តទៅទៀតបានឬក៏លោកប្រធានចង់ឈប់សម្រាកនាពេលនេះសិន ដោយសារខ្ញុំត្រូវការផ្លាស់ប្ដូរប្រធានបទមួយផ្សេងពីនេះ។

[១០:២៨:០១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អ៊ីចឹងអង្គជំនុំជម្រះសូមប្រកាសសម្រាក ១៥នាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះដប់ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអង្គជំនុំជម្រះសូមជម្រាបភាគីតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីថា ពេលវេលាដែលយើងធ្វើសវនាការនៅព្រឹកនេះ យើងនឹងផ្អាកសវនាការនៅវេលាម៉ោងសម្រាកហ្នឹង នៅវេលាម៉ោងដប់មួយហាសិបនាទី ដោយសារមូលហេតុនៅរសៀលនេះ យើងនឹងធ្វើសវនាការឲ្យបានឆាប់រហ័ស គឺនៅម៉ោងចាប់ផ្ដើមម៉ោងមួយម្ភៃ

នាទី ក្នុងបំណាងលៃពេលវេលាសម្រាប់រសៀលនេះក្នុងការស្តាប់សក្ខីកម្មតាមសោតទស្សន៍។ អ៊ីចឹងហើយយើងសម្រាកតែ ១៥នាទីទេនៅពេលនេះ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនៅក្នុងអំឡុងពេលសម្រាក ហើយនិងអញ្ជើញគាត់ឲ្យត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់ប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៩ នាទី ដល់ម៉ោង ១០:៤៧ នាទី)*

[១០:៤៧:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីនៅពេលនេះខ្ញុំសូមអានជូនលោក ហើយសួរលោក ពាក់ព័ន្ធទៅនឹងឯកសារមួយទៀតគឺឯកសារ E3/1091។ គឺជាសារទូរលេខលេខ៥៣ ចេញពីតំបន់៨០១ បញ្ជូនទៅ៨៧0 ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៧៧។

[១០:៤៨:៤៨]

ខ្ញុំសូមអានកថាខណ្ឌទី១ នៃសារទូរលេខនេះ ដូចដែលបានសរសេរដូចតទៅ "យោងតាមសេចក្តីសម្រេចរបស់បក្ស ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការងារនៅតំបន់១០៣ សម្រាប់មួយរយៈពេល។ ខ្ញុំសូមរាយការណ៍អំពីសកម្មភាពរបស់ខ្ញុំដូចខាងក្រោម៖ ក្នុងរយៈពេល១០ថ្ងៃ ខ្ញុំធ្វើការងារនៅក្នុងស្រុកចំនួន

ប្រាំ : ប៉ៃលិន, សង្គមថ្មី, រវៀង ហើយនិងជាំក្សាន្ត។ ខ្ញុំធ្វើការងារមួយនឹងប្រធានស្រុក ប្រធានភូមិ និងមន្ទីរផ្សេងទៀតនៅក្នុងមន្ទីរ។ នៅក្នុងនោះគឺថារៀបរាប់អំពីបញ្ហាគោលនយោបាយ និងមាគ៌ារបស់បក្សផងដែរ"។ សូមបញ្ចប់ការដកស្រង់សម្ដី។ នៅក្នុងកំណត់ហេតុរបស់លោក លោកសាក្សី លោកបានរៀបរាប់អំពីបុគ្គលម្នាក់ឈ្មោះ កង ចាប ហៅ សែ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ នរណាគេគឺជា សែ នេះ?

**លោក ព្រំ ស៊ូរ៉ះ**

**ឆ៖** សែ នេះគឺជា កង ចាប ដែលចាត់តាំងជាប្រធានភូមិភាគឧត្តរថ្មីនៅសៀមរាប។ ឧត្តរថ្មីនេះ មាន១០៦, ១០៣ ដល់ឧត្តរចាស់នៅខេត្តកំពង់ធំ។

**ស៖** តើលោកនៅចាំទេ កងចាប មកធ្វើការនៅតំបន់១០៣ ១០ថ្ងៃនៅខែសីហា ឆ្នាំ១៩៧៧ ដែរឬទេ? នៅពេលនោះដែលគាត់កោះប្រជុំនូវកម្មាភិបាលថ្នាក់ស្រុកដែរឬទេ?

**ឆ៖** ជាដំបូងបង្អស់គឺលើការប្រកាសចាត់តាំង កងចាប ជាប្រធានភូមិភាគណាគឺក្រោមអធិបតីរបស់អ៊ំ នួន ជា នៅមន្ទីរទម្លាប់នេះគឺប្រកាសបានស្គាល់ត្រឹមហ្នឹង។

**ស៖** បាទ ខ្ញុំនឹងសួរសំណួរមួយចំនួនអំពីការប្រជុំនេះដែល នួន ជា វត្តមាននៅពេលខាងមុខនេះបន្តិចទៀត។ ប៉ុន្តែមុននឹងចូលទៅដល់ចំណុចនេះខ្ញុំចង់សួរលោកអំពីបញ្ហានៅក្នុងឯកសារមួយ ឯកសារ E3/1144 នេះគឺជាសារទូរលេខ ដែលចេញមកពី កង ចាប ហៅ សែ ជូនទៅគណៈមន្ទីរ៨៧០ ដែលចុះថ្ងៃទី០៨ បាទ ដែលចម្លងជូន បង វ៉ន, បង វ៉ាន់, បង ខៀវ ជាដើម។ ហើយនៅខាងចុងនៃផ្នែកនេះ នៃតេឡេក្រាមនេះគឺមានរបាយការណ៍អំពីស្ថានសភាពការណ៍ខ្មាំងផ្ទៃក្នុងបាទ។ ដែលក្នុងនោះ សែ បានរាយការណ៍ដូចខាងក្រោមនេះ។

[១០:៥២:៣៦]

ខ្ញុំសូមអានជូនផ្នែកនេះជូនលោក សូមដកស្រង់ "នៅមូលដ្ឋានមន្ទីរ ក្រសួងហើយនិងមន្ទីរយោធាយើងបានរកឃើញខ្មាំងជាច្រើនដែលស៊ីរូងផ្ទៃក្នុងតាមរយៈចារកម្មទៅបដិវត្តន៍ ហើយនិងតាមរយៈតាមចម្លើយ។ ឯពួកខ្មាំងជារដ្ឋការ និងប៉ូលិស ទាហានចាស់យើងរកឃើញជាបន្តបន្ទាប់"។ សូមចប់សេចក្ដីដកស្រង់។ ខ្ញុំចង់សួរលោកជាបឋមថា តើអតីត មន្ត្រីទាហាន ហើយនិងប៉ូលិស លន់នល់តើគេចាត់ទុកថាអ្នកទាំងអស់នោះជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** តាមខ្ញុំដឹងពេលនោះគឺក្រោយពីការចាត់តាំងកងចាបជាប្រធានភូមិភាគហើយ ខ្ញុំគឺមាន

មនុស្សរប៉ាត់រប៉ាយអស់ហើយ កម្មាភិបាលចាប់មួយចំនួនទៅ ហើយនៅសល់គោ ក្របីសេះ អីហ្នឹងខ្ញុំក៏ប្រមែប្រមូលទៅបានពីរនាក់ អ្នកដែលពិការដៃទាំងពីរនាក់ទៅឃ្វាលនៅតែក្នុងព្រៃ។ ដូច្នេះ បញ្ហាអីផ្សេងៗមិនសូវដឹងទេ គឺមិនដឹងតែម្តងព្រោះនៅក្នុងព្រៃមើលគោ មើលក្របីហ្នឹង។ នេះសូមឆ្លើយប៉ុណ្ណឹង។

**ស៖** តើលោកអាចប្រាប់តុលាការបានទេ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ១៩៧៩ តើតំបន់១០៣ ធ្លាប់បានស្វែងរកចំពោះបុគ្គល ឬក៏មន្ត្រីយោធាទាហានអ្វីរបស់ លន់ នល់ ដែរឬទេ ដែលគេចាត់ទុកថាជាខ្មាំងនោះ?

[១០:៥៤:៥៧]

**ឆ៖** ក្រោយថ្ងៃ១៧ មេសាទៅ គឺទាហាន លន់ នល់ ហើយនិងមន្ត្រីរាជការរបស់ លន់ នល់ នោះគឺនៅតាមសហករណ៍ មួយចំនួនទៀតក៏ប្រគល់ទៅតាមអង្គភាពៗបង្កបង្កើនផល។ អាហ្នឹងគឺតាមខ្ញុំដឹងដូចជាមិនមានការបោសសម្អាតអីដែរ គឺបញ្ហាសំខាន់ គឺប្រមូលទៅដាក់កន្លែងបង្កបង្កើនផលនេះ ហើយនិងបង្កបង្កើនផលតាមសហករណ៍។ ក្រៅពីហ្នឹងទៀតខ្ញុំមិនដឹងដែរទេ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំចង់ត្រឡប់ទៅប្រធានបទដែលលោកបានយោងពី៣នាទីខាងមុខនេះ។ លោកនិយាយថា អំពីការប្រជុំចាត់តាំងកម្មាភិបាលនៅភូមិភាគឧត្តរថ្មីដែលលោក នួន ជា ជាអធិបតីនាកាលនោះ។ សូមលោកជម្រាបតុលាការជាបឋម ថាតើការប្រជុំនោះនៅក្នុងថ្ងៃខែឆ្នាំណា? ហើយនៅប្រជុំនៅទីកន្លែងណាតាមដែលលោកចាំ?

[១០:៥៦:២៣]

**ឆ៖** តាមដែលខ្ញុំចាំនោះគឺ ពេលនោះខ្ញុំមកនៅធ្វើការរដ្ឋាននៅជិតមន្ទីរតំបន់។ គឺនៅជុំវិញតំបន់នៅភូមិទម្លាប់។ ហើយមានធ្វើសាលាប្រជុំ សាលាអីតំបន់ ធ្វើសាលាប្រជុំហ្នឹង។ តែខ្ញុំក៏ពេលប្រជុំហ្នឹងគឺតំបន់ហ្នឹងក៏មានហៅខ្ញុំទៅចូលរួមដែរ។ ហើយនិងប្រធានអង្គភាពផ្សេងៗ ស្រុកអីៗហ្នឹងទៅប្រជុំហ្នឹងគឺប្រកាសរៀបចំក្រោមអធិបតីអ៊ំ នួន ជា នេះគឺប្រកាស កង ចាប ហៅ សែ នេះគឺជាប្រធានភូមិភាគព្រោះឥឡូវនេះឲ្យនៅស្វយ័តហើយ។ ១០៣ក៏ដោយ ១០៦ក៏ដោយ ១០៤ក៏ដោយ គឺឈប់នៅស្វយ័ត គឺទៅបង្កើតជាភូមិភាគ ហើយនៅសៀមរាបនេះ ប្រហែលជាក្នុងឆ្នាំ១៩៧៧ អីហ្នឹង ចុង៧៧អីហ្នឹង។

**ស៖** តើលោក នួន ជា បាននិយាយក្នុងការប្រជុំនោះរយៈពេលប៉ុន្មានដែរ?

**ឆ៖** ពេលប្រជុំនោះ គឺតែមួយព្រឹកទេ គឺហ្នឹងបែកគ្នាទៅ មិនមានហូបបាយរួមហូបអីទេ គឺ

ជជែកគ្នាតែរហូតតាមកន្លែងរៀងៗខ្លួនទៅ។ ប៉ុន្តែហៅថាកម្មាភិបាលខ្លះដែលទៅពីឆ្ងាយអីៗនេះក៏មានកន្លែងខ្ញុំនេះទៅមិនទាន់ក៏ហូបបាយកន្លែងខ្ញុំទៅ។

[១០:៥៨:២៨]

**ស៖** ហើយនៅក្នុងការប្រជុំនោះ ដែលថាប្រើពេលអស់មួយព្រឹកនេះ ខ្ញុំចង់ដឹងថាតើលោក នួន ជា បាននិយាយប្រហែលជារយៈពេលប៉ុន្មានក្នុងមួយព្រឹកហ្នឹងបាទ?

**ឆ៖** ក្នុងមួយព្រឹកនេះ គឺមិនមាននិយាយអីច្រើនផង និយាយពីសភាពការណ៍គឺតំបន់នោះត្រូវចូលទៅភូមិភាគទៅ ហើយនិងសភាពការណ៍បង្កបង្កើនផលបីតោនកន្លះ ប្រាំពីរតោនហ្នឹង។ គឺយកឲ្យបានជោគជ័យហ្នឹង គឺខំបិតទំនប់ ជីកប្រឡាយ រកជី ហ្នឹងឲ្យបានបីតោនកន្លះ ប្រាំពីតោន។ ហើយនិងការរៀបចំប្រជុំជាសម្ងាត់អី ចាត់តាំងតំបន់អីទៀតហ្នឹង ខ្ញុំអត់ដឹងដែរទេ ដឹងតែប្រជុំប៉ុណ្ណឹង ចប់ទៅ។ ការប្រជុំផ្សេងៗទៀត អាហ្នឹងខ្ញុំអត់បានដឹង បានចូល បានរួមទេ។

**ស៖** នៅក្នុងកិច្ចប្រជុំដែលលោកបានចូលរួមនោះ តើ នួន ជា បាននិយាយអំពីស្ថានភាពខ្មាំងសភាពខ្មាំងទេ? ដូចជាៗការមានភ្នាក់ងារ សេ.អ៊ី.អា, កា.ហ្សេ.បេ តើគាត់ធ្លាប់បាននិយាយបែបនេះទេ?

[១១:០០:០៣]

**ឆ៖** តាមខ្ញុំបាន -- តាមខ្ញុំចាំបាននោះ គឺគាត់មាននិយាយដែរ ដូចថាយើងត្រូវរស់នៅមូលដ្ឋានអីចឹង គឺត្រូវប្រុងប្រយ័ត្ន ព្រោះភ្នាក់ងាររបស់ខ្មាំងវាធ្វើសកម្មភាព បង្កប់ស៊ីរូងអីហ្នឹង មានបាននិយាយនិយាយតិចដែរ។ អាហ្នឹងគ្រាន់ជាពាក្យប៉ុណ្ណឹង គាត់និយាយច្រើននោះ តែការបង្កបង្កើនផលដើម្បីបីតោនកន្លះ ទៅដល់ប្រាំពីរតោនហ្នឹង ហើយនិងរៀបចំភូមិភាគប៉ុណ្ណឹងទេ។

**ស៖** សូមលោកប្រាប់ខ្ញុំឲ្យលម្អិតបន្តិចថា តើគាត់និយាយជាក់លាក់អំពីការបង្កបង្កើនផលស្រូវនោះយ៉ាងដូចម្តេច គឺថាពីបីតោនកន្លោះ ទៅប្រាំពីរតោនក្នុងមួយហិកតានោះ តើគាត់បានកំណត់ពីគោលដៅសម្រាប់ -- ទិសដៅសម្រាប់តំបន់ទេដែលសេចក្តីបញ្ជាក់របស់លោក នួន ជា ទាក់ទងទៅនឹងទិសដៅរបស់តំបន់មួយៗគាត់បានបញ្ជាក់ដែរឬទេ?

**ឆ៖** ទិសដៅបីតោនកន្លះ ប្រាំពីរតោនេះ បញ្ហាទី១ ដើម្បីកែប្រែជីវភាពរបស់តំបន់នោះឲ្យបានហូបចុកគ្រប់គ្រាន់ និងធូរធារ ព្រោះថាតំបន់ហ្នឹងវាប្រជាជនធ្វើស្រែតិចតួចគ្រាន់តែមួយហូបគ្រប់ៗប៉ុណ្ណឹងទេ។ ហើយដល់ជម្លៀសប្រជាជនពីភ្នំពេញទៅទៀត វាត្រូវបន្ទុកទៅដល់ដីស្រែ ទៅលើផលដំណាំហ្នឹងថែមទៀត។ ដូច្នេះគាត់ថាត្រូវតែជំរុញបីតោនកន្លះ ប្រាំពីរតោននេះ សំខាន់បំផុតនោះ គឺឲ្យ

ហូបចុកបានគ្រប់គ្រាន់ និងបរិបូណ៌ អាហ្នឹងគឺឲ្យហូប១ថ្ងៃបានបីពេលអីអ៊ីចឹង។ ១០ថ្ងៃមានបង្អែមម្តង ហើយនិងចិញ្ចឹមឲ្យបានច្រើនហូបចុកបរិបូណ៌។ អាហ្នឹងប៉ុណ្ណឹងទេ។ រីឯទិសដៅថា ដើម្បីយកផលបីតោនកន្លះ ប្រាំពីរតោនហ្នឹង ទៅអីណាទៅអីណីទៀត គឺគ្មានទេក្នុងតំបន់១០៣នេះ ហូបចុកឲ្យបានគ្រប់គ្រាន់អាហ្នឹងអរហើយ។ ហើយបើដឹកជញ្ជូនទៅណាក៏អត់មានផ្លូវដឹកជញ្ជូនអី គ្មានមធ្យោបាយដឹកជញ្ជូនអីទៅណាទៀតទេ។

[១១:០២:៥៣]

**ស៖** តើលោកដឹងដោយរបៀបណាដែលថា អ្នកដែលនិយាយក្នុងអង្គប្រជុំនោះ គឺជា នួន ជា នោះ លោកដឹងដោយរបៀបណា?

**ឆ៖** គឺបានទៅអង្គុយប្រជុំផ្ទាល់ ហើយដែលពេលសម្រាកហ្នឹងគាត់ដើរទៅទស្សនានៅការដ្ឋានអង្គភាពរបស់ខ្ញុំដែរ។ ហើយឲ្យអ្នកដាំបាយដាំអីហ្នឹង ហើយអ្នកដែលទៅជាមួយហ្នឹងលូកស្ពៃជ្រក់អីហ្នឹងដាក់យកទៅឲ្យគាត់ផង។ អាហ្នឹងស្គាល់ហើយ។

**ស៖** តើលោកបានដឹងដែរឬទេថា លោក នួន ជា មានឋានៈ ឬក៏តំណែងជាអ្វីនៅកាលនោះ?

**ឆ៖** នៅកាលនោះតាមខ្ញុំដឹងច្បាស់ គឺដូចការចាត់តាំងផ្សាយតាមវិទ្យុនោះ គឺគាត់ជាប្រធានសភាកម្ពុជាប្រជាធិបតេយ្យនុ៎ង។

**ស៖** លោកក៏បានលើកឡើងគឺត្រង់ចម្លើយលេខ១០ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតលោកបានឆ្លើយថា "ក្រោយពេលប្រជុំដែលលោកបានចូលរួមនោះ នៅពេលនោះគឺថាវាមានការប្រជុំសម្ងាត់មួយដែលចូលរួមប្រជុំដោយ នួន ជា, កង ចាប ហើយនិងកម្មាភិបាលមកពីភូមិភាគនិរតីពីរនាក់ ដែលគេយកមកឲ្យគ្រប់គ្រង គឺតាឃឹម និងតាសារឿន"។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ធ្វើម្តេចទើបលោកបានដឹងថាមានការប្រជុំជាសម្ងាត់ដែលក្នុងនោះមានការចូលរួមមានវត្តមានតែ នួន ជា, កង ចាប តែបុគ្គលពីររូបទៀតតែប៉ុណ្ណោះ?

[១១:០៥:១៦]

**ឆ៖** ដែលខ្ញុំដឹងនោះ គឺតាមកាលវិភាគដែរទេ ព្រោះទៅប្រជុំប្រកាសៗតែភូមិភាគទេ គឺ កង ចាប ហើយនិង សែ។ រីឯតំបន់នោះគឺក្រោយពីប្រជុំហើយហ្នឹង បានមានការរៀបចំអី តាឃឹម ហើយនិង សារឿនហ្នឹង ទទួលខុសត្រូវតំបន់នេះ ហើយនិងបាត់ តាហង្ស នេះទៅ។ ហ្នឹងគឺដឹងប៉ុណ្ណឹង។ មិនដឹងប្រជុំត្រង់ណា ខ្លឹមសារឯណា គ្នាប៉ុន្មាននាក់អី ថែមអ្នកណាអ្នកណី ខ្ញុំអត់ដឹងដែរ។

E1/194.1

[១១:០៦:០០]

**ស៖** នៅក្នុងចម្លើយដដែល ចម្លើយទី១០ លោកបានឆ្លើយដូចតទៅ កិច្ចប្រជុំដែលធ្វើឡើងដោយ នួន ជា គឺនៅពេលនោះគឺមានការចាប់ខ្លួន បងហង្ស និងបុគ្គលដទៃទៀតនៅតំបន់១០៣។ តើលោកអាច ជម្រាបបានឬទេ ក្រោយការប្រជុំជាមួយនឹង នួន ជា រយៈប៉ុន្មានទើប ហង្ស បាត់ខ្លួន?

**ឆ៖** ក្រោយពីប្រជុំមិនជាយូរប៉ុន្មានទេ បាត់ខ្លួនបង ហង្ស ទៅ ហើយក៏ចាប់បណ្តើរៗទៀត កម្មាភិបាលនៅគ្រប់អង្គភាព នៅមន្ទីរតំបន់អីហ្នឹង ចាប់ជាបន្តបន្ទាប់គ្រួសារ បងហង្ស អីនេះ បងប្អូន បងហង្សអីនេះ ហើយកូននោះចាប់ជាបន្តបន្ទាប់។ យកឡានមកដឹក មិនមែនចាប់ទេ យកឡានមក ក៏ទៅបាត់ៗ។

**ស៖** ដើម្បីជាកំណត់ប្រតិចារឹក សាក្សីនេះបានឆ្លើយថា "កិច្ចប្រជុំ នួន ជា នេះធ្វើនៅចុងឆ្នាំ ១៩៧៧ ហើយមិនយូរប៉ុន្មានទេក្រោយពីប្រជុំនោះ គឺថា ហង្ស ត្រូវបានចាប់ខ្លួន" ឯកសារនេះគឺឯកសារ E3/442 (*ស៊ីក*) នៅក្នុងបញ្ជីសាក្សី។ នៅត្រង់លេខរៀង២២០ ដែលក្នុងនោះគឺមាន ហង្ស លេខាតំបន់ ១០៣ បានចូលមន្ទីរស-២១ នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨ នៅពេលនេះគឺថា ខ្ញុំសូមឲ្យសាក្សី--

[១១:០៧:២០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដូចជាមិនច្បាស់សោះ ថាតើការបន្ថែមចំណុចភស្តុតាងអម្បាញ់មិញនោះ គឺមានន័យយ៉ាងម៉េចនៅពេលនេះនោះទេ។ យើងស្តាប់សក្ខីកម្មរបស់សាក្សីមិនមែនមកបង្ហាញ ភស្តុតាងនោះទេ។ ដូច្នេះគោលបំណងនៃការលើកឡើងចំណុចណាមួយ ឬក៏ភស្តុតាងណាមួយ យកមក ដាក់ចូលប្រតិចារឹក ហើយលើកឡើងឲ្យសាក្សីបានដឹង ដូចជាការចាប់ខ្លួនរបស់បុគ្គលនេះ ថាវាមាន ពាក់ព័ន្ធ។ នេះគឺថាដូចជាមិនមានអ្វីដែលត្រូវអាចធ្វើទៅបានទេ នៅក្នុងកិច្ចដំណើរការនេះ។ ដូច្នេះហើយ ខ្ញុំសូមស្នើសុំឲ្យអង្គជំនុំជម្រះគូសចោលចំណុចដែលបានដាក់បញ្ចូលភស្តុតាងអម្បាញ់មិញនេះ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមឆ្លើយតប ចំណុចនេះ យើងធ្លាប់បានធ្វើឡើងរួចមកហើយកាលពីមុន ហើយអង្គជំនុំជម្រះ លើកឡើងថា ប្រសិនជា បើមានឯកសារភស្តុតាងណាពាក់ព័ន្ធគឺត្រូវតែលើកឡើងជូនដំណឹងដល់អង្គជំនុំ

ជម្រះនាពេលនុ៎ងតែម្តង។ នេះភស្តុតាងនេះគឺជាភស្តុតាងស៊ីសង្វាក់អំពីការដឹងរបស់សាក្សីទៅលើហេតុការណ៍ដែលកើតឡើងនៅពេលនោះ ដូច្នេះវាជាចំណុចល្អ និងពេលវេលាល្អដែលត្រូវយកមកដាក់បញ្ចូលឲ្យអង្គជំនុំជម្រះបានដឹង។ ដូច្នេះគួរអង្គជំនុំជម្រះគួរច្រានចោលការជំទាស់របស់ខាងមេធាវី។

[១១:០៩:៤៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១០:១៤]

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះបានទទួលយកនូវរបៀបក្នុងបង្ហាញរបៀបនេះច្រើនលើកច្រើនសារមកហើយតាំងពីចាប់ផ្តើមដំបូងនៃកិច្ចដំណើរការសវនាការ។ ដូច្នេះអង្គជំនុំជម្រះច្រានចោលនូវការជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាបន្តកិច្ចការរបស់លោកតទៅទៀត។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នៅក្នុងពេលនេះខ្ញុំសូមអានជូនសាក្សីនូវលិខិត ឬក៏សេចក្តីថ្លែងការណ៍មួយច្បាប់ដែលធ្វើឡើងដោយ -- ដែលសរសេរដោយលេខតំបន់១០៣ ហង្ស។ នៅព្រឹកថ្ងៃទី០៥ ខែមករា ឆ្នាំ៧៨ ក្រោយពីការចាប់ខ្លួន ហង្ស នេះភ្លាមៗ។ សេចក្តីថ្លែងការណ៍នេះ ឬលិខិតនេះគឺគាត់ ហង្ស នេះបានស្នើសុំឲ្យបក្សដោះលែងគាត់ ហើយគាត់បានបញ្ជាក់ថាគាត់មិនមែនជាជនក្បត់នោះទេ។ ឯកសារ E3/2470។

[១១:១១:២៦]

ចំណុចយោងដែលខ្ញុំអាននោះគឺត្រង់ខ្មែរ ERN 00296593 រហូតទៅដល់ 296594, អង់គ្លេស ERN 00768226 ដល់ 27, បារាំង 00842846 ទៅដល់ 47។ នៅក្នុងឯកសារនេះ “ហង្ស : បង និងបក្សជាទីស្នេហា និងមេដឹកនាំជាទីស្នេហា។ ខ្ញុំស្នើសុំឲ្យបងៗ និងបក្សជាទីស្នេហារកយុត្តិធម៌សម្រាប់ខ្ញុំ។ ខ្ញុំមិនដែលធ្លាប់គិត ឬក៏បន្តិចបន្តួចទាល់តែសោះក្បត់បក្ស។ ខ្ញុំមិនដែលចូលរួមការពិភាក្សាជាមួយនឹងខ្សែក្បត់នោះទេ។ បក្សបានពិនិត្យប្រវត្តិរូបរបស់ខ្ញុំ ហើយមើលឃើញថាខ្ញុំមិនមែនជាជនក្បត់នោះទេ។ ដូច្នេះសុំឲ្យបក្សទុកជីវិតខ្ញុំផង”។

នៅកថាខណ្ឌបន្ទាប់មកទៀត -- នៅមុននេះបន្តិចគឺ ហង្ស បានលើកឡើងអំពីហេតុផលផ្សេងៗ និងការចាប់ខ្លួនគាត់ ហើយបានលើកឡើងដូចតទៅ "ក្នុងអំឡុងពេលការប្រជុំលើកទី១ របស់ភូមិភាគ ៨០១ បងទី២ បានមកធ្វើជាគណៈធិបតីប្រជុំ។ នៅក្នុងកិច្ចប្រជុំនោះ គឺការបានលើកឡើងអំពីការបាត់ខ្សែ១០.០០០ខ្សែ ដោយនៅពេលនោះខ្ញុំមានការព្រួយបារម្ភណាស់។ ក្នុងពេលបណ្ដុះបណ្ដាលនោះ បងបាននិយាយអំពីគោលគំនិតមួយចំនួន បងបាននិយាយថា ហេតុអ្វីបានជាម៉ាស៊ីនកិនស្រូវតែងតែខូចជាញឹកញាប់។ ហើយនៅពេលដែលនិយាយដូច្នោះ គឺថាបងបានសំឡឹងមើលខ្ញុំ។ ក៏ប៉ុន្តែទោះបីជាខ្ញុំមានការភ័យខ្លាចក៏ដោយ ខ្ញុំមិនដែលធ្លាប់គិតថាខ្ញុំនឹងត្រូវបានបក្សចាប់ខ្លួនដោយចោទប្រកាន់ខ្ញុំថាក្បត់នោះទេ"។

[១១:១៣:៥៥]

លោកសាក្សី នៅក្នុងឯកសារនេះ ហង្ស បានលើកឡើងអំពីការសន្និបាត ឬប្រជុំលើកទី១ របស់ភូមិភាគ៨០១។ ការប្រជុំដែលលោកបានរៀបរាប់ជូនយើងខ្ញុំថា មានការចូលរួមដោយ នួន ជា នោះគឺការប្រជុំដែលយើងហៅថាជាការប្រជុំជួបជុំគ្នាសន្និបាតលើកទី១ របស់ភូមិភាគ៨០១ នេះឬក៏មិនមែនទេ?

**លោក ព្រុំ ស៊ូ៖**

**ឆ៖** ខ្ញុំអត់ដឹងទេ។ គឺតាមពិនិត្យទៅ គឺមិនទាន់ប្រជុំក្នុងគណៈកម្មការភូមិភាគទេ ៨០១ទេ គឺគ្រាន់តែប្រជុំតំបន់ ផ្នែកតំបន់ដែលត្រូវទៅបញ្ជាក់ ធ្វើការចាត់តាំងភូមិភាគប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំសូមសួរថា កិច្ចប្រជុំដែលលោកថាលោកបានចូលរួមហើយមាន នួន ជា មានវត្តមាននោះតើ ហង្ស បានចូមរួមដែរឬទេ?

**ឆ៖** តាមខ្ញុំចាំប្រជុំនេះគឺកម្មាភិបាលចាស់នៅខេត្តព្រះវិហារ នៅ១០៣ ទាំងអស់ហ្នឹងគឺមានទាំងអស់ដែរ គឺមានទាំង ហង្ស ទាំងអីទាំងអស់ អង្គភាពមន្ទីរនៅក្នុង១០៣ហ្នឹង។

[១១:១៥:៥០]

**ស៖** នៅពេលនេះខ្ញុំសូមត្រឡប់ទៅសួរអំពីលិខិតឆ្លើយឆ្លងមួយចំនួនដែលចាប់ផ្ដើមពីឆ្នាំ១៩៧៨ ឯកសារទី១គឺឯកសារ E3/918 គឺជាសារទូរលេខដែលផ្ញើជូនដោយលេខាភូមិភាគផ្ញើជូនទៅមន្ទីរ ៨៧០ ចម្លងជូន: បង , បងនួន, បងវ៉ាន់, បងវន, បងខៀវ, មន្ទីរ និងទុកជាឯកសារ។ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨" គឺប្រហែលជា ១អាទិត្យក្រោយពីការចាប់ខ្លួន ហង្ស។ នៅក្នុងឯកសារនេះ តំបន់១០៣ ត្រូវបានយកមកលើកឡើងនៅក្នុងកថាខណ្ឌចុងក្រោយ។ ដូច្នេះនៅពេលនេះខ្ញុំសូមអានការដកស្រង់ចេញពី

កថាខណ្ឌបន្ទាប់ពីកថាខណ្ឌចុងក្រោយដែលក្នុងនេះគឺជាការរាយការណ៍ជូននៅទីក្រុងភ្នំពេញដូចតទៅ៖ “យោងតាមការបង្ហាញរបស់សមមិត្តនៅក្នុងវគ្គរៀនសូត្របានឲ្យដឹងថា ឆ្នាំនេះជាទូទៅនៅក្នុងតំបន់ព្រះវិហារកន្លែងភាគច្រើនត្រូវអត់បាយមកពីការបង្កបង្កើនផល ស្ទូងឲ្យបានតែចំនួនច្រើន ឯគុណភាពជាផលបានតិច មូលហេតុកម្មាភិបាលបំភ្លើសបំភ្លៃ”។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានដែរឬទេពាក់ព័ន្ធទៅនឹងបញ្ហានៃការអត់បាយនៅតំបន់១០៣ ជាពិសេសនៅក្នុងអំឡុងខែមករា ឆ្នាំ១៩៧៨ នោះ?

[១១:១៧:៥៧]

**ឆ៖** តាមខ្ញុំដឹងគឺនៅក្នុងចុងឆ្នាំ១៩៧៧, ៧៨ ហ្នឹងគឺខ្ញុំទៅឃ្វាលគោនៅក្នុងព្រៃហើយ មិនដឹងជារឿងសភាពការណ៍ហ្នឹងយ៉ាងម៉េចដែរទេ គឺឃើញតែការចាប់ខ្លួនកម្មាភិបាល ហើយនិងយុទ្ធជនទេបញ្ជូនមកសៀមរាបបន្តបន្ទាប់ហ្នឹងហើយនិងមួយចំនួនដាក់នៅរវៀងហ្នឹង។ តែដោយតាមខ្ញុំជាក់ស្តែងខ្ញុំនៅមូលដ្ឋានហ្នឹង ពិតមែនតែនៅឃ្វាលគោមែន ក៏ប៉ុន្តែជាសភាពការណ៍ខ្ញុំក្តាប់បានដែរ គឺថាបញ្ហាតាំងពីដើមអើយមកនៅខេត្តព្រះវិហារគឺមិនដែលមានការអត់ឃ្លានអីទេ គឺបញ្ហាស្រូវអង្ករអីអត់ខ្វះបន្តិចបន្តួចភូមិស្រុកថ្មីៗអីដូចស្រុកបុទុមបូ ដូចស្រុកសិរិកាអី គឺមានការដោះស្រាយពីស្រុកផ្សេងៗដែលបានច្រើនយកមកចែកគ្នាដែរ។ ហើយបើហៅថាវាអត់បាយក៏វាមិនអត់អីទេ មានដំឡូងមានអីៗហ្នឹង មានពោតបង្កបង្កើនផលបាន។ អានេះតាមការជាក់ស្តែងដែលខ្ញុំនៅហ្នឹង។ រីឯសភាពការណ៍ដែលរាយការណ៍យ៉ាងម៉េចៗខ្ញុំដឹងមិនដល់ដែរព្រោះខ្ញុំនៅដាច់ហើយ។

[១១:១៩:២៩]

**សៈ** សំណួរពីរបីនាទីមុននេះលោកបានជម្រាបយើងខ្ញុំថា នួន ជា បានប្រាប់ថាឲ្យបង្កើនផលស្រូវពី ៣,៥តោន ក្នុងមួយហិកតា ទៅដល់ប្រាំពីរតោនក្នុងមួយហិកតា។ នៅក្នុងខេត្តព្រះវិហារថាតើអាចមានលទ្ធភាពបង្កបង្កើនផលស្រូវ ប្រាំពីរតោនក្នុងមួយហិកតា ឬក៏ប្រាំបីតោនក្នុងមួយហិកតាដែរឬទេ នៅតំបន់ព្រះវិហារនោះ?

**ឆ៖** តាមដែលខ្ញុំពិនិត្យមើល គឺរឿងប្រាំពីរតោនមួយហិកតាហ្នឹងគឺធ្វើពីរដង។ ទាល់តែកន្លែងនោះដែលមានទំនប់។ ហើយការធ្វើទំនប់នេះ ក៏វាមិនទាន់បានលទ្ធផលល្អល្អិតដែរ។ ដោយទំនប់អូរតាលកទំនប់អីនេះ ក៏មិនទាន់បានចេញលទ្ធផលដែរ។ ហើយរីឯស្រូវដែលមានធ្វើមួយហិកតាហ្នឹង ដែលល្អ ដូចនៅស្រុកគូលែន ដូចនៅស្រុកជ័យសែន ដូចនៅស្រុកឆែបនេះ គេបានបីតោនអី។ រីឯប្រាំពីរតោន

អី មានក្រោមទំនប់អី ដូចខ្ញុំធ្វើនៅទំនប់អី ក្រោមទំនប់អីពីរដងក្នុង១ឆ្នាំហ្នឹង បានស្រូវពូជល្អៗទៅគឺបាន ជិតដល់ទៅ វាមិនបានជាគ្រប់គ្រាន់អីទេ ក៏ប៉ុន្តែស្រែវាតិចតួច នៅព្រះវិហារដីភូមិសាស្ត្រខ្ពង់រាប មិនមានដីវាលល្វឹងល្វើយទូលំទូលាយដូចនៅបន្ទាយមានជ័យ ដូចនៅអាងត្រពាំងថ្មទេ។ ដូច្នេះគឺធ្វើជាលក្ខណៈប្រជាជន។ មួយអំពកពីរអំពក មួយកំប៉ុតពីរកំប៉ុតទៅ។ ដូច្នេះបានផលតែ១ឆ្នាំទៅគឺម្តងទេ។ ភាគតិចណាស់ដែលបានពីរដង ទាល់តែមានទំនប់។ ទំនប់ធំៗដូចទំនប់នៅអូរតាលកនេះ នៅខ្វាំងនេះក៏មិនទាន់បានប្រើប្រាស់ចាស់ទៅលើវាលស្រែណាទេ។ ដែលមិនដែលប្រើប្រាស់បាននេះ គឺទំនប់តូចៗ ដូចទំនប់ទម្លាប់អីៗនេះ ហើយនិងតាមស្រុកខ្លះ នោះគឺធ្វើបាន។ ដីដែលល្អហ្នឹងបានពីរដង បានប្រាំពីរតោន ដីដែលវាល្អដែរ មានជីវជាតិ មិនដាក់ប្រើជីអីប៉ុន្មានទេ ដីល្អ។ អានេះ ខ្ញុំសូមមានយោបល់ប៉ុណ្ណឹង។

[១១:២២:០៥]

**ស៖** នៅក្នុងរបាយការណ៍ដដែល ដែលខ្ញុំទើបតែឲ្យលោក អានឲ្យលោកស្តាប់អម្បាញ់មិញនេះ គឺថាថ្ងៃទី១០ សារទូរលេខថ្ងៃទី១០ មករា ឆ្នាំ៧៨ ផ្ញើជូនពីគណៈ -- ផ្ញើជូនទៅគណៈ៨៧០ គឺឯកសារ E3/918។ នៅក្នុងកថាខណ្ឌចុងក្រោយនៃរបាយការណ៍គឺបានលើកឡើងអំពីផែនការដែលត្រូវធ្វើឡើងនៅក្នុងតំបន់១០៣។ គាត់បានលើកឡើងថា គាត់តែងតាំងសមមិត្ត ប៊ុន ចាន់ ធ្វើជាជំនួយនៅតំបន់ ១០៣។ ហើយបន្ទាប់មកគាត់បានធ្វើរបាយការណ៍ជូនទៅទីក្រុងភ្នំពេញថា នៅពេលដែលគាត់ទៅតំបន់ ១០៣ – "ខ្ញុំនឹងផ្ញើជូនក្រពើទៅថែមទៀត។ សូមគណៈចាត់ចែងទទួលផង"។ ផ្អែកតាមពាក្យពេចន៍ដែលប្រើប្រាស់នៅក្នុងពេលនោះ តើលោកអាចជួយពន្យល់ដែរឬទេ តើនៅពេលដែលគេនិយាយថាជូន ផ្ញើជូនក្រពើទៅថែមទៀតនោះ ផ្ញើកូនក្រពើទៅថែមទៀតនោះ មានន័យយ៉ាងម៉េចដែរ?

**ឆ៖** បញ្ហាឯកសារនេះ ខ្ញុំអត់បានយល់ អត់បានដឹងរឿងកូនក្រពើ ឬកូនខ្លាអីទេ។ អានេះខ្ញុំអត់យល់។

[១១:២៣:៤៩]

**ស៖** ខ្ញុំសូមសួរសំណួរមួយចំនួនទៀតពាក់ព័ន្ធទៅនឹងឯកសារផ្សេងទៀត ឯកសារ E3/1077។ គឺថ្ងៃទី១០ ខែមេសា ឆ្នាំ៧៨, សារទូរលេខ ១០ មេសា ៧៨ មកពីលេខាភូមិភាគ ហើយបញ្ជូនទៅមន្ទីរ ៨៧០ ផ្ញើជូន បងនួន, បងវ៉ាន់, បងវន។ ផ្នែកដំបូងនៃរបាយការណ៍នេះលើកឡើងអំពីស្ថានភាពខ្មាំង។ ខ្ញុំសូមដកស្រង់សម្តី "មូលដ្ឋានរបស់ខ្មាំងគឺនៅភ្នំដងរែក ហើយយើងបានព្យាយាមធ្វើការពិនិត្យតំបន់

១០៣ ដែលមាន ហង្ស គ្រប់គ្រង។ ក្រោយពីយើងចាប់ខ្លួន ហង្ស និងពួករបស់វា ពួកអា អ៊ិន តាំ ត្រូវអស់បង្អែក"។ សំណួរដែលខ្ញុំចង់សួរលោកនោះ គឺតើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានដែរឬទេ អ្នកណាគេជា អ៊ិន តាំ?

**ឆ៖** តាមខ្ញុំយល់ អ៊ិន តាំ នោះ គឺពួកសេរីកាដែលនៅលើប្រាសាទព្រះវិហារ។ ក៏ប៉ុន្តែប្រាសាទព្រះវិហារហ្នឹង គឺរំដោះពីថ្ងៃទី២៧ ខែ៤ ឆ្នាំ១៩៧៥។ ដូច្នេះមិនមានជា អ៊ិន តាំ អីទេ ក្រោយ ៧៥មក។ នេះតាមដែលខ្ញុំយល់។ មានតែកម្លាំងដែលសេសសល់ ដែលហៅថា រំដោះហើយគេនៅតាមស្រុកតាមភូមិ អាហ្នឹងមាន ឲ្យទៅអង្គភាពអីៗនៅតាមភ្នំដងរែក។ អានេះដែលខ្ញុំមកនៅនេះដូចមិនទាន់មានទេ បើមុន៧៥ អាហ្នឹងឃើញមានធ្វើសកម្មភាពដែលមិនទាន់រំដោះនុំងមានធ្វើសកម្មភាព។ ខ្លះមកដល់ស្រុកគូលែនស្រុកអីហ្នឹង។

[១១:២៦:២០]

**ស៖** ឯកសារចុងក្រោយដែរខ្ញុំសូមសួរសាក្សីគឺឯកសារដែលខ្ញុំសូមបង្ហាញជូនសាក្សីថាតើគាត់ស្គាល់ឈ្មោះនៅក្នុងនោះដែរឬទេ? ជាពិសេសនៅត្រង់ក្របទំព័រ ឯកសារ E3/175 គឺឯកសារនេះមានពណ៌ធម្មជាតិឲ្យយើងមើល និងឯកសារ E3/3563 ឯកសារនេះស្រដៀងគ្នាតែប៉ុណ្ណោះ។ --

**លោក ខេល លីសាក់៖**

ខ្ញុំសូមអនុញ្ញាតពីអង្គជំនុំជម្រះ ហើយសួរថាសាក្សីថាតើសាក្សីអាចស្គាល់ឈ្មោះនៅលើក្រដាសនេះ ឯកសារនេះដែរឬទេ? សូមអនុញ្ញាតពីអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១១:២៧:៤១]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សីផ្នែកដែលខ្ញុំសូមឲ្យលោកមើលនេះ គឺឯកសារសរសេរដោយដៃមកពីលេខាសែ ចុះថ្ងៃ១៧ ខែមេសា ឆ្នាំ៧៨ ដែលមានការសរសេរដូចតទៅ "សូមគោរពគណៈ៨៧០ ជាទីស្នេហា ខ្ញុំសូមជូនឯកសារចម្លើយរបស់ឈ្មោះ សាន់ អ៊ាប ហៅ ខុន ពាណិជ្ជកម្ម១០៣ នៅភ្នំពេញ និង ស៊ើយ ហៅ ផង់ សន្តិសុខ១០៣, ដើម្បីគណៈពិនិត្យ ហើយនិងមើលឯកសារស្រាវជ្រាវខ្សែក្បត់បង្កប់ស៊ីរ្លូង

ផ្ទៃក្នុង។ នៅចំណារខាងឆ្វេងនោះបានដាក់ថា "តាមដាន"។ នេះគឺជាចម្លើយរបស់កម្មាភិបាលឈ្មោះ សាន់ អ៊ាប ហៅ ខុន ដែលជាពាណិជ្ជកម្ម១០៣ ប្រចាំនៅភ្នំពេញ។ តើលោកអាចជម្រាបយើងខ្ញុំបាន ដែរឬទេ លោកស្គាល់បុគ្គលរូបនេះដែរឬទេ សាន់ អ៊ាប?

**ឆ៖** ឈ្មោះដើមខ្ញុំអត់ស្គាល់ទេ។ ស្គាល់ឈ្មោះចុងឈ្មោះ ខុន ៗហ្នឹង នៅជាមួយ មិត្តពេញ ៗ។

**ស៖** តើ ខុន នេះធ្វើការនៅពាណិជ្ជកម្ម១០៣ ប្រចាំនៅភ្នំពេញ ឬក៏គាត់ធ្វើការនៅព្រះវិហារ?

**ឆ៖** កាលពីមុនគាត់នៅព្រះវិហារជាមួយខ្ញុំជាមួយអីហ្នឹង ដល់នៅនេះបន្ថែមគាត់មកជាមួយ មិត្ត ពេញ មកនៅភ្នំពេញ។

**ស៖** សំណួរចុងក្រោយលោក ព្រុំ ស៊ូ មុននឹងខ្ញុំប្រគល់វេទិកាទៅដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងឯកសារនេះលេខ៣៧ នៃបញ្ជីឈ្មោះនៅខាងចុងនៃចម្លើយសារភាព របស់ សាន់ អ៊ាប ដែលគេបញ្ជូនទៅមន្ទីរ៨៧០ នោះគឺដែលមានបញ្ជីរាយនាមរបស់កម្មាភិបាលមកពី តំបន់១០៣ ផ្នែកពាណិជ្ជកម្មនោះ តើលោកបានទទួលដំណឹងដោយថ្នាក់ដឹកនាំទេថា ខុន នោះឆ្លើយដាក់ លោកដែរឬទេ? ឬក៏អ្នក ឬក៏កម្មាភិបាលផ្សេងទៀតនៅ១០៣ ធ្លាប់ឆ្លើយដាក់លោកទេ? តើថ្នាក់លើ របស់លោកប្រាប់លោកបែបនោះដែរឬទេ?

[១១:៣០:៥៤]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ក្រោយពីចាប់ បងហង្ស ទៅគឺខ្ញុំទៅនៅព្រៃហើយ។ រីឯការដែលគេចុច ឈ្មោះអីៗមកដើម្បីអីនេះ គឺខ្ញុំអត់ដឹងទេ ក៏ប៉ុន្តែឈ្មោះនៅក្នុងនេះខ្ញុំស្គាល់ ឈ្មោះ រិត និងកូនខ្ញុំ ឈ្មោះ ហ្វា ហើយនិងឈ្មោះក្មេងៗផ្សេងទៀត ឈ្មោះ ឡឿន នេះស្គាល់។ ហ្នឹងប៉ុណ្ណឹង។

**លោក ខេល លីសាក់៖**

សំណួររបស់ខ្ញុំ គឺអស់ត្រឹមប៉ុណ្ណឹង លោកសាក្សី ព្រុំ ស៊ូ ហើយសូមអរគុណលោកប្រធាន ខ្ញុំមិន មានសំណួរអ្វីទៀតទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាង ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សម្រាប់រយៈពេល ២០នាទីដែលនៅសល់នេះ ខ្ញុំបាទ ហើយនិងកញ្ញាមេធាវី បេនី យេ នឹងសួរបន្តបាទ។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

[១១:៣២:១៧]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរលោក ព្រំ ស៊ូ, ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំចង់សុំផ្តោតជាពិសេសពាក់ព័ន្ធទៅនឹងស្ថានភាពរបស់ប្រជាជនដែលត្រូវបានជម្លៀស ហើយដែលបាន លោកបានជួបប្រទះនៅខេត្តកំពង់ធំ នៅស្ទឹងសែន។ តើលោកអាចបញ្ជាក់បានទេ តើមានកប៉ាល់ប៉ុន្មានដែលដឹកប្រជាជន ចេញពីភ្នំពេញតាមស្ទឹងសែនទៅទុកនៅកំពង់ធំនោះ សូមលោកជួយបញ្ជាក់ផង?

**លោក ព្រំ ស៊ូ៖**

**ឆ៖** ចំនួនកប៉ាល់ប៉ុន្មាន ខ្ញុំក្តាប់មិនបានដែរ ហើយដឹកជញ្ជូនប៉ុន្មានជើងនោះ ក្តាប់មិនបានដែរ ដឹងដល់កំពង់ធំហើយ គឺខ្ញុំរៀបចំចែកស្បៀង ចែកអីហើយ ឡើងឡានទៅព្រះវិហារ ខេត្តព្រះវិហារ មានឡាន មានត្រាក់ទ័រអី មធ្យោបាយប៉ុន្មានរបស់ពាណិជ្ជកម្មអី ដឹកជញ្ជូនទាំងអស់។ រីឯចំនួនអត់ដឹងដែរ។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់ថាមានប្រជាជនមកពីភ្នំពេញចំនួន៣.០០០នាក់ ហើយប្រហែលជា ៣.០០០នាក់ ហើយតើលោកអាចបញ្ជាក់បានទេក្នុងចំណោមប្រជាជនទាំងអស់នោះ ថាតើមានប្រជាជនប្រភេទណាខ្លះដែលនៅក្នុងនោះ? ចង់និយាយថា ជាចាស់ ឬក៏ជាកុមារ ហើយជាស្ត្រី? លោកអាចបញ្ជាក់បានទេ?

[១១:៣៣:៤៦]

**ឆ៖** បញ្ហាប្រជាជនដែលជម្លៀសទៅដល់ខេត្តកំពង់ធំ ដែលពួកយើងខ្ញុំទទួលនេះ គឺវាមានចាស់ក្មេងក្នុងគ្រួសារមួយ វាមានចាស់ វាមានមធ្យម មានក្មេង ធម្មតា ហើយអ្នកដែលសមាសភាពហ្នឹងក៏ចម្រុះដែរ មិនដឹងពីណាធ្វើអីខ្លះ ពីណាធ្វើអីខ្លះ ពីណារកស៊ីអីខ្លះ ចេះតែដឹកទៅ។

**ស៖** បាទ សូមអរគុណ។ តើ -- សំណួរបន្ទាប់របស់ខ្ញុំ ថាតើលោកអាចបញ្ជាក់បានទេពួកគាត់

មកដល់ -- ពេលដែលលោកទៅដល់ អញ្ជើញទៅដល់កំពង់ធំហ្នឹង តើពួកគាត់មកដល់ទាំងអស់គ្នានៅកន្លែងនោះរួចហើយជាស្រេច ឬក៏ពេលលោកទៅដល់ពួកគាត់មកបន្តិចម្ដងៗមកដល់ជួបជុំគ្នានៅទីនោះ?

**ផ៖** តាមដែលខ្ញុំដឹង គឺអាចមកច្រើនដងដែរ ហើយបន្តបន្ទាប់ ប៉ុន្តែមកជាដុំធំមិនជាច្រើនដងប៉ុន្មានទេ គឺថាមកដោះស្រាយៗទៅរហូតដល់អស់ទៅ ចប់។

**ស៖** ចុះពេល មុនពេលដែលលោកក្រុមរបស់លោកបានមកដល់កំពង់ធំ ផ្គត់ផ្គង់ដល់ពួកគាត់ តើពួកគាត់មានអ្វីបរិភោគគ្រប់គ្រាន់ដែរឬទេ មុនពេលដែលក្រុមរបស់លោកបានអញ្ជើញមកដល់ទីនោះ?

[១១:៣៥:៥០]

**ផ៖** ពេលដែលខ្ញុំមកទទួលនោះគឺ ជាស្បៀងអាហារមិនជាបរិបូណ៌អីទេ ក៏ប៉ុន្តែជាគ្រប់គ្រាន់បាទគ្រប់គ្រាន់ គឺដឹកស្បៀងមកពីណោះ ទៅវិញដឹកមនុស្សទៅ។ អាហ្នឹងគឺម្ហូបអីមិនជាមានអីច្រើនទេ អង្កាល់នោះដូចជា រកត្រីខាងអ្នកនេសាទកំពង់ធំអីបានមួយចំនួនដែរ ត្រីងៀតត្រីឆ្អើរ ហើយជាពិសេសគឺអំបិល ហើយនិងអង្ករ។

**ស៖** ខ្ញុំសូមទោស ដែលខ្ញុំធ្វើ -- សំណួរខ្ញុំប្រហែលជាមិនបានច្បាស់លាស់។ មុនដែលលោកបានដឹកស្បៀងអាហារមកដល់ បងប្អូនដែលជម្លៀសពីភ្នំពេញតាមកប៉ាល់មកនៅទីរួមខេត្តកំពង់ធំហ្នឹង ថាតើពួកគាត់ -- ពេលដែលគាត់កំពុងតែរង់ចាំមុនពេលក្រុមរបស់លោកមកដល់ហ្នឹង ថាតើគាត់មានចំណីអាហារបរិភោគគ្រប់គ្រាន់ដែរឬទេ?

**ផ៖** តាមខ្ញុំដឹង គឺមិនជាមានការខ្វះខាតអីទេ ព្រោះថាបើកស្បៀងហើយ មិនទាន់បាននៅក៏សម្រាក គឺថាអ្នកដែលអត់ទៅសម្រាក។ សរុបទៅមើលជាសភាពការណ៍ គឺជនដែលភៀសខ្លួនមកពីភ្នំពេញហៅថា ដូចហាក់ដូចជាធូរធារជាងប្រជាជននៅក្នុងខេត្តកំពង់ធំ។ អានេះតាមជាក់ស្ដែង ដែលខ្ញុំនៅនុំងណា។

[១១:៣៧:៤០]

**ស៖** តើលោកអាចដឹងទេ ប្រជាជនគាត់ធ្វើដំណើរតាមកប៉ាល់ពីភ្នំពេញមកដល់ទីរួមខេត្តកំពង់ធំហ្នឹងគាត់ត្រូវចំណាយពេលប៉ុន្មាន ដើម្បីមកដល់កន្លែងហ្នឹង? ហើយបន្តមកទៀត បន្ទាប់លោកដឹកជញ្ជូនពួកគាត់ពីទីរួមខេត្តកំពង់ធំទៅគោលដៅរបស់គាត់ នៅខេត្តព្រះវិហារហ្នឹង គាត់ត្រូវការចំណាយរយៈពេលប៉ុន្មានទៅដល់ទីនោះ?

**ផ៖** ពីភ្នំពេញទៅកំពង់ធំ ការធ្វើដំណើរដោយកប៉ាល់ក៏ដោយ កាណូតអីនេះខ្ញុំអត់ដឹងទេ។ ដឹងតែ

ទទួលពីស្ទឹងសែននេះ ពីផ្ទះសំណាក់ ពីផ្ទះអូតែលស្ទឹងសែនទៅនុំង គឺបើឡានអត់ខូចទេ គឺ១ថ្ងៃដល់ហើយ ទៅរវៀង។ បើទៅរវៀងទៀតបានចាត់ចែងតាមសហករណ៍តាមអីគេមកដឹក ដោយយករទេះយកអីមក ដឹកតទៅទៀតទៅ។ ហើយបើមានការខូចអី ត្រាក់ទ័រអី ១យប់អី គឺជួយដោះស្រាយ អាឡានដែលដឹក ទៅដល់ហើយមកទទួលវិញបាន។ ដូច្នេះអត់មានឧបសគ្គអីទេ ព្រោះអាផ្លូវហ្នឹង ផ្លូវលេខ១២ហ្នឹង កាល ដែលក្រោយ៧៥នៅល្អជាងបង្អស់ អត់មានទាន់គ្រលិកគ្រលុកអីទេ។ ហើយវាមាននេះខ្លះ នៅអាកន្លែង ព្រៃឫស្សីខាងជើងកំពង់ធំ ហើយនិងស្រែ*(ឮមិនច្បាស់)* វាមានគ្រលិកគ្រលុកខ្លះចាប់ពីសាលាវិស័យទៅ ភ្នំដែង ទៅរវៀងនោះអីហ្នឹងនៅល្អ ផ្លូវលេខ១២។

[១១:៣៩:៣៣]

**ស៖** បាទ សំណួរបន្ទាប់របស់ខ្ញុំ អ្នកដែលជាប្រជាជនដែលគេដឹកជញ្ជូនទៅរវៀងហ្នឹង ថាតើគេ គេមានចាត់ទុកថាពួកគាត់ជាជំពូកមនុស្សយ៉ាងដូចម្ដេចដែរទេនៅពេលនោះ?

**ឆ៖** ដោយឡែកនៅក្នុងតំបន់១០៣ ប្រជាជននៅក្នុងស្រុករវៀង ដូចជាមិនមានបែងចែកប្រជា ជនមកពីភ្នំពេញអីទេ គឺជួយគ្នាអស់លទ្ធភាព គឺសហករណ៍ខ្លះបន្ទុកវាល្មមនឹងប្រជាជនចាស់ ក៏ប៉ុន្តែ គ្នាចេះតែទ្រាំទៅ។ គឺតាមដែលខ្ញុំមើលទៅសភាពការណ៍គឺគោរពស្រលាញ់គ្នាណាស់ជាធម្មតា ដូចៗគ្នា ទាំងអស់ដែរ។ តែបញ្ហាដែលថាវាមានការឈឺស្កាត់អីហ្នឹងពេទ្យក៏មានអីក៏មានគឺវាអស់លទ្ធភាពហើយ មិនដឹងថាម៉េច មកឈឺទៅពេទ្យទៅមានការអីៗដោះស្រាយតាមសហករណ៍ទៅ ហើយសហករណ៍ ដោះស្រាយមិនទាន់ទេ មកដល់កន្លែងពាណិជ្ជកម្មទៅ។ ខ្លះក៏មកពាណិជ្ជកម្មផ្ទាល់ទៅ។ អានេះគឺមាន ការចែករំលែកគ្នាអីចឹង។ អត់មានចង្អៀតចង្អល់អីទេ។

**ស៖** បាទ សំណួរខ្ញុំចុងក្រោយពាក់ព័ន្ធនឹងប្រធានបទប្រជាជនដែលចេញពីភ្នំពេញនេះ គឺតើ លោកពិនិត្យឃើញយ៉ាងណាអំពីស្ថានភាពសុខភាព ឬក៏ស្ថានភាពរស់នៅរបស់ប្រជាជននៅពេលដែល លោកឃើញគាត់ដំបូងនៅទីរួមខេត្តកំពង់ធំ ប្រៀបធៀបពេលហ្នឹងទៅនឹងស្ថានភាពខុសភាពរបស់គាត់ ពេលដែលគាត់រស់នៅ ១ឆ្នាំ ២ឆ្នាំ នៅស្រុករវៀង ខេត្តព្រះវិហារ។ តើលោកអាចប្រៀបធៀបបានទេ តើវាមានការប្រែប្រួលយ៉ាងដូចម្ដេច? សុខភាពរបស់គាត់ល្អ គាត់រស់នៅសំបូរសប្បាយធូរធារដែរ ឬក៏ ស្ថានភាពរបស់គាត់មានការប្រែប្រួលយ៉ាងដូចម្ដេច?

[១១:៤១:៥៧]

**ឆ៖** តាមដែលខ្ញុំមើល តាមដែលខ្ញុំឃើញគឺសុខភាពរបស់ប្រជាជនដែលយកទៅគឺអ្នកដែលមិន

ប៉ះជំងឺគ្រុនចាញ់អី ឬក៏អីទេ អាហ្នឹងគឺដូចសុខភាពដូចប្រជាជនចាស់អ៊ីចឹងដែរ ទាំងការហូបចុកអីគឺគ្រប់គ្រាន់បរិបូរដែរ ដោយឡែកតែដូចខ្ញុំបានលើកខាងដើមហើយ គឺភូមិមួយដកពិសោធន៍ហើយ គឺនៅភូមិបោះប៉ី នៅឃុំស្រែធំ ហ្នឹងគឺយកទៅដាក់នៅដោយឡែកមួយក្រុមគ្នាគាត់ទៅ។ អាហ្នឹងឈឺច្រើនស្លាប់ច្រើន អាផ្លូវចុះពីបុសសៀមទៅ អាហ្នឹងប៉ុណ្ណឹងទេ ផុតពីនោះក៏ដូចជាមិនមានអីដែរ។ ការធ្វើការងារទៅ ដូចតែគ្នានឹងប្រជាជនចាស់នោះដែរ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំនៅសល់សំណួរចុងក្រោយមួយសំណួរទេ។ ហើយបន្ទាប់មកខ្ញុំនឹងសុំអនុញ្ញាតដើម្បីផ្ទេរជូនវេទិកាទៅសហការីរបស់ខ្ញុំ។ លោកបានបញ្ជាក់ថា តំបន់១០៣ ឬក៏តំបន់១០៦ ជាតំបន់ស្វយ័ត ថាតើតំបន់ស្វយ័តហ្នឹងវាមានទំនាក់ទំនងយ៉ាងម៉េចខ្លះជាមួយនឹងមជ្ឈិម បើប្រៀបធៀបជាមួយនឹងតំបន់ផ្សេងៗទៀតនៅក្នុងភូមិភាគផ្សេងៗទៀត។ តើមានទំនាក់ទំនងនឹងមជ្ឈិមយ៉ាងម៉េច? ហេតុអ្វីបានជាមានឈ្មោះស្វយ័ត?

[១១:៤៣:២៧]

**ឆ៖** តាមខ្ញុំដឹងតំបន់ស្វយ័តនេះគឺមិនជាប់ភូមិភាគនេះគឺតំបន់ដែលហៅថា វានៅជនបទដែលរំដោះមុន ដូចរតនគិរី ដូចនៅស្ទឹងត្រែង នៅព្រះវិហារអីហ្នឹង គឺ១០៤ មក ១០៣មក ខាងរតនគិរីមណ្ឌលគិរីនៅតំបន់ប៉ុន្មានទេ ស្វយ័តហ្នឹងគឺឡើងទៅមជ្ឈិមផ្ទាល់ដោយមិនមានភូមិភាគនិងមជ្ឈិមក្តាប់ផ្ទាល់។ រីឯភូមិភាគហ្នឹងគឺដូចភូមិភាគពាយ័ព្យ ភូមិភាគបស្ចិមអីហ្នឹង គឺពីតំបន់ត្រូវឡើងទៅភូមិភាគសិន។ បានភូមិភាគឡើងមកមជ្ឈិមដូចក្រោយដែលចាត់តាំងភូមិភាគឧត្តរហើយ គឺតំបន់មិនមានលទ្ធភាពអីទាក់ទងមកមជ្ឈិមទេ មានតែភូមិភាគទេ ដែលទាក់ទងមកមជ្ឈិម។

**ស៖** បាទ សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។ ខ្ញុំសូមផ្ទេរវេទិកាជូនសហការីរបស់ខ្ញុំ។ សូមអរគុណលោកប្រធាន។

**លោកស្រី បេនី យេ៖**

សូមគោរពតុលាការ លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ ហើយនិងសាក្សី ព្រំស្ទ៊ូ។ ខ្ញុំឈ្មោះ បេនី យេ ជាសហមេធាវី -- មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំសូមសួរសំណួរតពីលោកពេជ អង្គ។

**សួរដោយលោកស្រី បេនី យេ៖**

**ស៖** លោកបាននិយាយថា ប្រជាជនដែលមកពីភ្នំពេញហ្នឹងគឺត្រូវបានលំបាកនៅពេលដែលគេ

ទៅដល់ភូមិថ្មីរបស់ពួកគេនោះ ដែលគេត្រូវធ្វើការដាំដុះអ្វីផ្សេងៗ។ សូមលោកជម្រាបតុលាការថាតើ ថាហេតុអ្វីបានជាគេបញ្ជូនតែប្រជាជនថ្មីទៅភូមិទាំងអស់នេះ? ហេតុអីក៏គេមិនបញ្ជូនអ្នកមូលដ្ឋានទៅកន្លែងនោះផង?

**លោក ព្រំ ស៊ូ៖**

**ឆ៖** ដូចខ្ញុំបានលើកឡើងខាងដើមអ៊ីចឹង គឺមួយចំនួនៗភាគច្រើនទូទៅ៨-៩ភាគរយគឺនៅក្នុងភូមិចាស់។ ប៉ុន្តែដល់ភូមិមួយនោះ ដែលខ្ញុំថាភូមិបោះប៉ុនោះ ក្នុងឃុំស្រែធំនោះ គឺដកពិសោធទៅយកប្រជាជនថ្មីទៅដាក់នៅមួយក្រុមតែគ្នាគាត់ទៅ មានការឈឺច្រើន ហើយស្បៀងអាហារក៏ផ្គត់ផ្គង់ទៅវាមិនបានគ្រប់គ្រាន់ ដោយការប្រមែប្រមូលហូបនៅសហករណ៍តែមួយជាមួយគ្នាទៅអត់បញ្ហាទេ។ អានេះជាបញ្ហា ជាការដកពិសោធមួយ។ ដូច្នេះថ្ងៃក្រោយទៅក៏ខាងសហករណ៍អីនេះគេដកពិសោធទៅ យកទៅដាក់នៅជាមួយប្រជាជនចាស់វិញ ដើម្បីកុំឲ្យមានបញ្ហាហ្នឹង។ អាហ្នឹងគេមានប្រជុំដកពិសោធដែរ។

[១១:៤៦:៣៩]

**ស៖** សូមអរគុណ។ លោកក៏បាននិយាយផងដែរថា អ្នកដែលមកពីភ្នំពេញនោះ ត្រូវតែចាកចេញពីក្នុងភ្នំពេញដោយសារថាបញ្ហាសន្តិសុខ។ ខ្ញុំចង់សួរលោកតើ ថាតើលោកបានឃើញអ្នកដែលមកភ្នំពេញអាចត្រឡប់មកពីតំបន់១០៣មកភ្នំពេញដែរឬទេ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺមិនមានប្រជាជនដែលជម្លៀសទៅនៅភ្នំពេញ -- អ៊ំ! ជម្លៀសពីភ្នំពេញទៅនៅព្រះវិហារហើយ ត្រឡប់មកវិញទេ។ ទើបតែក្រោយ៧៩ហើយ បានមានត្រឡប់មកមួយចំនួនធំភាគច្រើនចង់១០០ភាគរយ។ តែមួយចំនួនធំនោះ គឺនៅនុ៎ង មានទឹកមានដីមានការងារអីហ្នឹង នៅៗហ្នឹងទៅ។ ខ្ញុំសួរថាម៉េចក៏អត់ទៅភ្នំពេញវិញ? អ្ហែ! ទៅម៉េច! មានដីមានផ្ទះមានអីៗទៅហើយ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំមានសំណួរចុងក្រោយមួយនិយាយអំពីនិស្សិតខ្មែរដែលមកពីបរទេស ហើយដែលគេបញ្ជូនទៅតំបន់១០៣ ពីភ្នំពេញទៅ។ ខ្ញុំចង់ដឹងថាលោកដឹងទេ ហេតុអីបានជាគេបញ្ជូនពួកនិស្សិតទាំងអស់នេះពីភ្នំពេញទៅតំបន់១០៣?

[១១:៤៨:១៦]

**ឆ៖** បញ្ហាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យគឺ អនុធន និស្សិតអី គឺត្រូវចាំបាច់ទៅរៀនសូត្រពីកសិករក្រីនៅតាមជនបទ។ ដូច្នេះឲ្យទៅរៀនសូត្រ ធ្វើស្រែ ធ្វើចម្ការអីៗ។ ហើយក្រោយ៧៥ ដែល

រំដោះហើយនេះ គឺបានបញ្ជូនត្រឡប់មកភ្នំពេញវិញ មួយចំនួនច្រើនដែរ។

**លោកស្រី បេនី យេះ**

សូមអរគុណលោកសាក្សី ព្រំ ស៊ូ។ ហើយខ្ញុំមិនមានសំណួរទេ សូមឲ្យលោកធ្វើដំណើរដោយសុវត្ថិភាពទៅផ្ទះវិញ។ សូមអរគុណលោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី។ ហើយកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃនេះគឺផ្អាកត្រឹមនេះសិន ហើយសវនាការស្តាប់សក្ខីកម្មរបស់លោកៗ ព្រំ ស៊ូ លើកទៅបន្តធ្វើនៅព្រឹកថ្ងៃស្អែកទៀត គឺថ្ងៃពុធ ទី២២ ខែឧសភា ឆ្នាំ២០១៣ ហើយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ បាទ សូមភាគី និងសាធារណជនជ្រាប។

[១១:៤៩:៣៧]

លោក ព្រំ ស៊ូ ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចាប់នៅឡើយទេ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មរបស់លោកនៅព្រឹកថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះកោះហៅលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនសាក្សី ព្រំ ស៊ូ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ ហើយនិងឲ្យខ្លួនគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនថា នៅរសៀលនេះអង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-277 ពីប្រទេសបារាំងតាមរយៈមធ្យោបាយសោតទស្សន៍ដែលនឹងចាប់ផ្តើមពីម៉ោងមួយនិងសាមសិបនាទី ហើយសវនាការអាចនឹងប្រព្រឹត្តទៅរហូតប្រាំល្ងាច។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ទៅសម្រាកនៅបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣០នាទី)*

[១៣:៣០:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅរសៀលនេះដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនរួចហើយ កាលពីមុនពេលបាយថ្ងៃត្រង់ថាអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-277 ពីប្រទេសបារាំងតាមរយៈប្រព័ន្ធសោតទស្សន៍។

លោក ដាវ អានសាន តើការរៀបចំដំណើរការប្រព័ន្ធបច្ចេកទេសសោតទស្សន៍ហ្នឹងបានរៀបរយហើយឬនៅ?

**ក្រឡាបញ្ជី៖**

សូមគោរពជម្រាបលោកប្រធាន ខាងបច្ចេកទេសបានរាយការណ៍មកថា បានរៀបចំរួចរាល់អស់ហើយ រួចហើយ។ ឯចំណែក -- ដោយឡែកសាក្សីក៏បានរង់ចាំរួចជាស្រេចដែរលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ សូមជម្រាបសួរលោកសាក្សី។

**លោក ហ្វីលីព ហ្ស៊ីល្យាន-ហ្គោប្រៃ្វស៖**

**ឆ៖** ជម្រាបសួរលោកប្រធាន។

**ស៖** បាទ អរគុណលោកសាក្សី។ តើលោកអាចជម្រាបអំពីឈ្មោះ នាមត្រកូល និងនាមខ្លួនរបស់លោកដល់អង្គសវនាការបានដែរឬទេ?

[១៣:៣២:៣៧]

**ឆ៖** បាទ លោកប្រធាន ខ្ញុំឈ្មោះ ហ្វីលីព ហ្ស៊ូល្យាន-ហ្គោហ្វ្រែស (*Phillippe JULLIAN-GAUFRES*)។ ខ្ញុំកើតនៅថ្ងៃទី២៤ កុម្ភៈ ឆ្នាំ១៩៣០ នៅប្រទេសបារាំង។

**ស៖** បាទ អរគុណលោក ហ្វីលីព ហ្គោហ្វ្រ។ ក្នុងនាមលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះនេះ អង្គជំនុំជម្រះតម្រូវឱ្យលោកធ្វើសម្បថតាមជំនឿសាសនារបស់លោក តើលោកយល់ព្រមដែរឬទេ?

**ឆ៖** បាទ ខ្ញុំយល់ព្រមក្នុងការធ្វើសម្បថលោកប្រធាន។

**ស៖** បាទ អរគុណ។ ហើយក្រឡាបញ្ជីសវនាការ កញ្ញា មីរីអ៊ាម ម៉ាហ្វេសាន់ទិ សូមណែនាំលោកសាក្សី ហ្វីលីព ហ្គោហ្វ្រ ឱ្យធ្វើសម្បថតាមជំនឿសាសនារបស់គាត់។

**ក្រឡាបញ្ជី៖**

លោកសាក្សី សូមលោកថាតាមខ្ញុំ។

**លោក ហ្វីលីព ហ្ស៊ូល្យាន-ហ្គោហ្វ្រែស៖**

បាទ ខ្ញុំនឹងថាតាមលោកស្រី។

**ក្រឡាបញ្ជី៖**

សូមប្រកាសជាឱឡារិកថា ខ្ញុំនឹងនិយាយការពិត--

**លោក ហ្វីលីព ហ្ស៊ូល្យាន-ហ្គោហ្វ្រែស៖**

ខ្ញុំសូមប្រកាសថា ជាឱឡារិកថា ខ្ញុំនិយាយតែការពិត។

**ក្រឡាបញ្ជី៖**

--និងគ្មានអ្វីក្រៅតែពីការពិត។

**លោក ហ្វីលីព ហ្ស៊ូល្យាន-ហ្គោហ្វ្រែស៖**

បាទ គឺថាខ្ញុំនឹងនិយាយតែពីការពិត គ្មានអ្វីក្រៅតែពីការពិត។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។

[១៣:៣៤:៣០]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ហ្វីលីព ហ្កោប្រូ តាមរបាយការណ៍របស់ក្រឡាបញ្ជីអម្បាញ់មិញ កាលពីព្រឹកមិញថា តាមសមត្ថភាពដែលលោកអាចដឹងលោកមិនមានចំណងញាតិលោកហិត ឬញាតិពន្ធជាមួយនឹងភាគីដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជា ជាមួយនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន តើពិតមែនដែរឬទេ?

**លោក ហ្វីលីព ហ្សីល្យាន-ហ្កោប្រែស៖**

**ឆ៖** បាទលោកប្រធាន គឺពិតណាស់។

**ស៖** បាទអរគុណ។ ហើយជាបន្តនេះអង្គជំនុំជម្រះសូមជម្រាបអំពីសិទ្ធិ និងករណីកិច្ចរបស់សាក្សី។ បាទ ក្នុងនាមជាសាក្សី លោក ហ្វីលីព ហ្កោប្រូ ក្នុងកិច្ចដំណើរការសវនាការនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅសំណួរ ឬក៏សុំឱ្យធ្វើអំណះអំណាងណាមួយ ឬច្រើនដែលដាក់ពិរុណភាពលើខ្លួនឯង។ ហើយចំណែកឯករណីយកិច្ចវិញ គឺក្នុងនាមលោកជាសាក្សីត្រូវតែផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ ហើយលោកជាសាក្សីត្រូវតែឆ្លើយតែការណាដែលពិតដែលខ្លួនបានឃើញ បានដឹង បានឮ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬការធ្វើសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ តើលោកយល់ដែរឬទេ?

[១៣:៣៦:១១]

**ឆ៖** បាទលោកប្រធាន ខ្ញុំយល់ច្បាស់ណាស់។

**ស៖** បាទអរគុណ។ ហើយក្នុងអំឡុងពេលកន្លងមកនេះ តើលោកមានដែលធ្វើការផ្តល់បទសម្ភាសន៍ចំពោះការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ?

**ឆ៖** បាទ លោកប្រធាន ខ្ញុំមិនដែលត្រូវបានខាងណាសម្ភាសនោះទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយដោយសារសាក្សីនេះជា តាមសំណើរសុំរបស់មេធាវីការពារក្តីលោក ខៀវ សំផន ដូច្នេះអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បី

ឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ ហើយក្រុមមេធាវីការពារក្តី ខៀវ សំផន មានរយៈពេល១ម៉ោង ១៥នាទីក្នុងការសួរសាក្សីរូបនេះ។ ហើយតំណាងសហព្រះរាជអាជ្ញា រួមទាំងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏មានរយៈពេល១ម៉ោង១៥នាទីដូចគ្នាដែរ។ បាទ សូមអញ្ជើញ!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** ជម្រាបសួរលោក ហ្វ៊្វល្យាន ខ្ញុំឈ្មោះ អាកទួរ វែកគែន។ ខ្ញុំជាមេធាវីការពារក្តីលោក ខៀវ សំផន។ ដើម្បីចាប់ផ្តើម ខ្ញុំសូមឱ្យលោកបញ្ជាក់ជូនអង្គជំនុំជម្រះអំពីខ្សែការសិក្សា និងមុខរបររបស់លោក? បាទ សូមអញ្ជើញលោកនិយាយឲ្យបានត្រួសៗអំពីប្រវត្តិសិក្សា និងការងាររបស់លោក?

**លោក ហ្វីលីព ហ្វ៊្វល្យាន-ហ្គោប្រែហ្វស៖**

**ឆ៖** ខ្ញុំសិក្សានៅសាលាជាន់ខ្ពស់ពាណិជ្ជកម្មនៅទីក្រុងប៉ារីស។ ខ្ញុំទទួលបានសញ្ញាបត្រនៅឆ្នាំ១៩៥០។ បន្ទាប់មកខ្ញុំធ្វើការនៅប្រទេសបារាំងនៅធនាគារមួយ។ បន្ទាប់មកខ្ញុំបានស្នាក់នៅចុងបូព៌ានៅឆ្នាំ៥៥-៥៦។ ក្រោយមកទៀត ខ្ញុំត្រឡប់មកប្រទេសបារាំងវិញ ហើយខ្ញុំបានស្គាល់និស្សិតមួយចំនួនជាពិសេសមកពីកម្ពុជានៅពេលដែលខ្ញុំសិក្សាខាងផ្នែកពាណិជ្ជកម្ម។ បន្ទាប់មកទៀត ខ្ញុំចង់ធ្វើការនៅប្រទេសកម្ពុជា។ ដូច្នេះពេលដែលខ្ញុំត្រឡប់ទៅប្រទេសបារាំងវិញនោះ ធ្វើការផង ខ្ញុំរៀនភាសាខ្មែរផងនៅសាលាភាសាខាងភាសាបូព៌ា។ នេះជាប្រវត្តិនៃការសិក្សារបស់ខ្ញុំ។

[១៣:៣៩:០៣]

ហើយនៅសាលាខ្មែរនោះ គឺថាខ្ញុំបានទទួលសញ្ញាប័ត្រនៅឆ្នាំ១៩៦០។ បន្ទាប់ពីខ្ញុំទទួលបានសញ្ញាបត្រពីសាលាបូព៌ាប្រទេសនោះ ខ្ញុំបានធ្វើការនៅក្នុងក្រុមហ៊ុនបារាំងមួយ។ ហើយខ្ញុំចង់ធ្វើការនៅប្រទេសកម្ពុជា។ ជាចុងក្រោយខ្ញុំបានរកការងារនៅក្រុមហ៊ុនមួយឈ្មោះ អ៊ែលីគីដ។ ដូច្នោះនៅក្នុងឆ្នាំ៦១ ខ្ញុំមកកម្ពុជា ហើយខ្ញុំបានធ្វើជាប្រធានផ្នែកឧស្សាហកម្មនៃក្រុមហ៊ុននោះ។ ខ្ញុំធ្វើការនៅថៃឡង់ដ៍ ម៉ាឡេស៊ី ហើយបន្ទាប់មកខ្ញុំត្រឡប់ទៅបារាំងវិញ។ ខ្ញុំបន្តការងារនៅក្នុងក្រុមហ៊ុន អ៊ែលីគីដ។ ក្រោយមក ខ្ញុំជានាយកផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ នៅពេលដែលខ្ញុំចូលនិវិត្តន៍ គឺប្រហែលជាង២០ឆ្នាំមក

ហើយ ខ្ញុំធ្វើការឲ្យអង្គការមួយដែលទទួលបន្ទុកខាងផ្នែកជំនួយបច្ចេកទេសទៅដល់ប្រទេសកំពុងអភិវឌ្ឍ។ ហើយនៅសម័យនោះហើយ នៅក្នុងអង្គការនោះហើយ ដែលខ្ញុំត្រូវទទួលខុសត្រូវ មានទំនួលខុសត្រូវជាមួយនឹងបស្ចិមបូព៌ា -- នៅចុងបូព៌ា គឺនៅពេលដែលខ្ញុំនៅវិទ្យាល័យនោះ តាមរយៈការអានទៅ ខ្ញុំបានយល់អំពីវប្បធម៌ អរិយធម៌របស់ចុងបូព៌ា ហើយដែលខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ដូច្នេះហើយ ខ្ញុំបានព្យាយាមសិក្សាស្វែងយល់អំពីវប្បធម៌ យើងឃើញថាគុណតម្លៃក៏មានលក្ខណៈខុសគ្នា។ ដូច្នេះ កាលនោះពេល គឺថាអាមេរិកគេចាត់ទុកថាជាគំរូ ក៏ប៉ុន្តែខ្ញុំវិញខ្ញុំគិតថា អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺថាយើងរកអ្វីដែលផ្សេងគ្នាពីវប្បធម៌ និងពីអរិយធម៌របស់យើង។ គឺខ្ញុំចាប់អារម្មណ៍ទៅលើអរិយធម៌របស់ចុងបូព៌ា។

[១៣:៤១:២២]

**ស៖** សូមអរគុណលោក។ លោកបានឆ្លើយថាលោកស្នាក់នៅកម្ពុជាដំបូងនោះគឺ នៅក្នុងឆ្នាំ ៥៥, ៥៦ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេថា ពេលណាដែរបានជាលោកមកស្នាក់នៅកម្ពុជានុំង?

**ឆ៖** ខ្ញុំបំពេញកាតព្វកិច្ចយោធានៅក្នុងកងទ័ពជើងទឹកបារាំង។ ដូច្នេះខ្ញុំបានចំណាយពេល២ឆ្នាំនៅអឺរ៉ុប ហើយ១ឆ្នាំនៅចុងបូព៌ា គឺឆ្នាំ៥៥, ៥៦។ ក្រោយពីកិច្ចព្រមព្រៀងក្រុងហ្សឺណែវ គេបានបញ្ជូនខ្ញុំឲ្យទៅដោះស្រាយបញ្ហាមួយចំនួននៅចុងបូព៌ា។ ខ្ញុំនៅសាយហ្គន នៅវៀតណាម ខ្ញុំបានបំពេញបេសកកម្មមួយចំនួននៅប្រទេសកម្ពុជា នៅហុងកុង និងនៅហ្វីលីពីន។ ដូច្នេះខ្ញុំស្នាក់នៅតាមបែបយោធាជាអ្នកទេសចរណ៍ផងដែរនៅប្រទេសកម្ពុជានោះ។

**ស៖** សូមអរគុណលោក។ លោកបានឆ្លើយថា ក្រោយមកលោកត្រឡប់មកកម្ពុជាវិញក្នុងក្របខ័ណ្ឌនៃអាជីពរបស់លោក គឺលោកធ្វើការនៅក្រុមហ៊ុន អ៊ែលីគីដ។ តើលោកអាចពន្យល់ឲ្យច្បាស់អំពីវិស័យសកម្មភាពនៃក្រុមហ៊ុននេះដែរឬទេ? បានន័យថាក្រុមហ៊ុននេះធ្វើអ្វីដែរនៅប្រទេសកម្ពុជា?

[១៣:៤២:៥៦]

**ឆ៖** ក្រុមហ៊ុន អ៊ែលីគីដ នេះគឺជាក្រុមហ៊ុនឧស្សាហកម្មមួយដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩០២។ ដូច្នេះវាមានរាប់ឆ្នាំមកហើយ សកម្មភាពចម្បងនោះគឺការផលិតឧស្ម័នឧស្សាហកម្ម និងវេជ្ជសាស្ត្រ ដូចជាអុកស៊ីហ្សែន, អ៊ីដ្រូហ្សែន, អាសូត...។ល។ ហើយនិងក៏មានការផលិតសម្ភារៈសម្រាប់ប្រើប្រាស់ឧស្ម័នទាំងអស់នេះ។ ដូច្នេះ អ៊ែលីគីដនេះ គឺជាក្រុមហ៊ុនបារាំងអន្តរ -- ទី១ នៅក្នុងពិភពលោកបើផ្អែកទៅលើសកម្មភាពរបស់ខ្លួន។ នៅប្រទេសកម្ពុជា គឺមានផ្នែកផលិតកម្មមួយសម្រាប់

ផលិតអុកស៊ីហ្សែន, មានផ្នែកមួយទៀតសម្រាប់ផលិតអាសេទីឡែន និងមានផ្នែកមួយទៀតសម្រាប់ផលិតឧស្ម័នកាបូនិច។ ហើយខ្ញុំធ្វើការនៅខាងផ្នែកគ្រប់គ្រងឧស្ម័នសម្រាប់ផ្នែកវេជ្ជសាស្ត្រ ឧទាហរណ៍ដូចខាងអាម៉ូញាក់ជាដើម សម្រាប់ការដាំកៅស៊ូជាដើម។

[១៣:៤៤:០៦]

**ស៖** ក្នុងក្របខ័ណ្ឌនៃការងាររបស់លោក នៅក្នុងក្រុមហ៊ុនអ៊ែលីគីដ នៅប្រទេសកម្ពុជា តើលោកនៅតែប្រទេសកម្ពុជាទេ ឬក៏យ៉ាងណា? ហើយបើសិនជានៅប្រទេសកម្ពុជានោះ នៅក្នុងពេលណាដែរ?

**ឆ៖** នៅពេលដែលខ្ញុំដាក់បេក្ខភាពរបស់ខ្ញុំនៅក្រុមហ៊ុននោះ ក្រោយពីទទួលបានសញ្ញាបត្រខាងភាសាបូព៌ាប្រទេសនោះ ខ្ញុំបានបញ្ជាក់ថាខ្ញុំចង់ធ្វើការនៅប្រទេសកម្ពុជា ហើយនៅពេលនោះហើយក្រុមហ៊ុននោះកំពុងតែអភិវឌ្ឍសកម្មភាពរបស់ខ្លួននៅប្រទេសកម្ពុជា ដោយបង្កើតរោងចក្រថ្មីមួយហើយនិងបង្កើតក្រុមហ៊ុនមួយ ដែលគេថាក្រុមហ៊ុនខ្មែរអុកស៊ីហ្សែន និងអាសេទីឡែន។ ហើយដើមទុននោះត្រូវបានកាន់កាប់៤៩ភាគរយ ដោយក្រុមហ៊ុនអ៊ែលីគីដ, ២៥ភាគរយដោយរដ្ឋាភិបាលកម្ពុជាហើយនិង២៦ភាគរយ ត្រូវបានកាន់កាប់ដោយបុគ្គលឯកជនកម្ពុជា។ ខ្ញុំជាអគ្គនាយកប្រធានរបស់ក្រុមហ៊ុននោះត្រូវ បានចាត់តាំងដោយរដ្ឋាភិបាលកម្ពុជា។ ដូច្នេះលោក ស៊ុន វ៉ាន់សៃ ជាប្រធានដែលគាត់បានរៀននៅប្រទេសបារាំង។

[១៣:៤៥:៣៣]

**ស៖** លោក ហ្ស៊ីល្យាង ខ្ញុំសូមកាត់ចម្លើយរបស់លោកពីព្រោះថាខ្ញុំអត់មានពេលវេលាច្រើននោះទេ លោករៀបរាប់លម្អិតពេកហើយ។ ដូច្នេះវាមិនសូវមានប្រយោជន៍ទេ បើលោកលម្អិតពេកនោះ សូមឲ្យលោកបញ្ឈប់ត្រឹមនេះសិន។ ក៏ប៉ុន្តែសូមឲ្យលោករៀបរាប់អំពីរយៈពេលដែលលោកបំពេញការងារនៅប្រទេសកម្ពុជាឲ្យក្រុមហ៊ុន អ៊ែលីគីដ។

**ឆ៖** ខ្ញុំនៅប្រទេសកម្ពុជាចន្លោះឆ្នាំ៦១ ដល់ឆ្នាំ៦៦ ហើយនៅឆ្នាំ៦៧ នេះក៏ខ្ញុំធ្វើបន្តិចដែរ។ បន្ទាប់មកខ្ញុំត្រឡប់មកវិញម្តងទៀត គឺថាឆ្នាំ៧៤ ប្រហែលជា១ខែទេ មកបំពេញបេសកកម្ម។

**ស៖** តើលោកអាចជម្រាបបានទេ ថា រហូតមកដល់ថ្ងៃនេះលោកនៅតែមានសកម្មភាពពាក់ព័ន្ធទៅនឹងអាស៊ី ជាពិសេសពាក់ព័ន្ធនឹងប្រទេសកម្ពុជា។ លោកបាននិយាយអំពីអង្គការអម្បាញ់មិញនេះដែលមាន រៀបរាប់អំពីសកម្មភាពអង្គការជាដើមនោះ។ សូមលោករៀបរាប់ឲ្យបានលម្អិតបន្តិច?

**ឆ៖** ទំនាក់ទំនងជាសំខាន់ជាមួយកម្ពុជានេះ គឺថានៅពេលដែលខ្ញុំនៅកម្ពុជា ខ្ញុំបានរៀបការជាមួយប្រពន្ធដែលជាជនជាតិខ្មែរដូច្នេះយើងមានកូនបួននាក់។ ប្រពន្ធខ្ញុំហើយនិងខ្ញុំបានមកធ្វើដំណើរមកប្រទេសកម្ពុជាកាលពីប៉ុន្មានឆ្នាំមុននេះ។ អង្គការដែលខ្ញុំធ្វើការឲ្យនោះ បានតម្រង់ទិសឲ្យខ្ញុំធ្វើការពាក់ព័ន្ធទៅនឹងទំនាក់ទំនងជាមួយចិនពីព្រោះថា ខ្ញុំធ្លាប់ធ្វើការជាមួយចិនកាលពីនៅក្រុមហ៊ុន អ៊ែលីគីដ ដូច្នេះហើយការងាររបស់ខ្ញុំហ្នឹងគឺតម្រង់ទិសជាសំខាន់ទៅទំនាក់ទំនងជាមួយប្រទេសចិន។ ក៏ប៉ុន្តែតាមរយៈប្រពន្ធរបស់ខ្ញុំនោះ ខ្ញុំមានទំនាក់ទំនងជាច្រើនជាមួយនឹងប្រជាជនកម្ពុជាដែលរស់នៅប្រទេសបារាំង ឬក៏ទៅដើរលេងនៅស្រុកបារាំង។

[១៣:៤៧:៣៥]

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីដើមកំណើតនៃការចាប់អារម្មណ៍របស់លោកទៅលើប្រទេសកម្ពុជា។ សូមឲ្យលោកពន្យល់ជូនអង្គជំនុំជម្រះអំពីរបៀបដែលលោកបង្កើនការយល់ដឹងរបស់ខ្លួនអំពីកម្ពុជានៅពេលដែលលោករៀននៅប្រទេសបារាំង។ លោកបានបញ្ជាក់ហើយថាលោក រៀននៅសាលាខ្មែរមួយគឺថាសាលាបូព៌ាប្រទេស។

**ឆ៖** បាទ ខ្ញុំសូមត្រឡប់មកក្រោយបន្តិច។ គឺថាខ្ញុំរៀននៅសាលាជាន់ខ្ពស់ពាណិជ្ជកម្ម ព្រោះថានៅទីនោះហើយខ្ញុំបានជួបជនជាតិកម្ពុជាមួយចំនួននោះ។ ហើយខ្ញុំកាលនោះគឺថានៅក្នុងជំនាន់ខ្ញុំមានជនជាតិកម្ពុជា -- មាននិស្សិតកម្ពុជាពីរនាក់។ ដូច្នេះខ្ញុំសូមនិយាយឲ្យលឿនបន្តិច។ បន្ទាប់ពីខ្ញុំស្នាក់នៅកម្ពុជានៅឆ្នាំ៥៥ នោះពេលនោះហើយខ្ញុំចង់ត្រឡប់មកធ្វើការវិញ។ ដូច្នេះ ខ្ញុំបានទៅរៀនភាសាខ្មែរនៅសាលានៅបារាំងហើយកាលនោះរៀនអំពីភាសា ហើយនិងខាងអក្សរសាស្ត្រ។ ដូច្នេះហើយខ្ញុំចង់សន្ទនាគ្នាជាមួយនិស្សិតខ្មែរដើម្បីអាចបង្កើនភាសារបស់ខ្ញុំនៅប៉ារីស។ ដូច្នេះខ្ញុំក៏បានទៅទាក់ទងជាមួយនឹងសមាគមនិស្សិតខ្មែរដែលពេលនោះហើយដែលលោក ខៀវ សំផន នោះជាប្រធានសមាគម។ ដូច្នេះខ្ញុំសូមឲ្យគាត់ធ្វើម៉េចឲ្យខ្ញុំទាក់ទងជាមួយនិស្សិតខ្មែរម្នាក់ ពីរនាក់ដែលរស់នៅប្រទេសបារាំងនៅប៉ារីសហ្នឹងដើម្បីឲ្យខ្ញុំអាចជជែកពិភាក្សាគ្នាទៅដើម្បីនឹងបង្កើនភាសាខ្មែររបស់ខ្ញុំ ដើម្បីឲ្យខ្ញុំអាចអនុវត្តការនិយាយភាសា ហើយអាចធ្វើឲ្យពួកគាត់ហ្នឹងក៏អាចបង្កើនចំណេះដឹងខាងភាសាបារាំងដែរ។

**ស៖** ទំនាក់ទំនងជាមួយលោក ខៀវ សំផន នោះគឺនៅប្រទេសបារាំងនៅប៉ារីសនោះនៅឆ្នាំណាដែរ?

[១៣:៤៩:៤៤]

**ឆ៖** ការជួបគ្នាហ្នឹងគឺនៅបុរីសកលវិទ្យាល័យគឺនៅឆ្នាំ ៥៧។ គឺឆ្នាំនោះហើយដែលខ្ញុំបានចាប់ផ្តើមរៀន ហើយប្រហែលជាដើម ៥៧ ឬក៏ចុង ៥៨ ខ្ញុំដូចជាមិនសូវច្បាស់ទេអំពីចំណុចនេះ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា ក្រោយមកទៀត ក្រៅពីការជួបដំបូងជាមួយលោក ខៀវ សំផន នេះលោកបានជួបលោក ខៀវ សំផន ទៀតទេក្នុងអំឡុងឆ្នាំ ប៉ុន្មានឆ្នាំក្រោយមកទៀតនោះ?

**ឆ៖** នៅពេលដែលគាត់នៅប៉ារីស ខ្ញុំបានជួបគាត់ក្នុងពេលសម្តែងសិល្បៈមួយដែលរៀបចំដោយសមាគមនិស្សិតខ្មែរ ហើយខ្ញុំបានជជែកសំណេះសំណាលជាមួយគាត់ពីព្រោះថាពេលនោះ គឺថាខ្ញុំចង់មកធ្វើការនៅប្រទេសកម្ពុជា ហើយគាត់ៗធ្វើនិក្ខេបបទអំពីសេដ្ឋកិច្ច។ ហើយខ្ញុំៗធ្វើការខាងឧស្សាហកម្ម។ ដូច្នេះ ខ្ញុំគិតថាជាការចាប់អារម្មណ៍ណាស់ចំពោះខ្ញុំ ដើម្បីពិភាក្សាជាមួយគាត់។ បន្ទាប់មកគាត់ចូលមកប្រទេសកម្ពុជា ហើយខ្ញុំមកកម្ពុជានៅក្នុងឆ្នាំ៦១--

**ស៖** លោកៗសាក្សី ខ្ញុំសូមកាត់ចម្លើយលោក ដើម្បីឲ្យសក្ខីកម្មរបស់លោកច្បាស់លាស់នោះ គឺថាយើងជាដំបូងយើងនិយាយអំពីរយៈកាលនៅបារាំង។ លោកៗបានឆ្លើយថាលោកជួបលោក ខៀវ សំផន នៅបុរីសាកលវិទ្យាល័យ។ ហើយបន្ទាប់មកទៀត លោកជួបគាត់ជាច្រើនដងទៀត។ ហើយលោកថាលោកបានជជែកពិភាក្សាជាមួយនឹង ខៀវ សំផន ពាក់ព័ន្ធទៅនឹងវិស័យសេដ្ឋកិច្ច។ តើអ៊ីចឹងមែនទេ លោកសាក្សី?

[១៣:៥១:២៥]

**ឆ៖** បាទ ពិតជាអ៊ីចឹងហើយ។ គឺថានៅក្នុងសន្និសីទមួយដែលត្រូវបានរៀបចំនៅខែមីនា ឆ្នាំ ១៩៥៩។ សន្និសីទនោះមានការអញ្ជើញតំណាងអ្នកអតីតឥណ្ឌូចិន ហើយមានខ្មែរម្នាក់ វៀតណាមម្នាក់ ហើយខ្មែរនុ៎ងហើយគឺដូចលោក ខៀវ សំផន នេះឯង។ ប្រធានបទនៃសន្និសីទនេះ គឺការវិនិយោគបរទេស ឬក្នុងស្រុកនៅក្នុងដែនដីនៃអតីតឥណ្ឌូចិននោះ។

**ស៖** នៅក្នុងសំណុំរឿង យើងមានសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់លោក ហើយលោកបានចុះហត្ថលេខទៀតដែលមានលេខ E190/2.5។ នៅក្នុងនោះគឺថាមានប្រហែលជា១០ជាងទំព័រជាងនោះមានភ្ជាប់នូវកំណត់ត្រាសរសេរដៃមួយ ដែលបានបញ្ជាក់ថាកំណត់ត្រាសរសេរដៃធ្វើក្នុងពេលចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់លោក ខៀវ សំផន ស្តីពីវិស័យវិនិយោគនៅកម្ពុជានាឱកាសសន្និសីទស្តីអំពីបណ្តាលប្រទេសដែលជាអតីតឥណ្ឌូចិនរបស់បារាំងនៅទីក្រុងបារីស ថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៩។ តើលោកពិតជាអ្នកសរសេរកំណត់ត្រានេះមែនទេ?

[១៣:៥៣:០៦]

**ឆ៖** បាទ ពិតហើយ ខ្ញុំជាអ្នកសរសេរមែន។ ហើយខ្ញុំខ្លួនឯងនោះ មានការភ្ញាក់ផ្អើលណាស់ក្នុងការដែលអាចរក្សាកំណត់ត្រានេះ ហើយនិងរកកំណត់ត្រាឃើញវិញនោះ។

**ស៖** តើលោកមានអាចអានកំណត់ត្រាហ្នឹងឡើងវិញបានទេ?

**ឆ៖** បាទ ខ្ញុំពិតជាបានអាន។

**ស៖** តើលោកអាចរៀបរាប់យ៉ាងម៉េចបានតាមរយៈការអានហ្នឹង ដើម្បីឲ្យលោករំឭកអំពីអនុស្សាវរីយ៍របស់លោក អំពី -- ហើយបានលោកចាំខ្លឹមសារ តើវាជាៗ -- លោក ខៀវ សំផន បាននិយាយអំពីបញ្ហាអ្វីពាក់ព័ន្ធទៅនឹងវិស័យវិនិយោគនៅកម្ពុជានោះ?

**ឆ៖** ប្រធានបទសំខាន់នោះគឺជាការផ្លាស់ប្តូរពីសេដ្ឋកិច្ចអាណានិគម។ ដែលមានន័យថាសេដ្ឋកិច្ចមួយដែលប្រទេស ដែលបរទេសនាំចូលមកនូវវត្ថុធាតុដើម ហើយបន្ទាប់មកទៀតលក់ផលិតសម្រេច។ ដូច្នេះវាពាក់ព័ន្ធទៅនឹងឧស្សាហូបនីយកម្មដើម្បីលើកតម្លៃធនធានរបស់ប្រទេសកម្ពុជា។ ដូចជាកសិកម្ម ឈើ កៅស៊ូ។ ដូច្នេះតាមលោក ខៀវ សំផន នោះគឺថាត្រូវអភិវឌ្ឍឧស្សាហកម្មដើម្បីលើកតម្លៃផលិតកម្មក្នុងស្រុក គឺដើម្បីលើកស្ទួយដល់សេដ្ឋកិច្ចក្នុងស្រុក។ គាត់គ្រោងទុកនូវអន្តរាគមន៍របស់រដ្ឋមួយចំនួនក៏ប៉ុន្តែមិនមែនជាអន្តរាគមន៍ដាច់ខាតនិងទាំងស្រុងនោះទេ ពីព្រោះថា យើងមិនត្រូវធ្វើឲ្យវិនិយោគទុនបរទេសភ័យខ្លាចនោះទេ ពីព្រោះថាធនធានរបស់ប្រទេសនោះមិនគ្រប់គ្រាន់សម្រាប់ធ្វើឧស្សាហូបនីយកម្មប្រទេសនោះទេ ហើយនិងមិនអាចឧបត្ថម្ភទៅដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់នោះទេ។ ខ្ញុំនៅចង់ចាំ គឺថាមាននៅក្នុងកំណត់ត្រារបស់ខ្ញុំ លោក ខៀវ សំផន ក៏បានបញ្ចប់សំណេររបស់គាត់នោះ ដែលគាត់និយាយថា ចង់ឲ្យសេដ្ឋកិច្ចរបស់កម្ពុជានោះមានស្វ័យភាព គឺថាមិនមែនថា ឲ្យខ្លួនឧបត្ថម្ភខ្លួនទាំងស្រុងនោះទេ។ នេះជាការសង្ខេបនៅប្រធានបទដែលបានលើកឡើង។

[១៣:៥៥:៤២]

**ស៖** បើយើងមានកូពីនៃកំណត់ត្រានៅក្នុងសំណុំរឿង។ នៅក្នុងភាសាបារាំងនោះគឺ00809334, ជាភាសាខ្មែរ 00907771, ជាភាសាអង់គ្លេស 00911422។ ពាក់ព័ន្ធទៅនឹងវិនិយោគបរទេសនោះ ខ្ញុំឃើញថានៅក្នុងទំព័រមួយនៃកំណត់ត្រសរសេរដែររបស់លោកនោះ លោកបានសរសេរថា "ភាពផ្តាច់មុខនៃពាណិជ្ជកម្មក្រៅប្រទេសនោះ វាធ្វើឲ្យមានការប៉ះពាល់ទៅដល់ដើមទុនឯកជន"។

ហើយចុះក្រោមមកទៀតនៅទំព័រដែលមានតែពាក់កណ្តាល គឺឃ្លាចុងក្រោយនោះសរសេរថា

“ស្វ័យភាព ក៏ប៉ុន្តែមិនមែនខ្លួនទីពឹងខ្លួនដាច់ខាតនោះទេ”។ ដូច្នេះនេះជាអ្វីដែលបញ្ជាក់អំពីអ្វីដែលលោកបានបញ្ជាក់អម្បាញ់មិញនេះ អំពីស្នារតីនៃបទអន្តរាគមន៍របស់លោក ខៀវ សំផន នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៥៩។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតជាអ៊ីចឹងហើយ។

**ស៖** តើខ្លឹមសារនៃពាក្យពេចន៍ដែលលោក ខៀវ សំផន បាននិយាយជាសាធារណៈនៅថ្ងៃនោះ ត្រូវគ្នាទៅនឹងពាក្យពេចន៍ដែលលោកបានជជែកសំណេះសំណាលជាឯកជនជាមួយគាត់នោះដែរឬទេ?

**ឆ៖** បាទ ពិតណាស់ លើកលែងតែថា នៅក្នុងសន្និសីទនោះ គឺនិយាយអំពីវិនិយោគ ក៏ប៉ុន្តែក្នុងពេលដែលខ្ញុំសំណេះសំណាលជាឯកជនជាមួយគាត់នោះ លោក ខៀវ សំផន ក៏បានសង្កត់ធ្ងន់ទៅលើសង្គមកិច្ច គឺគាត់មានន័យថា ត្រូវតែអភិវឌ្ឍសេដ្ឋកិច្ចហើយ គឺសេដ្ឋកិច្ចប្រទេសជាតិត្រូវតែអភិវឌ្ឍ ក៏ប៉ុន្តែទន្ទឹមគ្នានោះយើងត្រូវតែបង្កើនជីវភាពប្រជាជន លើកកម្ពស់ជីវភាពប្រជាជន ជាពិសេសគឺកសិករ។ ខ្ញុំបានជជែកគ្នាជាមួយគាត់ផ្សេងទៀតពាក់ព័ន្ធទៅនឹងប្រធានបទនេះ នៅពេលដែលខ្ញុំនៅប្រទេសកម្ពុជាដែលខ្ញុំអាននឹងនិយាយបានទៅពេលបន្តិចទៀតនេះលោកមេធាវី។

[១៣:៥៨:២៧]

**ស៖** ក្នុងពេលដែលលោកជជែកពិភាក្សាជាមួយលោក ខៀវ សំផន នៅប្រទេសបារាំង និងនៅពេលសន្និសីទនេះ តើមានការនិយាយអំពីការលុបបំបាត់កម្មសិទ្ធិឯកជន ឬក៏ការលុបបំបាត់លទ្ធភាពក្នុងការទទួលបានសម្ភារៈ ឬក៏ទ្រព្យសម្បត្តិ ឬក៏ការលុបបំបាត់រូបិយវត្ថុនេះ។ តើនេះជាសម្ដី -- គាត់មានបាននិយាយអំពីចំណុចទាំងអស់នេះទេនៅពេលដែលលោកពិភាក្សាជាមួយគាត់នោះ?

**ឆ៖** ខ្ញុំដូចជាអត់មានចាំថា គាត់បានលើកឡើងអំពីសំណើនេះទេ។

**ស៖** --

[១៣:៥៩:១៨]

**ប្រធានអង្គជំនុំ៖**

សូមមេធាវីផ្អាកបន្តិចសិន សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ លោកមេធាវី វែកគែន សូមឱ្យលោកទុកពេលបន្តិចរវាងសំណួរ និងចម្លើយនោះ។ ខ្ញុំគិតថា អ្នកបកប្រែទុំង គឺថាគាត់ពិបាកក្នុងការបកប្រែណាស់ ពីព្រោះថាសួរចប់

ភ្លាម ឆ្លើយចប់ភ្លាម សួរភ្លាមអ៊ីចឹង។ ដូច្នេះ សូមឲ្យលោកទុកពេលបន្តិចឲ្យអ្នកបកប្រែ ហើយសំឡេងហ្នឹងក៏វាខុសគ្នាទៀត សំឡេងរបស់លោកនុ៎ង គឺខ្លាំងមែនទែន ហើយសំឡេងរបស់សាក្សីហ្នឹងខ្សោយៗ ស្តាប់មិនសូវបានទេ។ ដូច្នេះសូមឲ្យលោកកុំឲ្យ -- ធ្វើយ៉ាងម៉េចកុំឲ្យវាបញ្ហាលំបាកខាងផ្នែកបច្ចេកទេសនោះ។ សូមឲ្យលោកចាប់អារម្មណ៍លើចំណុចនេះផង។

[១៤:០០:០៥]

**លោក អាកទួរ វែកគែន៖**

បាទ លោកមេធាវី អ៊ីចឹងក៏ខ្ញុំពិបាកដែរនៅពេលដែលខ្ញុំស្តាប់នោះ។ តើមានផ្នែកណាដែលមិនត្រូវបានបកប្រែឲ្យត្រឹមត្រូវ ហើយខ្ញុំត្រូវត្រឡប់មកនិយាយឡើងវិញទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ចំពោះខ្ញុំ ខ្ញុំមិនដឹងច្បាស់ទេ ប៉ុន្តែជាបន្តទៀតនេះសូមឲ្យលោកនិយាយឲ្យបានយឺតបន្តិចទុកពេលឲ្យអ្នកបកប្រែៗបានផង។

[១៤:០០:៣២]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោក ហ្វ៊ីល្បាន សូមឲ្យលោកសង្ខេបអំពីប្រភពនៃសំណើរបស់លោក ខៀវ សំផន នៅសម័យនោះថាតើវាជាសុន្ទរកថាមួយដែលថាជាលក្ខណៈឆ្វេងនិយម ឬក៏វាជាលក្ខណៈកណ្តាលនិយម? តើលោកយល់យ៉ាងណាដែរអំពីសុន្ទរកថារបស់លោក ខៀវ សំផន នៅពេលនោះៗ?

**លោក ហ្វីលីព ហ្វ៊ីល្បាន-ហ្គោប្រែស៖**

**ឆ៖** ខ្ញុំអាចនិយាយបានថា មិនមែនជាសុន្ទរកថាបដិវត្តន៍ទេ នៅកាលពីប៉ុន្មាននោះ គឺថាវាជាប្រមាណ ៦០ឆ្នាំមុននេះ វាគ្រាន់តែជាសុន្ទរកថារបៀបវារគ្និន ក៏ប៉ុន្តែវាបង្ហាញអំពីគោលជំហរដែលពាក់ព័ន្ធទៅនឹងបក្សនយោបាយ ហើយវាមានជាគោលជំហរសង្គមនិយម។

**ស៖** បាទ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីរយៈពេលដែលលោកមកប្រទេសកម្ពុជា ហើយលោកបានប្រាប់ថា ពេលដែលលោកមកនេះគឺថាមកឆ្នាំ១៩៦១ ហើយលោកមកនៅទីនេះរហូតដល់ឆ្នាំ១៩៦៦ ហ្នឹងគឺថានៅជាប់រហូត។ ហើយលោកបាន -- ក្រោយមកទៀតគឺថាលោកបានបំពេញបេសកកម្មម្តងម្កាលទេនៅប្រទេសកម្ពុជា។ តើលោកអាចជម្រាបតុលាការបានដែរឬទេ គឺថាៗចាប់ពីឆ្នាំ៦១ទៅដល់ឆ្នាំ១៩៦៦ ហើយបន្ទាប់មកទៀតគឺថា ដល់ឆ្នាំ១៩៧៤ បើខ្ញុំមិនច្រឡំទេ លោកបានជួបលោក

ខៀវ សំផន ឡើងវិញនៅប្រទេសកម្ពុជា?

[១៤:០២:៤៤]

**ផ៖** បាទ ខ្ញុំបានជួបលោក ខៀវ សំផន នៅកម្ពុជាឡើងវិញហើយ ជាច្រើនដងចន្លោះពីឆ្នាំ ១៩៦១ និង៦៦។ ខ្ញុំបានជួបគាត់ឡើងវិញនោះពីព្រោះខ្ញុំមានឱកាសបានជួបគាត់ គឺថាខ្ញុំបានទៅលេងគាត់នៅផ្ទះគាត់តែម្តង ខ្ញុំបានស្គាល់ម្តាយគាត់ហើយនិងបងប្អូនប្រុសគាត់ម្នាក់ ហើយបានជួបគាត់ច្រើនដងដែរ។ ឧទាហរណ៍ដូចជាខ្ញុំបានអញ្ជើញគាត់ម្តងឲ្យមកទស្សនកិច្ចនៅរោងចក្រដែលខ្ញុំជាប្រធាន ហើយនៅពេលនោះគាត់បានធ្វើសុន្ទរកថាខ្លីមួយជូនទៅបុគ្គលិករោងចក្រហ្នឹង ហើយបុគ្គលិករបស់ខ្ញុំនោះពេញចិត្តនឹងសុន្ទរកថារបស់គាត់ ហើយគេថែមទាំងអរគុណខ្ញុំទៀតផង ដែលខ្ញុំបានអញ្ជើញគាត់មក។ ហើយនៅពេលនោះហើយគឺថា ខៀវ សំផន នោះគាត់ត្រូវបានជ្រើសរើសជាតំណាងរាស្ត្រ ហើយក្លាយជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**ស៖** ខ្ញុំចង់ដឹងពីខ្លឹមសារចម្បងនៃសុន្ទរកថាគាត់នៅពេលនោះ?

**ផ៖** បាទ ខ្លឹមសារចម្បងរបស់សុន្ទរកថារបស់គាត់នោះ ខ្ញុំមិនសូវយល់ទេ ព្រោះថាគាត់និយាយជាភាសាខ្មែរ ក៏ប៉ុន្តែ-- ព្រោះថាកាលនោះៗខ្ញុំចេះខ្មែរមិនទាន់ច្បាស់លាស់នៅឡើយទេ ដើម្បីឲ្យយល់សុន្ទរកថានយោបាយ ឬសេដ្ឋកិច្ចនោះ។ ក៏ប៉ុន្តែតាមរយៈការសន្ទនាពីមុនមកជាមួយគាត់ ហើយនិងក្រោយមកទៀត ខ្ញុំដឹងថាគាត់ចាប់អារម្មណ៍នឹងបញ្ហាសង្គម ហើយនិងកម្រិតជីវភាព គឺថាគាត់ចង់ឲ្យកសិករអាចលក់ផលិតផលរបស់ពួកគេឲ្យក្នុងតម្លៃមួយដែលអាចទទួលយកបាន សមរម្យ ហើយនិងអាចទទួលប្រាក់កម្ចីដោយមានការប្រាក់តិចតួច។ កាលនោះៗ ការប្រាក់ខ្ពស់ណាស់។ ហើយកាលនោះគាត់ក៏ចង់ -- ថាក្រៅពីគិតពីជីវភាពនេះ គាត់គិតពីបញ្ហាសុខភាព ហើយនិងការបណ្តុះបណ្តាលមនុស្សផងដែរ។ ហើយខ្ញុំដឹងថាគាត់ការពារផលប្រយោជន៍របស់ប្រជាជនដែលគាត់ធ្វើជាតំណាងរាស្ត្រ ហើយនិងគាត់ការពារប្រជាជនទាំងអស់នេះប្រឆាំងនឹងអំណាចមូលដ្ឋាន ហើយនិងអំណាចរបស់ពាណិជ្ជករមាន។ អ៊ីចឹងក៏គាត់មានបំណងប្រឆាំងនឹងអំពើពុករលួយ ហើយនិងការរំលោភបំពានអំណាចផងដែរ។

[១៤:០៥:៤០]

**ស៖** តើអ្វីដែលលោកទើបនឹងនិយាយនេះ គឺជាខ្លឹមសារនៃការពិភាក្សារវាងលោក ហើយនិងលោកខៀវ សំផន កាលពីសម័យនោះ?

**ផ៖** បាទអ្វីដែលខ្ញុំទើបតែនិយាយនោះ គឺថាឆ្លុះបញ្ចាំងអំពីការសន្ទនារវាងយើងទាំងពីរ ជួននៅ

ផ្ទះគាត់ ជូននៅរោងចក្រខ្ញុំ ឬក៏ជូននៅកន្លែងផ្សេងទៀត។

**ស៖** លោកទើបតែបាននិយាយថានៅក្នុងពេលពី៦១ ដល់៦៦ហ្នឹង លោកបានធ្លាប់មកលេងផ្ទះលោក ខៀវ សំផន។ តើលោកអាចជូនព័ត៌មានលម្អិតទាក់ទងទៅនឹងកម្រិតជីវភាពរបស់លោក ខៀវ សំផន បានដែរឬទេ ថាដូចរបៀបរស់នៅរបស់គាត់ ស្នាក់នៅ ឬក៏ការផ្លាស់ទីរបស់គាត់ជាដើម?

**ឆ៖** ការរបៀបរស់នៅគាត់ហ្នឹង គឺថារបៀបរស់នៅស្រគត់ស្រគំ មិនជាសម្ញែងអីទេ។ កាលឆ្នាំ៦១នោះ ខ្ញុំទៅលេងគាត់ គាត់នៅជាមួយម្ដាយគាត់នៅផ្ទះមួយ ដែលគេហៅជាភាសាបារាំងថាផ្ទះឈើក្បឿង ឬក៏ថាផ្ទះសង់ផុតពីដី ធ្វើអំពីឈើមានដំបូលក្បឿង។ ហើយពីរបីឆ្នាំក្រោយមកទៀត គាត់បានដូរផ្ទះ ហើយគាត់ទៅនៅផ្ទះមួយទៀតដែលមិនធំទេ។ ហើយម្ដងនេះធ្វើអំពីថ្ម។ កាលណោះ គាត់ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មហើយ។ គាត់មិនផ្លាស់ទីដោយជិះកង់ទៀតទេ ប៉ុន្តែជិះឡាន។ ក៏ប៉ុន្តែឡាននេះគឺថាឡានជជុះទេ ហើយម៉ាកនោះក៏មិនមែនជាម៉ាកអីអស្ចារ្យដែរ។ អ៊ីចឹងខ្ញុំគិតថាគាត់តែងតែប្រកាន់យកជីវភាពមួយដែលថា សាមញ្ញ សមរម្យ។

[១៤:០៧:៤៨]

**ស៖** នៅក្នុងក្របខណ្ឌនៃសកម្មភាពជាអាជីពរបស់លោកនៅក្នុងក្រុមហ៊ុនអ៊ែលីគីដរបស់លោកនោះក្នុងអំឡុងឆ្នាំទាំងអស់នោះ តើលោកធ្លាប់ជួបអ្នកនយោបាយខ្មែរដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ជួបពីព្រោះថាពីដំបូងដោយសារថា ប្រធានក្រុមហ៊ុនដែលខ្ញុំដឹកនាំហ្នឹងជាអ្នកដែលរដ្ឋាភិបាលតែងតាំង។ គាត់នោះជាអតីតប្រធានខាងអយស្ម័យយាន ផ្លូវដែក។ ហើយបន្ទាប់មកទៀត គាត់ត្រូវបានតែងតាំជាឯកអគ្គរាជទូតនៅវ៉ាស៊ីនតោន ហើយបន្ទាប់មកទៀតមានលោក ម៉ៅ សាយ ដែលជារដ្ឋមន្ត្រីក្រសួងផែនការ។ បន្ទាប់មកទៀតមានអ្នកម្ចាស់ភាគហ៊ុន ដែលជាឯកជន ដែលជាពាណិជ្ជកម្ម ហើយក៏មានអ្នកនយោបាយផងដែរ។ ឧទាហរណ៍ដូចជាអតីតនាយករដ្ឋមន្ត្រី មានលោក សិរិមតៈ ដែលជាសមាជិកក្រុមគ្រួសារមហាក្សត្រ។ ហើយក្នុងចំណោមអ្នកទាំងអស់នេះ ខ្ញុំក៏ធ្លាប់ទៅជួបក្រសួងឧស្សាហកម្ម ហើយក្រសួងពាណិជ្ជកម្មផងដែរ គឺថាមានឥស្សរជននៅក្នុងក្រសួងទាំងអស់នោះ ខ្ញុំធ្លាប់បានទៅជួបដែរ។

[១៤:០៩:២៤]

**ស៖** អ៊ីចឹងគឺថាភាពសាមញ្ញនៃជីវិតរបស់លោកខៀវ សំផន នៅសម័យនោះ តើវាផ្ទុះបញ្ចាំងពីភាពខុសគ្នា អំពីអ្នកនយោបាយដែលលោកបានមានឱកាសធ្លាប់បានជួបនៅសម័យនោះនៅកន្លែង

ផ្សេងៗទេ?

**ឆ៖** បាទ ខ្ញុំគិតថានៅក្នុងចំណោមអ្នកនយោបាយនោះ គឺថាមានអតីតឥស្សរជននៃគណបក្សប្រជាធិបតេយ្យដែលត្រូវបានដកចេញពីឆាកនយោបាយដោយសម្ដេចសីហនុ។ ហើយពួកទាំងអស់នោះក្រោយមកក្លាយជាពាណិជ្ជករ ហើយរស់នៅសមរម្យ ហើយក្រៅពីនុ៎ងថាមានអ្នកដែលនៅកាន់អំណាចដែលពេលនោះពិតជាមានការរស់នៅហ៊ឺហា សម្ញែងណាស់ ខុសពីករណីលោក ខៀវ សំផន។

**ស៖** ដោយសង្ខេប តើលោកអាចពិពណ៌នាអំពីស្ថានភាពសេដ្ឋកិច្ចនៃប្រទេសកម្ពុជានៅពេលនោះ គឺថានៅមុនពេលដែលខ្មែរក្រហមចូលកាន់អំណាចដែរឬទេ? កាលនោះគឺថាលោកមានសកម្មភាពអាជីព ដែលជាច្រើននៅពេលនោះ គឺថាលោកធ្វើការរហូតដល់ឆ្នាំ១៩៧៤ឯណោះ។ អ៊ីចឹងតើលោកអាចពិពណ៌នាស្ថានភាពសេដ្ឋកិច្ចនៅប្រទេសកម្ពុជាបានដែរឬទេ? បាទ អ៊ីចឹងសូមលោកអញ្ជើញធ្វើដោយសង្ខេប។

[១៤:១១:០២]

**ឆ៖** អ៊ីចឹងកាលនុ៎ង គឺថាគេមានការប្រឹងប្រែងក្នុងការធ្វើឧស្សាហកម្ម គឺថាដោយមានជំនួយពីចិននោះ គឺថាចិនគេផ្ដល់រោងចក្របួន រោងចក្រស៊ីម៉ង់ង៍ រោងចក្រកុងប្លាកេ រោងចក្រផលិតក្រដាស ហើយនិងមានរោងចក្រទី៤។ រោងចក្រទាំងបួននេះគឺថាដំណើរការល្អ។ ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាកាលណោះនោះ បើនិយាយទៅគឺថាជាក្នុងសេដ្ឋកិច្ចអាណានិគមនៅឡើយទេ ព្រោះថាមានដូចជាចម្ការកៅស៊ូ ផលិតផលរបស់ចម្ការនោះសុទ្ធជាផលិតផលមានគុណភាពល្អ ក៏ប៉ុន្តែមិនបានធ្វើនៅប្រទេសកម្ពុជាដោយផ្ទាល់នោះទេ។

នៅឆ្នាំ១៩៦៣ សម្ដេច សីហនុ បានជំទាស់ជំនួយបរទេស ឧទាហរណ៍ដូចជា ជំនួយអាមេរិកាំង ដោយព្រះអង្គចង់បានទទួលបាននូវសេដ្ឋកិច្ចជាតិជាង។ យើងនិយាយទៅសេដ្ឋកិច្ចកាលណោះនោះមិនជាណាស់ណានោះទេ ក៏ប៉ុន្តែកសិករនោះ ដោយសារខ្លួនប្រឹងប្រែងធ្វើការហ្នឹង គឺថាអាចចិញ្ចឹមជីវិតបាន។ ថាមានអ្នកក្រមែន ប៉ុន្តែមិនមានអ្នកអត់បាយស្លាប់នោះទេ។ ក៏ប៉ុន្តែមានអ្នកដែលមាននោះមួយក្ដាប់តូច ដែលកាន់តែមានទៅៗ ដោយសារពាណិជ្ជកម្មរបស់គេ ដោយសារពាណិជ្ជកម្មអន្តរជាតិ ឬការ ឬក៏សកម្មភាពរបស់គេដែលទាក់ទងទៅនឹងការធ្វើហេដ្ឋារចនាសម្ព័ន្ធជាដើមនោះ។

**ស៖** បាទ ដូច្នេះស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជានៅពេលនោះ គឺដូចជាស្ថានភាពមួយដែលថាមិនមែនជាស្ថានភាពសេដ្ឋកិច្ចដែលថាអភិវឌ្ឍណាស់ណានោះទេ។ បើតាមការទទួលការបណ្ដុះបណ្ដាល

របស់លោក ហើយនិងការចំណេះដឹងរបស់លោកទាក់ទងនឹងសេដ្ឋកិច្ចប្រទេសកម្ពុជា តើគំនិតយោបល់របស់លោក ខៀវ សំផន ដើម្បីឲ្យធ្វើការកែទម្រង់នោះ លោកគិតថានេះវាពិតជាការកែទម្រង់ជាលក្ខណៈតក្កវិទ្យា ឬក៏វាប្រកបដោយវិចារណញ្ញាណដែរឬទេ?

[១៤:១៣:៣៥]

**ឆ៖** គឺថាពិតជាសមស្របហើយ ពីព្រោះថាគឺជាការផ្តល់តម្លៃទៅដល់ធនធានមនុស្ស ធនធាននៅក្នុងស្រុក ដើម្បីឲ្យយើងទទួលបាននូវសេដ្ឋកិច្ចដើរលឿនជាងមុន ហើយនិងដើម្បីលើកស្ទួយជីវភាពប្រជាជន ជាពិសេសកសិករ។

**ស៖** បាទ ខ្ញុំគិតថាលោកមិនមែនបានត្រឡប់មកប្រទេសកម្ពុជានៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ?

**ឆ៖** បាទ ពិតហើយខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាវិញ តែឆ្នាំ២០០៥ឯណោះទេ។ មកហ្នឹងលក្ខណៈឯកជន។

**ស៖** តើលោកយល់អំពីការចូលរួមរបស់លោក ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំគិតថាតួនាទីដែលគាត់មាននៅពេលនោះ មានតួនាទីនេះដោយសារអ្នកមានអំណាចនៅក្នុងកម្ពុជាប្រជាធិបតេយ្យផ្តល់ឲ្យគាត់។ ពីព្រោះថាពួកអ្នកមានអំណាចនេះត្រូវការប្រមុខរដ្ឋមួយដែលមានប្រជាប្រិយភាព ហើយនិងដែលគួរឲ្យគោរព។ ពួកគេបានទទួលជ្រើសរើស គាត់ជាមនុស្សទី១ ជាប្រមុខរដ្ឋនោះគឺសម្តេច សីហនុ ដែលមានប្រជាប្រិយភាព ហើយដែលពិភពលោកទាំងមូលស្គាល់។ ១ឆ្នាំក្រោយមក ពេលដែលពួកគេចង់ប្តូរប្រមុខរដ្ឋ គេបានគិតទៅដល់ ខៀវ សំផន ពីព្រោះថា ខៀវ សំផន កាលនោះក៏មានប្រជាប្រិយភាពដែរ។

[១៤:១៥:៣៧]

លោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ នៅក្នុងសៀវភៅមួយរបស់គាត់គាត់និយាយថា លោក ខៀវ សំផន ជាគំរូរបស់យុវជន។ ហើយគឺជាឥស្សរជនគួរជាទីគោរព។ គាត់មានសញ្ញាប័ត្របណ្ឌិតផ្នែកសេដ្ឋកិច្ចនៅប្រទេសអឺរ៉ុប គឺថានៅប្រទេសបារាំង។ គាត់និយាយភាសាបារាំង ដែលជាភាសាផ្លូវការមួយនៃភាសាទាំង៥ នៃអង្គការសហប្រជាជាតិ។ គាត់ត្រូវបានទទួលស្គាល់ដោយស្ថានទូតបរទេសនៅប្រទេសកម្ពុជាពីព្រោះគាត់ជាតំណាងរាស្ត្រហើយនិងជារដ្ឋមន្ត្រី។ ហើយនៅពេលដែលគាត់បាត់ខ្លួនជាមួយ ហ៊ូ

យន់, ហ៊ូ នឹម នៅក្នុងឆ្នាំ១៩៥៧ គេនិយាយពីការបាត់ខ្លួនគាត់ច្រើនណាស់នៅក្នុងផ្នែកឯកជន ហើយនិងតាមស្ពានទូតនិងតាមអត្ថបទកាសែតជាច្រើន។ អ៊ីចឹង គឺជាមនុស្សដែលមានប្រជាប្រិយភាពគួរជាទីគោរព ហើយនិងគេស្គាល់ច្រើន។ ហើយគឺថាដោយលក្ខណៈវិនិច្ឆ័យនេះហើយដែលលោក ខៀវ សំផន ត្រូវបានគេជ្រើសរើសជាប្រមុខរដ្ឋ។

[១៤:១៦:៥៧]

**ស៖** អម្បាញ់មិញលោកបានឆ្លើយថា លោកបានត្រឡប់មកប្រទេសកម្ពុជាវិញនៅខ្ទង់ឆ្នាំ២០០០ ខ្ញុំគិតថាអំមិញនេះលោកនិយាយថាឆ្នាំ២០០៥ ហើយ២០០៦ ផងដែរ។ តើក្នុងពេលនេះដែលលោកត្រឡប់មកវិញនេះ អាចថាមុនពេលដែលលោកត្រឡប់មកវិញផង ទោះយ៉ាងណាក្តីគឺថាក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យរលំទៅនោះ ខ្ញុំចង់ដឹងថាតើលោកធ្លាប់បានជួបលោក ខៀវ សំផន ឡើងវិញទេ?

**ឆ៖** បាទ ខ្ញុំបានជួបលោក ខៀវ សំផន ឡើងវិញនៅឆ្នាំ១៩៩០ នៅពេលដែលគាត់ទៅទីក្រុងប៉ារីស។ គាត់នៅកន្លែង ផ្លាស បារសឺឡូន – នៅការិយាល័យមួយដែលជាការិយាល័យរបស់រដ្ឋាភិបាលចម្រុះនោះ។ ហើយកាលនោះមានសម្តេចសីហនុ ជាប្រធាន ហើយ សឺន សាន ជាអនុប្រធាន, ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រី។ ហើយបន្ទាប់មកទៀត ខ្ញុំបានជួបគាត់នៅឆ្នាំ១៩៩២, ២០០៥, ២០០៦ ខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាវិញ ហើយខ្ញុំបានជួបគាត់ច្រើនថ្ងៃដែរ។ នៅឆ្នាំ២០០៥ ខ្ញុំទៅប៉ៃលិន ខ្ញុំស្នាក់នៅផ្ទះគាត់។ ហើយខ្ញុំឃើញផ្ទះចាស់របស់គាត់នៅទីនោះ គឺថាផ្ទះក្បឿងដែលខ្ញុំបានពិពណ៌នាអម្បាញ់មិញអ៊ីចឹង។ ហើយក្រោយមកទៀតគាត់នៅផ្ទះថ្ម ប្រពន្ធគាត់នោះធ្វើការ ធ្វើម្ហូបម្ហានៅក្រៅផ្ទះទេ។ អ៊ីចឹងផ្ទះនោះមិនមានផាសុកភាពអីទេ អត់ទាំងមានទឹកម៉ាស៊ីនផង។

[១៤:១៨:៤៩]

ហើយឆ្នាំបន្ទាប់មកទៀត ២០០៦ នោះខ្ញុំទៅអន្លង់វែងដែលកូនប្រុសគាត់រស់នៅទីនោះ ហើយយើងបានស្នាក់នៅផ្ទះកូនប្រុសគាត់។ ផ្ទះនោះ ផ្ទះតូចតាចទេ ហើយកូនប្រុសគាត់ជាអ្នកលក់សាំងដប។ នៅផ្ទះក្រោមផ្ទះគាត់នោះ តាមពិត បន្ទប់នៅលើកន្លែងដែលគាត់លក់សាំងលក់អីហ្នឹង។ ហើយបន្ទាប់មកទៀតយើងបានទៅព្រះវិហារទៅ មើលប្រាសាទព្រះវិហារ។ តាមផ្លូវយើងឈប់ច្រើនដំណាក់ដែរ។ នៅតាមភូមិផ្សេងៗនោះ ខ្ញុំសង្កេតឃើញថាប្រជាជននៅតាមភូមិនោះនៅគោរពលោក ខៀវ សំផន ច្រើនណាស់ គោរពស្រលាញ់គាត់។

**ស៖** បាទ លោកបាននិយាយថា លោកបានជួបលោក ខៀវ សំផន នៅឆ្នាំ១៩៩០ នៅទីក្រុង

ប៉ារីសតើលោកដឹងថាលោក ខៀវ សំផន ធ្វើអីទេនៅពេលនោះ?

**ឆ៖** ខ្ញុំគិតថាកាលណោះ គាត់ធ្វើដំណើរទៅប្រទេសផ្សេងៗ ដើម្បីត្រៀមកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ កាលពេលនោះៗ គាត់ក៏បានទៅអាហ្វ្រិកដែរ ហើយមិត្តភក្តិខ្ញុំម្នាក់ដែលជាជនជាតិថៃ ដែលជាឯកអគ្គរដ្ឋទូតថៃប្រចាំនៅប្រទេសកេនយ៉ាបានជួបគាត់ដែរ។ ខ្ញុំគិតថាពួកគាត់បាននិយាយអំពីស្ថានភាពប្រទេសកម្ពុជាបន្ទាប់ពីវៀតណាមចូលលុកលុយប្រទេសកម្ពុជា។ អានេះនិយាយពីគោលជំហររបស់ប្រទេសទេសថៃមកប្រទេសកម្ពុជា ខ្ញុំមិនដឹងថាគាត់និយាយអីពិតប្រាកដទេ ខ្លឹមសារការពិភាក្សារបស់គាត់នោះ រវាងឯកអគ្គរដ្ឋទូតថៃនៅប្រចាំនៅប្រទេសកេនយ៉ាជាមួយលោក ខៀវ សំផន នោះ ក៏ប៉ុន្តែធ្វើយ៉ាងណាក្តី គាត់ស្ងើចសរសេរលោក ខៀវ សំផន ចំពោះបុគ្គលិកលក្ខណៈរបស់គាត់។

[១៤:២១:១២]

**លោក អាកទូរ វែកកែន៖**

បាទ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ លោក ហ្ស៊ីល្បាន ខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចៅក្រម សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមជម្រាបសួរលោក ហ្ស៊ីល្បាន-ហ្គោប្រែស ខ្ញុំជាចៅក្រម ឡាវែន៍ ចៅក្រមអន្តរជាតិ។ បាទ ជាបឋមខ្ញុំសូមត្រឡប់មកនិយាយពីជំនួបពីដំបូងជាមួយលោក ខៀវ សំផន នៅក្នុងឆ្នាំ៥០។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ នៅក្នុងការសន្ទនារបស់លោកនៅពេលលោកជួបលោក ខៀវ សំផន នោះ តើលោកនិយាយអំពីនយោបាយដែរឬទេ?

[១៤:២២:១៨]

**លោក ហ្វីលីព ហ្ស៊ីល្បាន-ហ្គោប្រែស៖**

**ឆ៖** បាទ លោកចៅក្រមជាទីគោរព! ខ្ញុំពិភាក្សាជាមួយគាត់បន្តិចបន្តួចតែប៉ុណ្ណោះ ពីព្រោះថាការ គាត់បានចាកចេញពីប្រទេសបារាំងនៅខែឧសភា ឆ្នាំ១៩៥៩ ហើយខ្ញុំបានជួបគាត់ឆ្នាំ៥៨។ យើងមិនបាននិយាយអ្វីឲ្យបានលម្អិតអំពីបញ្ហានយោបាយអីទេ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ ខ្ញុំយល់ច្បាស់ណាស់ថា

គាត់ចង់ឲ្យប្រទេសកម្ពុជាវិវត្តន៍ របបនយោបាយប្រទេសកម្ពុជាវិវត្តន៍ទៅលទ្ធិប្រជាធិបតេយ្យសាធារណៈប្រជាមានិត។ ប៉ុន្តែគាត់មិនចង់ឲ្យការវិវត្តនេះវិវត្តន៍គំហុកទេ គឺថាឲ្យវិវត្តន៍ទៅថាបន្តិចម្តងៗ។ គាត់ចង់បញ្ចៀសការធ្វើបដិវត្តន៍ ប៉ុន្តែចង់ឲ្យការវិវត្ត។

**ស៖** តើលោក ខៀវ សំផន ធ្លាប់បាននិយាយប្រាប់លោកថា ចាប់ពីឆ្នាំ១៩៥៧មកនោះ គាត់ជាសមាជិកនៃរង្វង់ក្រុមម៉ាក្សស៊ីស។ តើលោកដឹងថាពួកគាត់ហ្នឹងមានប្រជុំនៅក្នុងបន្ទប់ណាទេ វង់ម៉ាក្សស៊ីសទេ?

**ឆ៖** បាទខ្ញុំអត់មានព័ត៌មានជាក់លាក់អីទាក់ទងនឹងចំណុចនេះលោកចៅក្រម។

[១៤:២៣:៥៦]

**ស៖** ខ្ញុំគិតថា ខ្ញុំសន្មត់ថានៅក្នុងកិច្ចការរបស់និស្សិតខ្មែរនៅទីនោះ ប្រហែលជាលោកធ្លាប់បានជួបពួកគាត់ហើយ។ តើលោកមានធ្លាប់បានជួបលោក អ៊ុក សាគន្ធ ទេ?

**ឆ៖** ខ្ញុំមិនចាំឈ្មោះ អ៊ុក សាគុន្ធ នោះទេ ប៉ុន្តែខ្ញុំគិតថាប្រហែលជាអាចជួប ព្រោះថាកាលណោះខ្ញុំជួបមនុស្សប្រហែលជា៣០-៤០នាក់ណោះនៅប៉ារីសនោះ។ ជាពិសេសនោះ គឺចាប់ពីពេលដែលប្រទេសកម្ពុជាបានសង់បុរីនិស្សិតនៅទីក្រុងប៉ារីស។ អ៊ីចឹងប្រហែលជាៗជាង១០០នាក់ណោះ ខ្ញុំស្គាល់ច្រើន ក៏ប៉ុន្តែមិនស្គាល់ទាំងអស់ទេ។

**ស៖** តើក្នុងចំណោមនិស្សិតទាំងអស់នោះ តើលោកៗមានលោកធ្លាប់ជួបអ្នកណាដែលថាមានចំណាប់អារម្មណ៍លើបក្សកុម្មុយនីស្តដែរឬទេ? លទ្ធិកុម្មុយនីស្តទេ?

**ឆ៖** បាទ ជួបអ្នកខ្លះគេប្រាប់ថា គេបានចូលជាសមាជិកបក្សកុម្មុយនីស្តអន្តរជាតិ គឺថាដែលមានធ្វើសន្និបាតមួយឆ្នាំម្តង ឬពីរម្តង ជួនកាលនៅទីក្រុងប្រាក នៅអីអ៊ីចឹងទៅ។

[១៤:២៥:២៤]

**ស៖** បើតាមលោក យោបល់លោកនោះថាតើលោក ខៀវ សំផន អាចចូលប្រលូកនឹងចលនាហ្នឹងដែរឬទេ? បាទ គឺថាចូលមិនមែនដោយសារថាគាត់គាំទ្រមនោរគមន៍វិជ្ជាហ្នឹងទេ ប៉ុន្តែដោយសារគាត់ស្នេហារជាតិឬក៏ថាគាត់ចូលទៅដើម្បីគ្រាន់តែជាចងស្ពានមួយ ជាស្ពានចម្លងមួយដើម្បីបម្រើអ្វីមួយ?

**ឆ៖** ខ្ញុំដឹងថា លោក ខៀវ សំផន កាលណោះគាត់នៅលីវទេ ហើយគាត់ធ្វើអ្វីៗទាំងអស់ហ្នឹងគឺដើម្បីអភិវឌ្ឍន៍ប្រទេសរបស់គាត់ ដោយចូលរួមធ្វើសកម្មភាពផ្សេងៗខុសគ្នា ហើយគោលបំណងចម្បងរបស់គាត់ហ្នឹងគឺថា ធ្វើឲ្យលក្ខខណ្ឌជីវិត ជីវភាពប្រជាជនកម្ពុជាប្រសើរជាងមុន ហើយនិងដើម្បី

ឲ្យស្ថានភាពសេដ្ឋកិច្ចប្រសើរឡើង។

[១៤:២៦:៤២]

**សៈ** លោក ខៀវ សំផន ត្រូវបានគេស្តាប់ពេលពីដើមសវនាការនេះច្រើនដង។ ហើយបើតាមការចូលប្រលូកនៅក្នុងរង្វង់ម៉ាកស៊ីសនេះ នៅពេលគេស្តាប់គាត់នៅឆ្នាំ២០១១ នៅម៉ោង១២:២២នាទី ជាភាសា -- ERN ជាភាសាបារាំងគឺ 00661941 ដល់50, ERN ជាភាសាអង់គ្លេស 00761840 ដល់45, ឯកសារ E3/21.1។ លោក ខៀវ សំផន បាននិយាយថា គាត់បានទៅប្រទេសបារាំង គាត់បានចូលទៅក្នុងរង់ម៉ាក្សស៊ីស ដោយសារមិត្តរបស់គាត់ម្នាក់បង្ខំគាត់។ មិត្តដែលរៀននៅសាលាស៊ីសុវត្ថិ ឈ្មោះ អ៊ុក សុគន្ធ ហើយជាក់ច្បាស់ជាងនេះទៅទៀត គឺថាគាត់ក៏យល់ព្រមទៅ ដោយសារគេទទូចពេក ហើយគាត់បានចូលក្នុងរង់ម៉ាក្សស៊ីសនេះ ដោយសារគាត់ហ្នឹងមិនចង់ឲ្យ អ៊ុក សុគន្ធ នោះចាត់ទុកថាគាត់ជាមនុស្សកំសាក។ ហើយគាត់និយាយថា បន្ទាប់ពីបានសង្កេតស្ថានការណ៍នយោបាយនៅទីក្រុងប៉ារីស គាត់ត្រូវតែពិចារណាឲ្យបានវែងឆ្ងាយបន្តិច (ដកឃ្លាបន្តិច) ដោយមូលដ្ឋាននេះហើយបានជាគាត់ចេញទៅទីក្រុង ម៉ុងប៉ីលីយ៉េ ដោយយកលេសថា នៅទីនោះអាកាសធាតុវាល្អជាងសម្រាប់គាត់។ តើពាក្យសម្តីទាំងអស់នេះរបស់លោក ខៀវ សំផន នេះធ្វើឲ្យលោកភ្ញាក់ផ្អើលទេ ឬក៏លោកធ្លាប់និយាយអំពីបញ្ហានេះជាមួយលោក ខៀវ សំផន ទេ?

[១៤:២៨:៣៤]

**ធៈ** ខ្ញុំអត់មានភ្ញាក់ផ្អើលអីទេ។ ខ្ញុំមិនបាននិយាយជាមួយគាត់ពីប្រធានបទនេះនោះទេ ក៏ប៉ុន្តែខ្ញុំមិនធ្លាប់ភ្ញាក់ផ្អើលអីទេ បើកាលក្នុងទសវត្សរ៍ឆ្នាំ៥០ គឺថាមានតែបក្សកុម្មុយនីស្តបារាំងទេ ដែលទទួលយកអ្នកដែលនិយមឯករាជ្យ ដែលស្ថិតនៅក្នុងប្រទេសស្ថិតនៅក្រោមអាណានិគម។ ដូច្នេះ ខ្ញុំមិនភ្ញាក់ផ្អើលអីទេដែលថា ពីព្រោះថាផ្លូវមានតែមួយគត់ទេចំពោះលោក ខៀវ សំផន នោះ គឺថាគាត់ត្រូវតែផ្សាភ្ជាប់ខ្លួនទៅនឹងបក្សកុម្មុយនីស្តបារាំង។

**សៈ** អានេះប្រហែលជាលើសពីការខិតជិតទៅបក្សកុម្មុយនីស្តបារាំងហើយ ព្រោះថាពេលនោះ អៀង សារី បានឲ្យគាត់ធ្វើជាប្រធានរង់ម៉ាក្សស៊ីសនេះ។ នៅក្នុងសវនាការដដែលនេះ គាត់និយាយថា គាត់ទទួលបន្ទុកនោះ ពីព្រោះថា អ្នកដែលជាក់លាក់ជាងគេត្រឡប់មកប្រទេសកម្ពុជាវិញហើយ មានតែគាត់ទេដែលអាចទទួលតំណែងនេះជំនួសបាន ហើយគាត់ឃើញថា គាត់អាចមានលទ្ធភាពធ្វើអ្វីមួយមានប្រយោជន៍ ដោយបំពាក់បំប៉នស្មារតីស្នេហាជាតិដល់សមាជិករបស់ខ្លួននៃរង់ម៉ាកស៊ីសនេះ។ អ៊ីចឹង

ប្រហែលជាមិនមែននៅត្រឹមតែថាបង្ខិតខ្លួនឲ្យមកជិតបក្សកុម្មុយនីស្តនេះទេ ពីព្រោះថាគាត់ជា -- គាត់វាលើសពីហ្នឹងទៅទៀត ព្រោះថាគាត់ជាប្រធានវង់ម៉ាកស៊ីសនេះផង។ ក៏ប៉ុន្តែលោកនិយាយអំមិញថាគាត់ជាប្រកាន់ខាងសង្គមនិយមទេ។ អ៊ីចឹងតើនេះមានភាពផ្ទុយគ្នាទេ?

[១៤:៣០:៤០]

**ឆ៖** បាទ ដូចខ្ញុំបានលើកឡើងអម្បាញ់មិញអ៊ីចឹង គឺថាបក្សសង្គមនិយមមិនមែនជាអង្គការមួយដែលមានសកម្មភាពខ្លាំងក្លានោះទេ ទាក់ទងទៅនឹងការបំបាត់អាណានិគមនោះ។ គឺថាអង្កាល់នោះមានតែបក្សកុម្មុយនីស្តទេដែលធ្វើចលនាបំបាត់អាណានិគមនិយម តែគ្រាន់តែថាលោក ខៀវ សំផន នេះគាត់ចាប់អារម្មណ៍លើបញ្ហាសេដ្ឋកិច្ចខ្លាំងជាង។ ហើយផ្នែកនយោបាយនេះមានតែបក្សកុម្មុយនីស្តទេដែលអាចធ្វើឲ្យលោក ខៀវ សំផន ពេញចិត្តបាន។

**សៈ** តើលោកដឹងថា តើនៅក្នុងរបបសង្គមនិយមនេះគេនេះទេ គេធ្វើការទិតៀនស្វ័យទិតៀនអីទេ? អង្កាល់នោះយើងនៅឆ្នាំ៥៧, ៥៨ ឬ៥៩។ ឯករាជ្យប្រទេសត្រូវបានផ្តល់ជូនប្រទេសកម្ពុជាតាំងពីឆ្នាំ៥៣មកម្ល៉េះ។

**ឆ៖** ជាបឋមនោះគឺថាខ្ញុំមិនដែលទៅជួបវង់ម៉ាកស៊ីសនោះទេ ហើយនៅនិន្នាការនយោបាយនៅឆ្នាំ៥៣, ៥៤ នេះគឺថាឯករាជ្យ ទទួលបានមែនស្រុកខ្មែរនេះ ប៉ុន្តែផ្នែកសេដ្ឋកិច្ចនោះគឺថានៅតែជាសេដ្ឋកិច្ចអាណានិគមនៅឡើយទេ គឺថារហូតដល់ចុងឆ្នាំហាប្តាយនោះ ជិតដល់ឆ្នាំ៦០នោះ។

**សៈ** អ៊ីចឹងពាក្យ “ការងារ” ដែលគេហៅថា “រណសិរ្សរួបរួមជាតិនោះ” មានន័យថាយ៉ាងម៉េចដែរចំពោះលោក?

[១៤:៣២:៣២]

**ឆ៖** គ្មានន័យអីទេចំពោះខ្ញុំ។

**សៈ** ទាក់ទងនឹងរូបភាពរបស់លោក ខៀវ សំផន ខ្ញុំ -- អម្បាញ់មិញនេះលោកនិយាយថាលោក ខៀវ សំផន ជាមនុស្សមានប្រជាប្រិយភាព គួរជាទីគោរព ហ្មត់ចត់ ស្មោះត្រង់។ តើខ្ញុំអាចនិយាយបានដែរឬទេថា ជាមនុស្សដែលមិនជ្រុលនិយម ហើយជាមនុស្សដែលធ្វើឲ្យគេទាំងអស់គ្នាទុកចិត្ត។ គឺថាគ្រប់មជ្ឈដ្ឋានទាំងអស់ទុកចិត្តគាត់?

**ឆ៖** បាទ ពិតជាត្រឹមត្រូវហើយ។ ហើយលោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ គាត់សរសេរនៅក្នុងសៀវភៅរបស់គាត់នោះ គាត់បានចាត់ទុកលោក ខៀវ សំផន ថា “លោក ខៀវ សំផន ជាមនុស្សស្អាត

ស្អំ ជាមនុស្សស្មោះត្រង់" ហើយភាពស្មោះត្រង់របស់គាត់នេះគឺថា គេទទួលស្គាល់គាត់ទោះបីជាគេកាន់និន្នាការនយោបាយខុសពីគាត់ក៏ដោយ។ ដូច្នេះ ភាពស្មោះត្រង់របស់គាត់នេះខ្លាំងណាស់ ហើយនិងចំណាប់អារម្មណ៍របស់គាត់ទៅលើបញ្ហាសង្គម។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺថាអម្បាញ់មិញនេះគឺថាលោកនិយាយថា រូបភាពនេះគឺជារូបភាពមួយដែលចលនាខ្មែរក្រហមអាចប្រើ ដើម្បីឲ្យទុកចិត្តលោក ខៀវ សំផន?

**ឆ៖** បាទ ហ្នឹងដែលអ៊ីចឹងហើយ។

[១៤:៣៤:១២]

**ស៖** ឥឡូវនេះខ្ញុំចូលទៅសំណួរផ្សេងមួយទៀត ប្រហែលជាមានភាពឈឺចាប់បន្តិចចំពោះលោក។ នៅក្នុងឯកសារដែលលោកបានផ្ញើមកតុលាការ គឺឯកសារ E190/2.5 ដែលជាលិខិតបញ្ជាក់របស់លោក។ លោកបានសរសេរថា បានបាត់សមាជិកគ្រួសារសាច់ថ្លៃរបស់លោក ហើយនិងមនុស្សជាច្រើនជា ដែលជាមិត្តភក្តិរបស់លោក ដូចជា ឪពុកក្មេករបស់លោក, បងប្អូនថ្លៃរបស់លោក ហើយនិងមានប្រពន្ធកូនរបស់ពួកគេ ហើយឧទាហរណ៍ដូចជាលោក អ៊ុន សុកន, អ៊ុន សុផាន់, លោក ស្ងួន កាសេត, លោក តូច ខាំឌឿន, លោក ឌី ផុន។ តើលោកដឹងទេថា តើពួកគាត់ទាំងអស់ហ្នឹងស្លាប់នៅឯណា ដូចជាលោក អ៊ុន សុកាន, ស្ងួន កាសិត, តូច ខាំឌឿន, ឌី ផុន ជាដើមនេះ?

**ឆ៖** ខ្ញុំមិនដឹងច្បាស់ទេ។ ក៏ប៉ុន្តែខ្ញុំមានបញ្ជីឈ្មោះមនុស្សដែលត្រូវបានសម្លាប់នៅ ស-២១។ ខ្ញុំមិនចាំថាអ្នកណាស្លាប់នៅឯណាទេ។ ក៏ប៉ុន្តែនៅឆ្នាំ៧៩នោះ គឺពួកគាត់ស្លាប់អស់ទៅហើយ។

**ស៖** បាទលោក អ៊ុន សុផាន ត្រូវបានឃុំនៅស-២១ គឺលេខ ២៩៨៩ ដែលជាបញ្ជីអ្នកទោសស-២១ ឯកសារ E3/352-- សូមទោស 342។ លោក ស្ងួន កាសេត ក៏ឃុំនៅស-២១ដែរ គឺនៅលេខរៀង ១០៩០ នៅក្នុងបញ្ជីឈ្មោះដដែល។ ហើយលោក តូច ខាំឌឿន ក៏ត្រូវបានឃុំនៅស-២១ដែរ គឺថាលេខ ១០៨១៨។ លោក ឌី ផុន ក៏ឃុំនៅស-២១ដែរ គឺលេខ១៩៣៧។ លោកបានឆ្លើយថា ក្នុងចំណោមអ្នកទាំងអស់ហ្នឹង លោកអត់បានជួបទៀតទេ ហើយក្នុងនោះក៏មានកម្មាភិបាលនៅក្នុងក្រុមហ៊ុនរបស់លោកដែរ។ ឧទាហរណ៍ដូចលោក តាំង គឹមយុន, លោកស្រី និល នាលី, អ៊ីវ យ៉ាង ហើយនិងមួយភាគបីនៃកម្មករនៅក្រុមហ៊ុនស្វូកូអាហ្នឹង។ សំណួរខ្ញុំសាមញ្ញទេ តើលោកមានបានពិភាក្សាគ្នាជាមួយលោកខៀវ សំផន អំពីការបាត់ខ្លួនទាំងអស់នេះទេ? តើបើតាមលោកយល់នោះ លោក ខៀវ សំផន ស្គាល់លោក អ៊ុន សុកាន, អ៊ុន សុផាន់, លោក តូច ខាំឌឿន, លោក ឌី ផុន ទាំងអស់ហ្នឹងទេ?

[១៤:៣៧:២៦]

**ឆ៖** ខ្ញុំគិតថាលោក ខៀវ សំផន ស្គាល់ៗទាំងអស់ហ្នឹង។ ពីព្រោះពួកគាត់សុទ្ធតែជានិស្សិតនៅប៉ារីស នៅពេលដែលខ្ញុំទាក់ទងជាមួយនឹងផ្ទះខ្មែរនៅបារាំងនោះ។ ខ្ញុំបានឃើញលោក ខៀវ សំផន ឡើងវិញនៅឆ្នាំ៩០, ៩២ ក៏ប៉ុន្តែខ្ញុំមិនបាននិយាយជាមួយគាត់អំពីបញ្ហានៃសម័យឆ្នាំ៧៥, ៧៩នោះទេ។ យើងនិយាយជាសំខាន់អំពីបញ្ហាគ្រួសារ ហើយនិងបញ្ហាបុគ្គលផ្ទាល់ខ្លួន។ បន្ទាប់មកទៀត ខ្ញុំគិតថាវាមិនសមរម្យទេក្នុងការសួរគាត់អំពីសម័យកាលកម្ពុជាប្រជាធិបតេយ្យនោះ។ ពីព្រោះថារឿងរ៉ាវនោះវាចប់ទៅហើយ។ ដូច្នេះខ្ញុំចាំឲ្យស្ថានភាពហ្នឹងវាស្ងាត់បន្តិចសិន។ ពីព្រោះថាមានការរៀបរាប់នៅក្នុងកាសែត នៅក្នុងសៀវភៅ មានការនិយាយរឿងរ៉ាវជាច្រើនដែលទាមទារឲ្យមានការស្ងប់ស្ងៀមជាជាងការពុះកញ្ជ្រោលនោះ។

[១៤:៣៨:៥៣]

**ស៖** លោកសាក្សី លោកមិនដឹងច្បាស់ថាអ្វីដែលយើងចាប់អារម្មណ៍បំផុតនៅទីនោះ គឺថារយៈពេលកម្ពុជាប្រជាធិបតេយ្យនុ៎ងហើយ។ ដូច្នេះប្រហែលជាលោកអាចមានការខ្មាស់អៀនក្នុងការសួរលោកខៀវ សំផន អំពីរបបនោះ។ ក៏ប៉ុន្តែចំពោះយើង គឺយើងចាប់អារម្មណ៍ទៅលើរបបនោះ។ តើលោកដឹងទេថាតើលោក ខៀវ សំផន នោះមាននិយាយអំពីគ្រួសាររបស់គាត់ប្រាប់លោកទេ លោកស្គាល់ម្ដាយបងប្អូនរបស់គាត់ លោកអាចដឹងអំពីចំណុចនេះទេ?

**ឆ៖** បាទ ក្នុងការពិភាក្សាគ្នានៅក្នុងឆ្នាំ៩០ហ្នឹង យើងនិយាយអំពីបញ្ហាគ្រួសារ ហើយគាត់បានប្រាប់ខ្ញុំថា គាត់រស់នៅឆ្ងាយ គឺថាពីម្ដាយ ពីបងប្អូនរបស់គាត់ ហើយគាត់មិនសូវបានជួបគ្នាទេ មិនងាយនឹងជួបជុំគ្នាទេ។

**ស៖** គាត់មានបញ្ជាក់ថាពួកគាត់ទាំងអស់នុ៎ងនៅឯណាទេ ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យនិងបងប្អូនក្រុមគ្រួសារគាត់នៅឯណាទេ?

[១៤:៤០:១៣]

**ឆ៖** ខ្ញុំអត់សួរសំណួរហ្នឹងទេ ដូច្នេះខ្ញុំអត់ដឹងលម្អិតអំពីចំណុចនេះទេ។ ប៉ុន្តែអ្វីដែលខ្ញុំដឹងខ្ញុំយល់នោះ គឺថាគ្រួសាររបស់ប្រមុខរដ្ឋទាំងពីរ ទាំងនរោត្តម សីហនុ ដែលជាប្រជាមុខរដ្ឋទី១ ហើយនិង ខៀវ សំផន ដែលជាប្រមុខរដ្ឋទី២នោះ គ្រួសារគាត់ហ្នឹងគឺថាក៏មិនខុសពីអ្នកដទៃដែរ។ ពីព្រោះថាក្រុមគ្រួសាររបស់សម្ដេច សីហនុ នោះគឺថាគាត់បាត់បង់កូនចៅដល់ទៅប្រហែល១៤នាក់ បាត់បង់បង -- ហើយបង

ប្អូនថ្លៃគាត់ដូចជាស៊ីសុវត្ថិជាដើមនុ៎ង។ ហើយនៅក្នុងពេលដែលលោក ខៀវ សំផន ឡើងជាប្រមុខរដ្ឋនោះ គឺក្រុមគ្រួសាររបស់គាត់នុ៎ងក៏មិនមានស្ថានភាពអីល្អប្រសើរដែរ គឺដូចតែអ្នកដទៃអីចឹង។

**សៈ** តើលោកអាចប្រៀបធៀបអំពីឋានៈរបស់ នរោត្តម សីហនុ នៅពេលជាប្រមុខរដ្ឋទី២ និងលោក ខៀវ សំផន ជាប្រមុខរដ្ឋទី២នេះ? លោកដឹងទេថាតើលោក ខៀវ សំផន នៅតំណែងនៅក្នុងគណៈមជ្ឈិមដែរឬទេនៅសម័យនោះ?

[១៤:៤១:៣២]

**ផៈ** ខ្ញុំដឹងថាអ្នកទាំងពីរជាប្រមុខរដ្ឋ ហើយនៅក្នុងប្រទេសកុម្មុយនីស្តនោះ គឺប្រមុខនុ៎ងតួនាទីត្រឹមតែតំណាងទេ ដូចជាគ្មានអំណាចអ្វីប៉ុន្មានទេ។ ឧទាហរណ៍ដូចជាចិនជាដើម លោកប្រធានាធិបតី យូ ស៊ាវជី ត្រូវបានកម្ទេចដោយ ម៉ៅ សេទុង ក្នុងបដិវត្តន៍វប្បធម៌។ ហើយសម័យនេះ នៅឥឡូវនេះនៅកូរ៉េខាងជើងនោះ យើងស្គាល់ គីម ជុងអ៊ុន ច្បាស់ណាស់ អ្នកណាក៏ដឹងដែរ។ ហើយមាន គីម យុងណាម ដែលជាប្រមុខរដ្ឋនោះតាំងពីឆ្នាំ៩៨មក ហើយនៅក្នុងរដ្ឋធម្មនុញ្ញកូរ៉េខាងជើង ក៏ដូចជាក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ គឺថាតួនាទីរបស់ប្រធានគណៈប្រធានរដ្ឋនោះ គឺគ្រាន់តែជាតួនាទីតំណាងក្នុងការទទួលឯកអគ្គរដ្ឋទូតដែលចូលមកប្រទេសនោះ។ ហើយគឺលេខាបក្សអីចឹងទេ អ្នកកាន់អំណាចនោះ។ ដូច្នេះចំពោះនៅគណៈមជ្ឈិម ឬមិននៅនោះ ខ្ញុំអត់ដឹងទេ។

**សៈ** អ្វីដែលលោកឆ្លើយនេះ គឺជាការវិភាគផ្ទាល់ខ្លួន និងជាទូទៅ។ ក៏ប៉ុន្តែតើលោកមានធ្លាប់ពិភាក្សាគ្នាច្បាស់លាស់ដើម្បីឲ្យដឹងអំពីតួនាទីរបស់លោក ខៀវ សំផន ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យដែរឬទេ? លោកមានព័ត៌មានផ្តល់ជូនអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងចំណុចនេះទេ? យើងបានរៀបចំសវនាការជាច្រើនហើយ ហើយយើងដឹងថាមានអ្វីកើតឡើងនោះ។

[១៤:៤៣:១៩]

**ផៈ** ខ្ញុំមិនដឹងច្បាស់ទេ ខ្ញុំមិនបានពិភាក្សាស៊ីជម្រៅអំពីចំណុចនេះទេ។ ខ្ញុំស្គាល់លោក ខៀវ សំផន តាំងពីឆ្នាំ១៩៥៧ ក៏ប៉ុន្តែស្គាល់អំពីលម្អិតពីជីវិតរបស់គាត់នៅចន្លោះឆ្នាំ៧៥ និង៧៩នោះខ្ញុំមិនដឹងទេ។ ដូច្នេះខ្ញុំក៏មិនអាចឆ្លើយអ្វីពាក់ព័ន្ធនឹងចំណុចនេះទេ។

**សៈ** ក្នុងសក្ខីកម្មរបស់លោក លោកសាក្សី លោកបានឆ្លើយថាលោកមានការភ្ញាក់ផ្អើលតាមរយៈការអានរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ។ ជាពិសេសនោះគឺ នៅពេលដែលលោកអាននូវមាត្រា៣នៃរដ្ឋធម្មនុញ្ញ។ តើលោកមានចាំអំពីមាត្រា៣នៃកម្ពុជាប្រជាធិបតេយ្យ -- នៃរដ្ឋធម្មនុញ្ញកម្ពុជា

ប្រជាធិបតេយ្យទេ?

**ឆ:** ខ្ញុំមិនចាំច្បាស់ទេ។

**ស:** គឺថាមាត្រាហ្នឹងនិយាយអំពីវប្បធម៌។

**ឆ:** បាទ បើលោកចៅក្រមប្រាប់ខ្ញុំ ខ្ញុំចាំបន្តិចហើយ។ រដ្ឋធម្មនុញ្ញនោះគឺចែងថា វប្បធម៌ចាស់នោះ ដែលជាអរិយធម៌ វប្បធម៌ពីមុននោះគឺជាអរិយធម៌អាវ៉ាសែ ប្រតិកិរិយា មានអំពើហិង្សា។ ដូច្នេះជាវប្បធម៌ពីមុនពេលដែលទទួលបានអំណាចរបស់កម្ពុជាប្រជាធិបតេយ្យនោះ។ ខ្ញុំចង់និយាយអំពីមាត្រា១១ ដែលនិយាយអំពីតួនាទីរបស់ប្រមុខរដ្ឋ។

[១៤:៤៥:០៣]

**ស:** លោកសាក្សីខ្ញុំមានសំណួរផ្សេងទៀត។ តើលោកមានបានពិភាក្សាជាមួយលោក ខៀវ សំផន អំពីតួនាទីរបស់គាត់ពាក់ព័ន្ធទៅនឹងការតាក់តែងរដ្ឋធម្មនុញ្ញដែរឬទេ? លោកមានបានស្តាប់មតិអត្ថាធិប្បាយរបស់គាត់នៅពេលដែលគាត់ធ្វើបទឧទ្ទេសនាមអំពីរដ្ឋធម្មនុញ្ញជូនប្រជាជាតិកម្ពុជា។ យើងមានរបាយការណ៍គួរឲ្យចាប់អារម្មណ៍ពាក់ព័ន្ធទៅនឹងចំណុចនេះគឺឯកសារ E3/259។

**ឆ:** ខ្ញុំអត់មានព័ត៌មានលម្អិតទេ។ អ្វីដែលខ្ញុំដឹងនេះគ្រាន់តែជាការកត់សម្គាល់ជាទូទៅគឺថាសុន្ទរកថារបស់ប្រមុខរដ្ឋមិនត្រូវបានសរសេរដោយប្រមុខរដ្ឋផ្ទាល់ទេ។ ខ្ញុំជឿថាបើសុន្ទរកថារបស់ ស្តេចអង់គ្លេសក៏ដោយត្រូវសរសេរដោយរដ្ឋាភិបាល មិនមែនដោយស្តេចខ្លួនឯងជាអ្នកសរសេរទេ។ ហើយក្នុងប្រទេសផ្សេងៗទៀតនោះក៏អ៊ីចឹងដែរ។ ជាពិសេសទៅទៀតនោះ គឺក្នុងប្រទេសកុម្មុយនីស្តគឺថាប្រមុខរដ្ឋនោះត្រូវបាន -- ដោយលេខាបក្ស ហើយនិងរដ្ឋាភិបាលទេជាអ្នកគ្រប់គ្រងនោះ។

[១៤:៤៦:២៥]

**ស:** ខ្ញុំមិនដឹងថាតើស្តេចស្រីអង់គ្លេសនិយាយយ៉ាងម៉េចនោះទេ ក៏ប៉ុន្តែអ្វីដែលមាននៅក្នុងឯកសារ E3/213 នោះគឺERN 00625798។ គឺជំពូកបី និយាយអំពីរបបវប្បធម៌គឺរបបវប្បធម៌កម្ពុជាប្រជា-ធិបតេយ្យ។ គឺជាប្រជាជាតិចម្រើននិយម ហើយនិងស្អាតស្អំ។ ហើយនេះជាចំណុចមួយដែលបង្ហាញពីស្ថានភាពពិតប្រាកដរបស់យើងនាពេលបច្ចុប្បន្ន។ មិនមានចោរ មិនមានពេស្យាចារនៅក្នុងប្រទេស។ វប្បធម៌យើងមានលក្ខណៈជាតិនិយមគឺជាវប្បធម៌ផ្ទាល់របស់យើង។ យើងប្រឆាំងទៅនឹងវប្បធម៌ផ្សេងៗទៀតដែលពុករលួយ និងប្រតិកិរិយា។ ហើយដែលមានពួកចក្រពត្តិនិយមមានពួកនាយទុននិយមនៅប្រទេសកម្ពុជា។ រឿងដែលផ្សាយអំពីវប្បធម៌អាវ៉ាសែនោះគឺបានបាត់បង់អស់ហើយ។ យើងស្លៀកពាក់

ស្អាតស្អំទៅតាមវប្បធម៌និងទៅតាមមធ្យោបាយដែលយើងអាចធ្វើទៅបាន។ យើងមិនធ្វើតាមដោយងងឹតងងុល យើងមិនចម្លងអំពីវប្បធម៌របស់ពួកចក្រពត្តិដូចពួកបនក្បត់ លន់ នល់ ទេ។ យើងមើលអំពីអ្វីដែលពួក លន់ នល់ ធ្វើចំពោះអ្នកគាំទ្ររបស់ពួកគេ។ ខ្ញុំមិនដឹងថាតើគួររៀបរាប់បែបណានោះទេ។ ផ្ទះមួយៗនោះគឺអត់មានលក្ខណៈជាតិទេ។ ហេតុនេះហើយបានជាយើងប្រឆាំងទៅនឹងវប្បធម៌ប្រភេទនេះ។ ប្រសិនបើ យើងអនុញ្ញាតឲ្យវប្បធម៌ពុករលួយនៅក្នុងប្រទេសយើងនោះវានឹងបំផ្លាញទៅដល់កិច្ចខិតខំប្រែងការពារ ប្រទេសជាតិ និងការពារឯករាជ្យម្ចាស់ការរបស់យើងហើយ។ ដូច្នេះយើងដាច់ខាតយើងត្រូវតែបដិសេធនូវវប្បធម៌ពុករលួយប្រតិកិរិយា ចក្រពត្តិ ក៏ប៉ុន្តែយើងត្រូវតែពង្រឹងគោលជំហររបស់ប្រជាជនយើង។

[១៤:៤៩:០៨]

កាលពីមុនប្រជាជនយើងមិនបាន -- បានព្យាយាមតស៊ូលុបបំបាត់វប្បធម៌ទាំងអស់នោះហើយ។ ឥឡូវនេះយើងនៅតែបន្តតស៊ូប្រយុទ្ធប្រឆាំងដើម្បីរក្សានូវវប្បធម៌ជាតិនិងប្រជាជនរបស់យើង។ តើចំណុចនេះវាត្រូវគ្នាទៅនឹងអ្វីដែលលោក ខៀវ សំផន ប្រាប់លោកនៅប៉ារីស ឬក៏នៅពេលដែលលោកមកកម្ពុជានៅទសវត្សរ៍ឆ្នាំ៦០ដែរឬទេ?

**ឆ៖** ពាក់ព័ន្ធទៅនឹងឃ្លាដំបូងគឺការចង់បានវប្បធម៌ប្រជាជនជាតិនិយមនោះគឺបាទ។ ក៏ប៉ុន្តែ ខ្ញុំឮគាត់រិះគន់អំពីនយោបាយហើយនិងអំណាចផ្តាច់ការរបស់សម្តេច សីហនុ។ នៅពេលហ្នឹងទាំងគាត់ជាប្រមុខរដ្ឋ និងជាប្រមុខរដ្ឋាភិបាល។ ក៏ប៉ុន្តែ ខ្ញុំមិនឮគាត់និយាយអំពីការរិះគន់ប្រឆាំងទៅនឹងវប្បធម៌កម្ពុជាបុរាណនោះទេ។ នៅពេលដែលគាត់នៅទីក្រុងប៉ារីស រដ្ឋាភិបាល លន់ នល់ នោះមិនទាន់កាន់ចូលកាន់អំណាចទេ គឺពេលនោះរដ្ឋាភិបាល សីហនុ។ ហើយនៅក្នុងចន្លោះឆ្នាំ៦០-៧០ ដែលរដ្ឋាភិបាល លន់ នល់ ត្រូវបានលើកបន្តុបដោយអាមេរិកនោះ គឺថាមានបង្កឲ្យមានសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំយល់ពីចំណុចនេះច្បាស់ណាស់ថា យើងរិះគន់ពីមុន គឺឆ្នាំ៧០ ឆ្នាំ៧៥ នុ៎ង ដែលជាពេលនោះគឺថាមានបញ្ហាគួរឲ្យរន្ធត់នៅប្រទេសកម្ពុជា គឺថាមានសង្គ្រាមស៊ីវិលផ្ទៃក្នុងផង មានការទម្លាក់គ្រប់បែកពីអាមេរិកាំងផង។

[១៤:៥១:១១]

**សៈ** តើលោក ខៀវ សំផន មានបានប្រាប់លោកថា ហេតុអ្វីបានជាមានភាពចាំបាច់ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងក្រោយពេលរំដោះកម្ពុជាបាននោះ?

**ឆ៖** គាត់មិនដែលនិយាយប្រាប់ខ្ញុំទេ ក៏ប៉ុន្តែខ្ញុំៗមានគំនិតថា ក្នុងឆ្នាំ៧៥ ភ្នំពេញគឺកាត់ផ្តាច់ពីពិភពខាងក្រៅទាំងស្រុង។ ការផ្គត់ផ្គង់ស្បៀងអាហារទាំងអស់នោះ គឺតាមរយៈផ្លូវអាកាស ឬតាមយន្តហោះ។ ហើយនៅពេលដែលពួកខ្មែរក្រហមរាប់ពាន់នាក់ដែលវាយយកទីក្រុងភ្នំពេញនោះ បាននោះគឺថាពួកគេមិនអាចផ្តល់ស្បៀងដល់ប្រជាជនបានទេ។ ដូច្នេះការជម្លៀសចេញហ្នឹង គឺធ្វើក្នុងស្ថានភាពមួយអាណោចអាធ័មមែន។ ក៏ប៉ុន្តែវាជាភាពចាំបាច់ខាងផ្នែកសេដ្ឋកិច្ចដែលត្រូវតែជម្លៀសចេញ។

**ស៖** ខ្ញុំយល់ថា លោកគិតថាការជម្លៀសចេញនេះ គឺជាភាពចាំបាច់ខាងផ្នែកសេដ្ឋកិច្ច។ នេះជាចម្លើយរបស់លោកមែនទេ?

**ឆ៖** ទីក្រុងត្រូវបានផ្គត់ផ្គង់ស្បៀងតាមរយៈ ទូក កប៉ាល់ ហើយនិងយន្តហោះ។ ហើយចាប់ពេលដែរ ពីពេលដែលខ្មែរក្រហមកាន់អំណាចនោះ មិនមានការផ្គត់ផ្គង់ស្បៀងតាមយន្តហោះ តាមទូកពីវៀតណាម ឬក៏ពីថៃទៀតនោះទេ។ ដូច្នេះប្រជាជនត្រូវតែត្រឡប់ទៅទីជនបទ។ ក៏ប៉ុន្តែខ្ញុំទទួលស្គាល់ថា បើតាមអ្វីដែលខ្ញុំស្តាប់ឮនោះគឺថា ការធ្វើបែបការជម្លៀសនោះ គឺថាស្ថិតក្នុងស្ថានភាពអាណោចអាធ័មមែនទែន។

[១៤:៥៣:០១]

**ស៖** ដូច្នេះអ្វីដែលតាមអ្វីដែលលោកយល់នុ៎ងគឺថាជាចំណុចមួយដែលគេគិតទុកជាមុនហើយ ឬក៏លោកមានការភ្ញាក់ផ្អើលនៅពេលដែលគេនិយាយពីការជម្លៀសនោះ?

**ឆ៖** ការធ្វើនេះ គឺថាមិនឲ្យខ្ញុំភ្ញាក់ផ្អើលណាស់ណាទេ។ ក៏ប៉ុន្តែដូចខ្ញុំនិយាយអ៊ីចឹងគឺថាវាធ្វើឡើងក្នុងលក្ខខណ្ឌមួយដែលវាអាណោចអាធ័ម។

**ស៖** តើលោកដឹងទេថា មានច្បាប់ប៉ុន្មានដែលត្រូវបានអនុម័តដោយសភាតំណាងប្រជាជន? ហើយលោកដឹងថាមានស្ថាប័នតុលាការដំណើរការទេក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ខ្ញុំមិនដឹងទេ លោកដឹងហើយថា នៅ -- ខ្ញុំជាប្រធានខាងផ្នែកហិរញ្ញវត្ថុក្នុងក្រុមហ៊ុនមួយ។ ខ្ញុំមានការងារច្រើនណាស់ ខ្ញុំធ្វើការតាំងពីម៉ោងប្រាំពីរកន្លះ ម៉ោងប្រាំបី ហើយម៉ោងប្រាំបីយប់អីណោះបានចប់នោះ។ ខ្ញុំមិនធ្វើការ៣៥ម៉ោងដូចឥឡូវនេះទេ។ ដូច្នេះខ្ញុំយកចិត្តទុកដាក់ទៅលើតែការងាររបស់ខ្ញុំទេ។ ហើយខ្ញុំមានព័ត៌មានតិចតួចណាស់។ ដូច្នេះ ខ្ញុំមិនដឹងច្បាស់ពីអ្វីដែលបានកើតឡើងនៅប្រទេសកម្ពុជានៅសម័យនោះទេ។

**ស៖** អម្បាញ់មិញនេះ យើងនិយាយអំពី អ៊ុន សុកាន, អ៊ុន សុផាន់។ តើលោកស្គាល់បុគ្គលម្នាក់

ឈ្មោះ អ៊ិន សុភាព?

**ឆ៖** បាទ ខ្ញុំស្គាល់គាត់ ខ្ញុំបានជួបគាត់។

[១៤:៥៤:៤១]

**ស៖** តើលោកមានអានសៀវភៅមួយដែលសរសេរដោយលោក អ៊ិន សុភាព ដែលមានចំណងជើងថា "*ខៀវ សំផន: អាក្រង់ឌី ដេវេអែល*"។ លោកមានបានអានសៀវភៅហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងអំពីសៀវភៅហ្នឹងទេ។ ក៏ប៉ុន្តែខ្ញុំគិតថា ខ្ញុំនឹងចាប់អារម្មណ៍ ប្រហែលជាខ្ញុំអាននៅពេលខាងមុខ។

**ស៖** ខ្ញុំក៏អ៊ីចឹងដែរ។ ដូច្នេះ ខ្ញុំគិតថាខ្ញុំមិនមានអ្វីទៀតទេ ឯកសារនេះនឹងដាក់ចូលទៅក្នុងសំណុំរឿងនាពេលឆាប់មុខនេះ ហើយនិងអាចមានការចោទសំណួរផ្សេងៗទៀតពាក់ព័ន្ធនឹងឯកសារនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ហើយសូមអរគុណលោកសាក្សី ដែលបានសហការឆ្លើយសំណួររបស់ខ្ញុំ។

**លោក ហ្វីលីព ហ្សំល្យាន-ហ្គោហ្វ្រែស៖**

បាទ សូមអរគុណលោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី។ អរគុណលោកចៅក្រម ឥឡូវនេះដល់ពេលសម្រាកហើយ សាក្សីយើងសម្រាក២០នាទី ចាប់ពីពេលនេះតទៅម៉ោងនៅកម្ពុជានេះ គឺរហូតដល់ម៉ោងបីនិងដប់ប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥៦ នាទី ដល់ម៉ោង ១៥:១៦ នាទី)*

[១៥:១៦:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្តីលោក ហ្ស៊ែល្យាន ហ្វីលីព ហ្គោហ្វ្រេ!

**លោក ហ្វីលីព ហ្ស៊ែល្យាន-ហ្គោហ្វ្រែសៈ**

បាទ ជម្រាបសួរលោកប្រធាន ខ្ញុំត្រៀមលក្ខណៈរួចអស់ហើយ។

**ប្រធានអង្គជំនុំៈ**

បាទ អរគុណ។ បាទជាបន្តនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯលៈ**

អរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហភាគីទាំងអស់ជាទីគោរព។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯលៈ**

**សៈ** ជម្រាបសួរលោកសាក្សី! ខ្ញុំឈ្មោះ លោក វាំងសង់ ដេវីល ខ្ញុំតំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំមានសំណួរមួយចំនួនចោទទៅកាន់លោក ហើយសំណួរមួយចំនួននោះជាសំណួរបន្តចេញពីសំណួររបស់លោកចៅក្រម ឡាវែន៍ ដែលសួរលោកអម្បាញ់មិញនេះ។

[១៥:១៨:០៩]

បាទ ខ្ញុំមានសំណួរដំបូងមួយចំនួនលិខិតលាយលក្ខណ៍អក្សររបស់លោកដែលមានលេខ E190/2.5 ដែលចុះថ្ងៃទី១៥ តុលា ២០១០ គឺថាចេញពេលមួយខែក្រោយពេលចេញដីកាដំណោះស្រាយ។ តើលោកអាចជម្រាបតុលាការបានដែរឬទេ ដែលថាគឺលោកជាអ្នកមានគំនិតផ្តួចផ្តើមក្នុងការទាក់ទងក្រុមការងារការពារលោក ខៀវ សំផន ដើម្បីសរសេរលិខិតគាំទ្រលោក ខៀវ សំផននេះ ឬក៏ខាងការពារក្តីលោក ខៀវ សំផន ទេដែលទាក់ទងលោក ដើម្បីឲ្យលោកផ្តល់សក្ខីកម្ម ដើម្បីគាំទ្រលោក ខៀវ សំផន?

**លោក ហ្វីលីព ហ្ស៊ែល្យាន-ហ្គោហ្វ្រែសៈ**

**ឆៈ** បាទ អង្កាល់ណោះខ្ញុំមានទំនាក់ទំនងជាលោកមេធាវី ហ្សាក់ វែកហ្សេស ដែលបានស្នើឲ្យខ្ញុំផ្តល់ព័ត៌មានមួយចំនួនដែលខ្ញុំដឹងទាក់ទងទៅនឹងពីប្រទេសកម្ពុជា ហើយនិងទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។ ហើយបន្ទាប់មកទៀត ខ្ញុំក៏ស្នើសុំផ្តល់សក្ខីកម្មដើម្បីគាំទ្រលោក ខៀវ សំផន។

**សៈ** បាទ សូមអរគុណ។ បើថាចន្លោះថ្ងៃ១៥ តុលា ២០១០ ហើយនិងសវនាការយើងនេះគឺថា

ជាពិសេសគឺថារយៈពេលប៉ុន្មានខែចុងក្រោយនេះ តើលោកមានទំនាក់ទំនងជាមួយនឹងក្រុមមេធាវីលោក ខៀវ សំផន ដែរឬទេ?

**ឆ៖** សប្តាហ៍មុនខ្ញុំបានជួបលោកមេធាវី វែកគែន ដើម្បីឲ្យដឹងអំពីសវនាការយើងថ្ងៃនេះ ការប្រព្រឹត្តទៅនៃសវនាការយើងនេះ។ ហើយអ៊ីចឹងគឺគ្រាន់តែចង់ពីដំណើរការសវនាការយើងនេះទេ ខ្ញុំជួបគាត់នោះ។

[១៥:២០:១០]

**ស៖** បាទសូមអរគុណ។ មានសំណួរមួយទៀត។ បាទ ខ្ញុំអានសំបុត្រគាំទ្ររបស់លោកនេះ លោកនិយាយថា លោកបានចន្លោះឆ្នាំ៥៧, ៥៩ នោះលោកជួបលោកខៀវ សំផន ជាញឹកញាប់។ ហើយបន្ទាប់មកទៀតឆ្នាំ៩០, ៩២ផងដែរ។ ហើយពី២០០៥-២០០៦ ក៏លោកបានទៅស្នាក់នៅផ្ទះគាត់ផងដែរ។ តើលោកអាចចាត់ទុកថាទំនាក់ទំនងរវាងលោក ហើយនិងគាត់នេះជាទំនាក់ទំនងមិត្តភាព?

**ឆ៖** នេះគឺជាទំនាក់ទំនងមិត្តភាពពិតប្រាកដហើយ។

**ស៖** បាទអ៊ីចឹង គឺថាដោយសារលោកមានទំនាក់ទំនងជាមិត្តភាពនេះហើយ ឬដោយសារមានអនុស្សាវរីយ៍ជាមួយគ្នានេះហើយដែលលោកយល់ព្រមធ្វើផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ ហើយនិងដោយផ្ទាល់មាត់ដើម្បីគាំទ្រគាត់នេះ?

[១៥:២១:០៩]

**ឆ៖** ខ្ញុំអាចនិយាយបានថាទំនាក់ទំនងមិត្តភាពយើងនេះ គឺថាវាមានជាមូលដ្ឋាន គឺខ្ញុំគោរពសរសើរគាត់។ លោក ខៀវ សំផន ដែលខ្ញុំស្គាល់គាត់នៅទីក្រុងប៉ារីស ហើយក្រោយមកទៀតខ្ញុំបានជួបគាត់នៅប្រទេសកម្ពុជា ហើយខ្ញុំក៏យល់ពីអត្តចរិតរបស់គាត់ចំពោះប្រទេសគាត់។

**ស៖** អ៊ីចឹងយើងអាចនិយាយបានថា នៅពេលដែល ខៀវ សំផន ចូលព្រៃនៅឆ្នាំ១៩៦៧ ដែលជារយៈពេលដែលលោកបានចាកចេញពីប្រទេសកម្ពុជា កាលនោះលោកនៅប្រទេសកម្ពុជាដែរ។ ហើយរហូតដល់ថ្ងៃទី១៧ មេសា ៧៥ តើចន្លោះពីឆ្នាំ៦៧ ដល់៧៥នេះលោកមានទំនាក់ទំនងផ្ទាល់ជាមួយលោក ខៀវ សំផន ទេ?

**ឆ៖** នៅពេលដែលគាត់ចាកចេញពីទីក្រុងភ្នំពេញដើម្បីចូលព្រៃនៅឆ្នាំ៦៧នេះ កាលណោះខ្ញុំនៅប្រទេសម៉ាឡេស៊ីទេ ហើយបន្ទាប់មកទៀត ខ្ញុំពុំមានទំនាក់ទំនងដោយផ្ទាល់ជាមួយគាត់នោះទេ។ គឺថារហូតដល់ឆ្នាំ៩០ ឯណោះ។

[១៥:២២:៣០]

**ស៖** បាទសូមអរគុណ។ បើសិនខ្ញុំយល់មិនច្រឡំទេ គឺថាលោកមានទំនាក់ទំនងជាមួយគាត់ប្រហែលជា២៣ឆ្នាំ។ ហើយក្នុងរយៈពេលនេះ លោកពុំមាន -- គឺថារយៈពេល២៣ឆ្នាំ គឺថាលោកអត់មានបានទំនាក់ទំនងជាមួយគាត់ទេ ឬក៏ថាបើមានក៏មានតិចតួចដែរ។ អ៊ីចឹងលោកមិនដឹងថា គាត់មានតួនាទីអ្វី សកម្មភាពអ្វី ហើយនិងគោលជំហរមនោគមន៍វិជ្ជាអ្វីទេ ហើយជាពិសេសហ្នឹងគឺថាលោកក៏មិនដឹងថាគាត់មានជំនឿជឿជាក់ ឬក៏គំនិតនយោបាយរបស់គាត់នោះប្រែប្រួលយ៉ាងម៉េចទេធៀបទៅនឹងពេលដែលលោកស្គាល់គាត់ហ្នឹង?

**ឆ៖** បាទ លោកសហព្រះរាជអាជ្ញា ហ្នឹងត្រឹមត្រូវហើយ។ ព្រោះថាខ្ញុំពុំមានទំនាក់ទំនងអ្វីជាមួយគាត់នោះទេក្នុងរយៈពេលហ្នឹងដើម្បីឲ្យដឹងថាគាត់វិវត្តន៍យ៉ាងម៉េច យ៉ាងណានោះទេ។

**ស៖** បាទនៅក្នុងសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់លោកនេះ គឺលោកបានធ្វើការកត់សម្គាល់ហើយនិងការវិភាគផ្ទាល់ខ្លួន គឺថាចាប់ពីចំណុចទី៩ ដែលនិយាយអំពីមូលហេតុដែលលោក ខៀវ សំផន ត្រូវបានតែងតាំងជាប្រមុខរដ្ឋ ហើយនិងតួនាទីជាប្រមុខរដ្ឋនៅក្នុងរដ្ឋកុម្មុយនីស្ត ហើយនិងសេចក្តីសន្និដ្ឋានរបស់លោកដែលលោកធ្វើការសន្និដ្ឋានដូចជាលោកជាចៅក្រម គឺថាលោកជំនឿជឿជាក់ផ្ទាល់ខ្លួនរបស់លោក។ អ៊ីចឹងទាក់ទងទៅនឹងការវិភាគទៅលើរយៈពេលដែលលោកពុំមានទំនាក់ទំនងផ្ទាល់ជាមួយលោក ខៀវ សំផន ដោយសារលោកមិននៅប្រទេសកម្ពុជានោះ តើលោកយល់ស្របដែរឬទេថាការវិភាគរបស់លោកនេះគឺជាការវិភាគដោយ គេហៅថាពុំមានសត្យានុម័ត គឺជាការសន្និដ្ឋាន?

[១៥:២៤:៣២]

**ឆ៖** បាទនេះគឺជាការធ្វើសន្និដ្ឋានរបស់ខ្ញុំ ដោយសារខ្ញុំស្គាល់លោក ខៀវ សំផន នៅក្នុងអតីតកាល ហើយនិងដោយខ្ញុំឈរទៅលើអ្វីដែលខ្ញុំសង្កេតឃើញនៅឆ្នាំ២០០០នេះ។

**ស៖** អ៊ីចឹងដើម្បីឲ្យច្បាស់ហ្នឹង ខ្ញុំសូមលើកសំណួររបស់លោកមួយ។ លោកបានសរសេរដូចតទៅនេះ គឺថានៅក្នុងឯកសាររបស់លោកគឺថា ឯកសារ E190/2.5, ERN ជាភាសាបារាំងគឺ 00809329 ហើយជាភាសាខ្មែរគឺ 00907765។ បាទលោកសរសេរដូចតទៅទនេះ ខ្ញុំសូមដកស្រង់ "វាប្រហែលជា ខៀវ សំផន ដែលមិនមែនជាសមាជិកគណៈកម្មការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាពុំមានអំណាចច្រើនណាស់នោះទេ ហើយដូចក៏ជានរោត្តម សីហនុ ដែរគឺថាចន្លោះឆ្នាំ៧៥ ដល់៧៦"។ សូមបញ្ចប់ការដក។ បាទមានអំណាចតិចជាង សីហនុ ទៅទៀត។ ខ្ញុំចង់ដឹងថាតើលោកដឹងថា សីហនុ

ហ្នឹងជាសមាជិកនៃគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ ហើយបានចូលរួមកិច្ចប្រជុំនៅគណៈអចិន្ត្រៃយ៍ដែរ ឬទេ?

[១៥:២៦:០៩]

**ឆ៖** ខ្ញុំមិនដឹងទេ ខ្ញុំមិនដឹងថានរោត្តម សីហនុ គាត់ធ្វើអ្វីនោះនោះទេ មានទំនាក់ទំនងជាមួយអ្នកណាអ្នកណីនោះទេចន្លោះពី៧៥-៧៦។ ក៏ប៉ុន្តែខ្ញុំដឹងថាគាត់ទៅប្រទេសកម្ពុជាក្នុងឆ្នាំ ចន្លោះឆ្នាំ៧០-៧៥ ហើយកាលណោះគាត់ស្នាក់នៅទីក្រុងប៉េកាំង ក៏ប៉ុន្តែយ៉ាងហោចណាស់គឺថាគាត់បានទៅប្រទេសកម្ពុជាម្តងដែលមានរូបថតទៀតផង ពេលនោះគាត់ជួប ប៉ុល ពត, ខៀវ សំផន។ នេះបើតាមរយៈរូបថតដែលខ្ញុំបានឃើញបាទ។

**ស៖** បាទអម្បាញ់មិញលោកនិយាយអំពី សិរិមតៈ ដែលលោកនិយាយថា សិរិមតៈ នេះជាម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនរបស់លោកនៅប្រទេសកម្ពុជា។ តើលោកធ្លាប់ឮសុន្ទរកថា ឬក៏អានសុន្ទរកថាលោក ខៀវ សំផន នៅអំឡុងថ្ងៃ១៧ មេសា ៧៥ ឬក៏មុំថ្ងៃហ្នឹងដែលនិយាយអំពីជនក្បត់ ឬក៏ជនមហាក្បត់ ដែល សិរិមតៈ ក៏ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សមហាក្បត់ហ្នឹងដែរ?

**ឆ៖** ខ្ញុំមិនដឹងពីសុន្ទរកថានេះទេ ហើយថាទោះបីធ្វើសុន្ទរកថារបស់លោក ខៀវ សំផន ឬក៏អ្នកណាផ្សេងទៀតនោះក៏ដោយ។ ប៉ុន្តែ សិរិតមៈ បានចូលរួមជាមួយ លន់ នល់ ក្នុងការទម្លាក់សម្តេច សីហនុ ពីអំណាចកាលខែមីនា ឆ្នាំ១៩៧០។

**ស៖** បាទ អម្បាញ់មិញពេលលោកឆ្លើយទៅលោកចៅក្រម ឡាវ៉ែន៍ លោកនិយាយថា ខៀវ សំផន មិនដែលធ្លាប់បាននិយាយប្រាប់លោកថា គាត់ធ្លាប់ជាសមាជិក ឬក៏ជាប្រធានវង់ម៉ាក្សស៊ីសទេ ឬក៏សមាជិកបក្សកុម្មុយនីស្តបារាំងនោះទេ។ តើរឿងទាំងអស់នេះលោកដឹងពេលក្រោយមកហើយទេ ថាលោក ខៀវ សំផន នោះជាសមាជិកបក្សកុម្មុយនីស្ត ហើយនិងជាវង់ម៉ាក្សស៊ីសនេះ ឬក៏លោកទើបតែដឹងអម្បាញ់មិញនេះទេ?

[១៥:២៨:២៩]

**ឆ៖** ខ្ញុំសង្ស័យដែរ កាលនោះនោះ ក៏ប៉ុន្តែឥឡូវនេះខ្ញុំច្បាស់ហើយ ដឹងច្បាស់ហើយ។

**ស៖** ដោយសារលោកសង្ស័យនោះ អ៊ីចឹងតើទាក់ទងនឹងទំនាក់ទំនងមិត្តភាពរបស់លោកជាមួយលោក ខៀវ សំផន នោះលោកមានដែលធ្លាប់សួរខ្លួនឯងទេ ថាលោកដឹងថាលោកស្គាល់ច្បាស់លាស់តែម្តង ឬក៏លោកមានគិតថាប្រហែលជាមានកន្លែងណាមួយដែលលោក ខៀវ សំផន លាក់បាំងមិនឲ្យ

លោកដឹង?

**ឆ៖** ខ្ញុំជួប ខៀវ សំផន ហើយសំណេះសំណាលជាមួយលោក ខៀវ សំផន មួយចំនួនដែរ។ ដូចខ្ញុំជម្រាបជូនលោកហើយអ៊ីចឹង គឺថាពេលដែលខ្ញុំជួបគាត់ទាំងប៉ុន្មានដងនោះ ធ្វើឲ្យខ្ញុំស្ងើចសសើរគាត់ ហើយខ្មែរៗដែលនៅប៉ារីសពេលនោះនោះ គឺថាគេក៏គោរពគាត់ដែរ ហើយពេលដែលខ្ញុំជួបគាត់នៅប្រទេសខ្មែរនេះ ពេលដែលគាត់ឃើញថារបៀបធ្វើនយោបាយរបស់គាត់ របៀបរស់នៅរបស់គាត់។ ហើយខ្ញុំ ខ្ញុំចាំថាលោក ខៀវ សំផន ជាតំណាងរាស្ត្ររបស់បក្សសង្គមរាស្ត្រនិយម ហើយក្រោយមក--

**អ្នកបកប្រែ៖**

លោកប្រធានសំឡេងមានបញ្ហាកុងខ្លាំង ស្តាប់អត់បាន។

*(មានបញ្ហាបច្ចេកទេស)*

**អ្នកបកប្រែ៖**

លោកប្រធានឮស្ងួរឡើងៗខ្លាំង អ្នកបកប្រែស្តាប់អត់បាន អត់ឮសំឡេងសាក្សីនិយាយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សុំមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងផ្នែកខាងសោតទស្សន៍មានបញ្ហាបច្ចេកទេស។

[១៥:៣០:២៨]

*(មានបញ្ហាបច្ចេកទេស)*

[១៥:៣១:៤០]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអាចបន្តការតាំងសំណួរដេញដោលចំពោះសាក្សីហើយ ហើយសុំសួរសំណួរចុងក្រោយអំមិញ ព្រោះអំមិញគឺមានបញ្ហាមិនមានការបកប្រែទេដោយសារបច្ចេកទេសនៃសោតទស្សន៍មានបញ្ហា។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាងឯល៖**

**ស៖** បើសិនមិនច្រឡំទេអម្បាញ់មិញនេះ សំណួរចុងក្រោយអម្បាញ់មិញនេះគឺខ្ញុំទទួលបានចម្លើយហើយ។ ខ្ញុំអាចចោទសំណួរបន្តទៅមុខទៀត។ តែបើសិនជាអស់លោកចៅក្រមមិនបានឮចម្លើយទេ

អាចត្រឡប់សួរម្តងទៀតបាន។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីរដ្ឋធម្មនុញ្ញ។ អម្បាញ់មិញលោកបាននិយាយថាលោកភ្ញាក់ផ្អើលដោយសារលោកអានពីវប្បធម៌ ខ្ញុំសូមដកស្រង់នូវទំព័រទី២ របស់លោក, "បាទខ្ញុំឃើញមានការវាយប្រហារទៅលើវប្បធម៌មួយដែលខ្ញុំជ្រួតជ្រាបតាមរយៈការសិក្សារបស់ខ្ញុំនៅសាលាបូព៌ា -- ភាសាបូព៌ា ពោលគឺវប្បធម៌ដែលផ្អែកទៅលើការគោរពចំពោះក្រុមគ្រួសារ ចំពោះសាសនា និងប្រពៃណីទំនៀមទម្លាប់ វប្បធម៌ដែលត្រូវបានមាត្រា៣នៃរដ្ឋធម្មនុញ្ញថ្ងៃទី០៥ មករា ឆ្នាំ ១៩៧៦ នៃកម្ពុជាប្រជាធិបតេយ្យ គាត់ថាគឺជាវប្បធម៌អន់ថយ ប្រតិកិរិយា ហើយវប្បធម៌ដែលត្រូវតែកម្ចាត់នូវវប្បធម៌នោះចោលឲ្យអស់ដាច់ខាត"។ ខ្ញុំដកស្រង់អ្វីមិញនេះ គឺថាលើការភ្ញាក់ផ្អើលរបស់លោក។ អ៊ីចឹងលោកអាចធ្វើការអត្ថាធិប្បាយបានទេ តើដោយហេតុថាប្រពន្ធរបស់លោកជាជនជាតិខ្មែរហើយខ្ញុំចង់ដឹងថាតើមាត្រាទី៣នេះ ដែលលោកបានសរសេរនៅក្នុងកំណត់ហេតុរបស់លោកក្នុងសក្ខីកម្មរបស់លោកដែលលោកថាធ្វើឲ្យលោកភ្ញាក់ផ្អើលខ្លាំងមាត្រា៣ នេះ។

[១៥:៣៤:០០]

**ឆៈ** ខ្ញុំគិតថាខ្មែរក្រហមកាលនោះចង់ផ្លាស់ប្តូរសង្គមទាំងស្រុងតែម្តង។ ខ្ញុំមិនគាំទ្រការធ្វើបដិវត្តន៍បែបហ្នឹងទេ ព្រោះថាវប្បធម៌ខ្មែរដែលមានគឺថាការគោរពប្រជាជនខ្ញុំគាំទ្រគោរពការបណ្តុះបណ្តាលឬការអប់រំ។ អ៊ីចឹងហើយបានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលដែលបានដឹងពីអ្វីដែលបានកើតឡើងនៅក្នុងអតីតកាលព្រោះពេលភ្លាមៗនោះខ្ញុំមិនបានដឹងទេ។ ព្រោះខ្ញុំមិនដឹងពីរដ្ឋធម្មនុញ្ញឆ្នាំ៧៥, ៧៦ នោះទេ គឺថា បួនដប់ឆ្នាំក្រោយមកហើយទេដែលខ្ញុំដឹងពីអ្វីដែលកើតឡើងនោះ។ ហើយនៅពេលនោះហើយដែលខ្ញុំភ្ញាក់ផ្អើលមែនទែន។

**សៈ** លោកក៏បាននិយាយអំពីសាសនាដែរ បន្ថែមពីលើគ្រួសារ និងប្រពៃណីវប្បធម៌អីជាដើមនេះ។ បាទ នេះឥឡូវនេះ ខ្ញុំសូមអានចំណុចនេះឡើងវិញ គឺថា "មាត្រាទី២០ នៃរដ្ឋធម្មនុញ្ញដែលចែងនៅទីនេះ ពលរដ្ឋមួយៗនៃប្រទេសកម្ពុជាត្រូវមានសិទ្ធិ មានជំនឿ ហើយសាសនា ហើយនិងក៏មានសិទ្ធិមិនជឿ ហើយមិនជឿលើសាសនាផងដែរ។ ហើយហាមដាច់ខាតនៅសាសនាប្រតិកិរិយាដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យនិងប្រជាជនកម្ពុជា"។ បាទ សូមបញ្ចប់ការដកស្រង់។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយពីឯកសារដែលខ្ញុំបានដកស្រង់អំមិញ -- ដោយចៅក្រម ឡាវែន៍ គឺឯកសារ E3/273 មិនមែនជាសុន្ទរកថាទេ ក៏ប៉ុន្តែជាសេចក្តីសង្ខេបរបស់ -- កំណត់ហេតុរបស់លោក ខៀវ សំផន ថ្ងៃទី១៤ ធ្នូ ៧៥។ គឺថាមុនពេលដែលរដ្ឋធម្មនុញ្ញនេះត្រូវបានអនុម័ត។ លោក ខៀវ សំផន បាននិយាយលើសាសនា

ដូចតទៅនេះ៖

[១៥:៣៦:១១]

បាទ ខ្ញុំសូមឲ្យលេខទំព័រ លេខខ្មែរគឺថា 00657450, ខ្ញុំអានឡើងវិញម្តងទៀត គឺ 00657450, ជាភាសាបារាំងគឺ 00725802, ជាភាសាអង់គ្លេសគឺ 00167816។ បាទលោក ខៀវ សំផន, សូមដកស្រង់, អ្វីដែលលោក ខៀវ សំផន និយាយមានដូចតទៅនេះ៖ "ជំពូក១៥ មាត្រា២០ ចែងថា ប្រជាជនយើងមានសិទ្ធិប្រកាន់ជំនឿសាសនាអ្វីក៏បានឲ្យតែខ្លួនពេញចិត្ត និងមានសិទ្ធិមិនប្រកាន់ជំនឿសាសនាអ្វីក៏បាន គឺគឺជាសេរីភាពថ្លៃនៃប្រជាជនយើង។ លើសពីនេះទៅទៀត ដូចដែលចែងផងដែរ នៅក្នុងរដ្ឋធម្មនុញ្ញយើងជំហររបស់យើងមិនត្រូវអនុញ្ញាតឲ្យពួកចក្រពត្តិបរទេសណាមួយប្រើប្រាស់សាសនាដើម្បីធ្វើវិទ្ធង្សនាមកលើយើងទេ។ យើងប្តេជ្ញាវាយប្រយុទ្ធពួកគេទោះបីជាប្រើរូបភាពលាក់បាំងអ្វីក៏ដោយ ពួកចក្រពត្តិនិយមស្វែងរកមធ្យោបាយវាយប្រហារយើងក្នុងចំណោមមធ្យោបាយទាំងនេះ។ ពួកគេប្រើសាសនាជារូបភាពលាក់បាំងមួយដើម្បីជ្រៀតចូលក្នុងប្រទេសយើង។ ដូច្នេះយើងគួរតែប្រឆាំងនឹងពួកគេទោះបីជាក្នុងកាលៈទេសៈណាក្តី"។ ទាក់ទងសាសនានេះតើលោក ខៀវ សំផន បានធ្លាប់និយាយប្រាប់លោក ទោះជាឆ្នាំ៩០ក៏ដោយ ឆ្នាំ២០០០ក៏ដោយនេះ លោក ខៀវ សំផន ធ្លាប់និយាយប្រាប់លោកទេ?

[១៥:៣៨:០០]

**ផ៖** ខ្ញុំមិនចាំថា យើងបានិយាយអំពីសាសនាជាស៊ីជម្រៅនោះទេ។ ក៏ប៉ុន្តែខ្ញុំគិតថាការរិះគន់របស់គាត់នេះ ក្នុងលក្ខណៈណាមួយជាការត្រឹមត្រូវ ព្រោះឧទាហរណ៍ដូចខ្ញុំមានអ្នកផ្សព្វផ្សាយសាសនាមួយៗ គឺថាអង្កាល់នោះ គេប្រើ-- ឲ្យស្ករគ្រាប់ទៅក្មេងៗហើយគេឲ្យក្មេងៗមករៀនសាសនា។ ហើយបើតាមខ្ញុំ -- បើតាមគេប្រាប់ខ្ញុំនោះ កាលសម័យនោះថា ពួកអ្នកផ្សព្វផ្សាយសាសនានេះ វាជាភ្នាក់ងារសេ.អ៊ី.អា ហើយគេទៅតាមស្រុកស្រែហ្នឹង ដើម្បីឲ្យដឹងអ្វីដែលកើតមានឡើងនៅស្រុកខ្មែរ ព្រោះថាពួកគេនោះចេះនិយាយភាសាខ្មែរ។ អ៊ីចឹងនេះ គឺជាអ្នកផ្សព្វផ្សាយសាសនាអាមេរិកាំង ហើយអង្កាល់នុ៎ងក្នុងចន្លោះឆ្នាំ៦០-៧០។

**ស៖** នៅក្នុងសេចក្តីសន្និដ្ឋាននៃសំបុត្រគាំទ្ររបស់ ខៀវ សំផន បាននិយាយថា លោក ខៀវ សំផន មិនដែលចូលរួមក្នុងបដិវត្តន៍វប្បធម៌នោះទេ ហើយគាត់ក៏មិនជំរុញឲ្យមានបដិវត្តន៍បែបនេះដែរ។ ខ្ញុំសូមរំឭកថា នេះគឺជាសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួន។ ក៏ប៉ុន្តែនៅពេលដែលលោកអានរដ្ឋធម្មនុញ្ញឆ្នាំ៧៦ នេះដែលថាចង់បំផ្លាញវប្បធម៌ ហើយនិងអត្តសញ្ញាណខ្មែរពីដើមមកនោះ តើនេះវាមិនផ្ទុះបញ្ចាំងអំពី

បដិវត្តន៍វប្បធម៌ទេឬ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនបានអានរដ្ឋធម្មនុញ្ញនេះឲ្យបានហ្មត់ចត់នោះទេ។ ខ្ញុំគ្រាន់តែវ៉ៃអ៊ីនធឺណេត ថាដោយបញ្ចូលពាក្យថា "ប្រធានរដ្ឋនៅប្រទេសកម្ពុជា" ហើយខ្ញុំក៏ឃើញមាត្រាទី១១ នេះទៅ មាត្រា១១នេះ។ បាទ ពិតណាស់គឺថានេះគឺជាបដិវត្តន៍វប្បធម៌ហើយ ក៏ប៉ុន្តែខ្ញុំនៅតែបន្តគិតថា ខៀវ សំផន មិនគាំទ្រអារឿងមហាលោតផ្លោះ ហើយនិងបដិវត្តន៍វប្បធម៌នោះទេ។ នៅក្នុងឋានៈដែលថា ប៉ុល ពត ហើយនិងអ្នកផ្សេងទៀតនោះគេស្ញើចសរសើរចិន រដ្ឋាភិបាលចិន ហើយនិងស្ញើចសរសើរ ម៉ៅ សេទុង។ អ៊ីចឹងពួកទាំងអស់នេះគេចង់ធ្វើមហាលោតផ្លោះ ហើយនិងបដិវត្តន៍វប្បធម៌ អ្វីដែលបង្កឲ្យមានមហន្តរាយស្លាប់ដល់ជីវិតមនុស្ស ដែលកើតមានឡើងនៅប្រទេសកម្ពុជានេះ។

[១៥:៤០:៥០]

**ស៖** បាទខ្ញុំមិនត្រឡប់មកនិយាយពីចំណុចនេះទៀតទេព្រោះថាឃើញថាច្បាស់ហើយ។ អម្បាញ់មិញនេះលោកបាននិយាយថា មានមិត្តភក្តិខ្មែរមួយចំនួនរបស់លោកស្លាប់នៅមន្ទីរស-២១ ដោយសារលោកឃើញមានបញ្ជីហ្នឹង។ បញ្ជីអ្នកទោសនៅស-២១ ហើយត្រូវបានប្រហារជីវិត ប៉ុន្តែលោកមិនដឹងថា អ្នកណាទេក្នុងចំណោមមិត្តភក្តិលោកនោះ។ តើលោកដឹងថាពួកគេនៅតែគេបញ្ជូនទៅមន្ទីរស-២១ គេចាត់ថាពួកគេជាខ្មាំង ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនដឹងថា អ្នកដែលយើងនិយាយអំមិញនេះត្រូវបានគេកម្ទេចនោះទេ ក៏ប៉ុន្តែខ្ញុំគិតថាគេស្អប់គាត់ ក៏ប៉ុន្តែបើតាមរយៈការទំនាក់ទំនងរបស់ខ្ញុំជាមួយគាត់នៅទីក្រុងប៉ារីសនោះគឺថា សុទ្ធពួកគាត់ទាំងអស់នេះ សុទ្ធតែជាពួកដែលអ្នកចង់ឲ្យប្រទេសកម្ពុជាវិវត្តន៍ទៅរបបប្រជាធិបតេយ្យ ហើយនិងរបបដែលមានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច។ ក៏ប៉ុន្តែការស្អប់គាត់ ការធ្វើបាបគាត់នេះ ខ្ញុំមិនដឹងថាមកពីមូលហេតុអ្វីនោះទេ។

[១៥:៤២:១៦]

**ស៖** តើយ៉ាងហោចណាស់ក៏លោកដឹង សួន កាសេត ហើយនិង អ៊ុន សុផាន់ ហើយនិង តូច ខាំឿន, ឌី ផុន អ្នកផ្សេងទៀតនេះសុទ្ធតែជាអ្នកសកម្មជននៅទីក្រុងប៉ារីស ឬក៏?

**ឆ៖** ខ្ញុំដឹងថា តូច ខាំឿន នេះបានចូលរួមកិច្ចប្រជុំនៅអឺរ៉ុបនៅពេលដែលគាត់នៅជានិស្សិត គឺថាមុនឆ្នាំ៦០ ចូលរួមក្នុងកិច្ចប្រជុំដែលរៀបចំដោយអាជ្ញាធរកុម្មុយនីស្តអន្តរជាតិ ក៏ប៉ុន្តែចំពោះអ្នកផ្សេងទៀតនោះ ខ្ញុំមិនដឹងទេ។ ខ្ញុំមិនឆ្ងល់ទេដែលថាអ្នកខ្លះនោះបានចូលទាក់ទងបក្សកុម្មុយនីស្តបារាំងពេល

ដែលគាត់នៅបារាំងនោះ ប៉ុន្តែពេលដែលពួកគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ បក្សកុម្មុយនីស្តកម្ពុជានៅស្រុកខ្មែរនេះ ខ្ញុំមិនដឹងថាអ្នកណាជាសមាជិកទេ។

[១៥:៤៣:២៤]

**ស៖** បាទ ឥឡូវទាក់ទងនឹងខ្លាំងនេះ ខ្ញុំសូមដកស្រង់ឯកសារមួយ មានឯកសារច្រើន ប៉ុន្តែខ្ញុំយកតែមួយមកនិយាយទេ គឺឯកសារ E3/201 គឺជាសម្រង់នៃសុន្ទរកថារបស់លោក ខៀវ សំផន ថ្ងៃទី១៥ មេសា ឆ្នាំ១៩៧៧ ដែលនិយាយអំពីជ័យជម្នះថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ទំព័រជាភាសាអង់គ្លេសគឺ 00417517, ជាភាសាខ្មែរគឺ 00292813 រហូតដល់ 14, ជាភាសាបារាំងគឺ 00612172។ ខៀវ សំផន និយាយយ៉ាងដូច្នេះ “យើងត្រូវតែលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍គ្រប់ពេលវេលា ប្រឆាំងនឹងសត្រូវពីគ្រប់ទិសទី ទាំងនៅក្នុង និងក្រៅប្រទេស ដើម្បីការពារកម្ពុជាប្រជាធិបតេយ្យ ការពាររដ្ឋបាលកម្មករ កសិករ និងរក្សាឲ្យបាននូវសមិទ្ធិផលនៃបដិវត្តន៍យើងជាដាច់ខាត និងជាអចិន្ត្រៃយ៍” បាទ សូមបញ្ចប់ការដកស្រង់។

តើនៅក្នុងចន្លោះឆ្នាំ៩០ ហើយនិង២០០០នេះ គាត់ធ្លាប់និយាយប្រាប់លោកអំពីលោកអំពីការដែលថានៅប្រទេសកម្ពុជាមានខ្មាំងក្នុងនិងក្រៅទេ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយគាត់ធ្លាប់ពន្យល់ប្រាប់លោកទេថា ពាក្យថា “ប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់” មានន័យថាយ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនដឹងថាខៀវ សំផន ជាអ្នកនិយាយប្រាប់ខ្ញុំ ឬក៏អ្នកណាទេ។ ក៏ប៉ុន្តែច្បាស់ណាស់ដែលជារាប់សតវត្សរ៍មកហើយ ប្រទេសកម្ពុជានេះជាចំណីរបស់វៀតណាម ហើយនិងថៃ។ ក៏ប៉ុន្តែនៅក្នុងរយៈកាលណាមួយនោះថា វៀតណាមគាំទ្រដោយសភាពសូវៀតដើម្បីដណ្តើមយកប្រទេសកម្ពុជា។ អ៊ីចឹងខ្ញុំគិតថាអ្វីដែលបានលើកឡើងទាក់ទងនឹងខ្មាំងផ្ទៃក្នុង -- ខាងក្រៅនោះគឺថាសំដៅលើវៀតណាម ហើយខ្មាំងខាងក្នុងនេះ គឺសំដៅលើខ្មែរដែលធ្លាប់បាន -- ដែលវៀតណាមធ្លាប់នាំទៅវៀតណាមខាងជើងដើម្បីទទួលការបណ្តុះបណ្តាលអប់រំ ដែលថាក្រោយមកគឺថាត្រូវបានគេខាត់ដុះលាងខួរក្បាលនោះ។

[១៥:៤៦:៣០]

**ស៖** តើក្រោយឆ្នាំ១៩៧៩ គឺថាហើយនិងក្រោយឆ្នាំ៩០ ដែលលោកបានជួបលោក ខៀវ សំផន ឡើងវិញនេះជាលើកទី១ តើលោកធ្លាប់បានចាប់អារម្មណ៍ទៅលើអ្វីដែលជនភៀសខ្លួនខ្មែរបានចេញទៅថៃ ទៅវៀតណាម ទៅបារាំងទេ? ឧទាហរណ៍លោកបាននិយាយពីសៀវភៅរបស់ ប៉ុងស្ងួ ដែលគាត់បានប្រមូលព័ត៌មានជាច្រើនពីជនភៀសខ្លួនទាំងអស់នេះ។ តើលោកធ្លាប់បានស្តាប់ជនភៀសខ្លួនទាំង

អស់នេះដែរឬទេ ដែលជាជនរងគ្រោះ?

**ឆ៖** ឆ្នាំ១៩៨០នោះ ខ្ញុំទៅជំរំជនភៀសខ្លួនពីរ គឺថានៅជំរំខាវអ៊ីដាងមួយ។ មួយទៀត ខ្ញុំភ្លេច ហើយនៅមាត់សមុទ្រ។ ខ្ញុំមិនចាំឈ្មោះទេ ជំរំនោះ។ អ៊ីចឹងខ្ញុំបាននិយាយជាមួយជនភៀសខ្លួននៅទីនោះ ហើយខ្ញុំបាននិយាយជាមួយជនភៀសខ្លួនដែលទៅស្រុកបារាំងផងដែរ។ អ៊ីចឹងយើងមាន ឧទាហរណ៍ដូច ជាលោកស័ក្តិប្រាំម្នាក់ ហើយកាលណោះយើងបង្កើតជាសមាគមមួយដើម្បីជួយជនភៀសខ្លួនទាំងអស់ នោះ ដើម្បីឲ្យគាត់មានសម្លៀកបំពាក់ ហើយនិងមានចំណីអាហារ ហើយនិងរកការងារបាន។ ហើយ ទាក់ទងនឹងចំនួនជនភៀសខ្លួនទាំងអស់នោះ កាលនោះគេនិយាយថាមានចំនួនច្រើនណាស់ ខ្ញុំមិនចាំ ច្បាស់ទេ ប៉ុន្តែថាប៉ុន្មានឆ្នាំក្រោយមកគឺថាក្នុងទសវត្សរ៍៨០ លោករដ្ឋមន្ត្រីវៀតណាមបានទៅទីក្រុង ប៉ារីស ទៅចូលរួមកិច្ចប្រជុំមួយដែលរៀបចំដោយស្ថាប័នមួយនៃប្រទេសបារាំង។ កាលនោះ គាត់បាន និយាយពីចំនួនថាមានមនុស្សស្លាប់៣លាននាក់។ អ៊ីចឹងខ្ញុំគិតថាវៀតណាម ដើម្បីបង្ហាញថាការចូលមក ប្រទេសកម្ពុជារបស់ខ្លួនជាការត្រឹមត្រូវនោះ គឺបំប៉ោងតួលេខមនុស្សស្លាប់។

[១៥:៤៨:៤៥]

ខ្ញុំគិតថាមានមនុស្សស្លាប់នៅក្នុងចន្លោះឆ្នាំ៧០, ៧៥ ដែលបង្កឡើងដោយសង្គ្រាមស៊ីវិល និងការ ទម្លាក់គ្រាប់បែកអាមេរិកាំង។ ហើយក៏មានមនុស្សស្លាប់ចន្លោះ ៧៥-៧៩ ផងដែរ។ មានអ្នកដែលគេត្រូវ បានកម្ទេច ហើយនិងអ្នកខ្លះស្លាប់ដោយសារខ្វះថ្នាំសង្កូវ ហើយនិងអ្នកដែលស្លាប់ដោយសារវៀតណាម ឈ្លានពានប្រទេសកម្ពុជានៅខែមករា ឆ្នាំ១៩៧៩។ អ៊ីចឹងអ្នកដែលរត់គេចខ្លួននោះ គឺថាត្រូវបានសម្លាប់ ហើយអ្នកខ្លះរត់ជាន់មីនស្លាប់។ អ៊ីចឹងបើចំនួនច្បាស់លាស់នោះ ខ្ញុំមិនច្បាស់ទេ ព្រោះថាមានអ្នកស្លាប់ ច្រើនប្រភេទ។

**ស៖** តើលោកធ្លាប់អាន ហើយនិងលោកធ្លាប់ដឹងពីអ្វីដែលលោក ខៀវ សំផន បានលើកឡើង ចំពោះជនរងគ្រោះនៃរបបខ្មែរក្រហម? គាត់បាននិយាយទៅកាន់អ្នកកាសែតអន្តរជាតិ ឧទាហរណ៍ដូច ជាលោក ម៉ាក ក្លាក *(Marsh Clark)* ដែលធ្វើការ*ម៉ាកាហ្សីន*ថាមស៍ ចុះថ្ងៃទី១ មីនា ឆ្នាំ១៩៨០។ ខ្ញុំសូមអានសម្រង់មួយ មុននឹងសួរសំណួរលោក គឺឯកសារ E3/628, ERN ជាភាសាបារាំងគឺ 007 40915, ជាភាសាអង់គ្លេសគឺ 00524517 ហើយជាភាសាខ្មែរគឺ 00709544។ នេះជាពាក្យពេចន៍ ដែលអ្នកកាសែតនិយាយឡើងវិញ៖ "តើលោកប៉ាន់ប្រមាណថាមានប្រជាជនប៉ុន្មាននាក់នៅពេលដែល លោកធ្វើបដិវត្តន៍? ចម្លើយរបស់លោក ខៀវ សំផន៖ "អ្វីដែលខ្ញុំអាចនិយាយបាននោះគឺថា ប្រជាជន

មិនលើសពី១០.០០០នាក់នោះទេ។ សំណួរ៖ ដូច្នេះលោកកំពុងនិយាយថា ការធ្វើសក្ខីកម្មស្មើរតែជាឯកច្ឆន្ទរបស់ប្រជាជនក្នុងប្រទេសថៃនោះ និងការបញ្ជាក់ផ្សេងៗនោះសុទ្ធតែមិនត្រឹមត្រូវទាំងអស់។ អ្វីដែលពួកគេនិយាយនោះ និងមើលឃើញនោះគឺមិនត្រឹមត្រូវ គឺថាវៀតណាមសម្លាប់មិនលើសពី២លាន -- អំ! មិនក្រោម២លាននាក់ទេ”។

[១៥:៥១:០៨]

តើលោកធ្លាប់និយាយជាមួយលោក ខៀវ សំផន ក្នុងទសវត្សរ៍៨០ ហើយនិងឆ្នាំ២០០០ ទេអំពីចំនួនដែលត្រូវបានសម្លាប់ ឬក៏ស្លាប់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ គឺថាដោយអត់អាហារ ឬក៏ដោយការប្រព្រឹត្តិធ្វើការធ្វើបាបអីជាដើមនេះ?

**ឆ៖** ខ្ញុំមិនដែលធ្លាប់និយាយជាមួយលោក ខៀវ សំផន អំពីចំនួនមនុស្សស្លាប់នោះទេ។ ពេលដែលយើងជួបគ្នាខ្លីៗនោះ យើងច្រើនតែនិយាយអំពីអនាគតរបស់ប្រទេសកម្ពុជាវិញទេ ឬក៏ពីស្ថាន -- ឬក៏ស្ថានភាពបច្ចុប្បន្ននៃប្រទេសកម្ពុជា។ ខ្ញុំមិនដឹងថាចំនួននោះប៉ុន្មានទេ ក៏ប៉ុន្តែខ្ញុំដឹងថាមានមនុស្សមួយចំនួនដែលត្រូវបានកម្ទេច គឺថាអ្នកដែលថាកាលនោះនោះដែលជំទាស់នឹងអំណាចខ្មែរក្រហម ពេលដែលខ្មែរក្រហមចូលមកក្នុងប្រទេសកម្ពុជានេះ។ ក៏ប៉ុន្តែនៅក្នុងពេលដែលវៀតណាមឈ្លានពាននោះ អ្នកដែលស្លាប់នោះប្រហែលជាមកពីលក្ខខណ្ឌការងារលំបាកលំបិន ខ្វះអាហារ ខ្វះថ្នាំសង្កូវ។ ក៏ប៉ុន្តែស្លាប់ដោយវៀតណាមបង្កប៉ុន្មាននាក់នោះ ខ្ញុំមិនដឹងទេ។

[១៥:៥២:៤៧]

**ស៖** អរគុណ។ អម្បាញ់មិញនេះលោកបាននិយាយថា ចន្លោះឆ្នាំ៩០-៩២ លោកមិនសូវបាននិយាយអំពីប្រធានបទ ឬក៏រឿងដែលថាវាស្រួចស្រាល់ទេ គឺថារយៈពេល៧៥-៧៩នេះ។ តើនៅក្រោយមកនេះ នៅឆ្នាំ២០០៦ហើយនេះ ធ្លាប់បាននិយាយអំពីរឿងរ៉ាវទាំងអស់នេះទេ ការស្លាប់មនុស្សនេះ គឺថា៣០ឆ្នាំប្លាយក្រោយមកហើយនេះ? តើមានអ្វីដែលធ្វើឲ្យលោកមិននិយាយអំពីបញ្ហាទាំងអស់នេះជាមួយលោក ខៀវ សំផន ដោយហេតុថាលោកដឹងថាមានគ្រួសារខ្មែរនៅប្រទេសកម្ពុជា ហើយដោយហេតុថាលោកជាមិត្តភក្តិរបស់លោក ខៀវ សំផន ផងនោះ ម៉េចក៏មិននិយាយពីបញ្ហានេះ?

**ឆ៖** ខ្ញុំទៅប្រទេសចិនច្រើនដង ហើយខ្ញុំសង្កេតឃើញថា ចិនដែលបានឆ្លងកាត់បទពិសោធន៍វប្បធម៌នេះ គឺថាចិនក៏មិនចង់និយាយពីបដិវត្តន៍វប្បធម៌នេះដែរ។ អ៊ីចឹងខ្ញុំគិតថានៅប្រទេសកម្ពុជាក៏ដូចគ្នាដែរ ខ្មែរមិនចង់និយាយពីរឿងរយៈពេល រយៈកាលកម្ពុជាប្រជាធិបតេយ្យពី៧៥ដល់៧៩ទេ។ ដូច្នេះ

យើងនិយាយអំពីអ្វីដែលកើតមានឡើង ពេលដែលខ្ញុំបានជួបគាត់តែប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំយល់ ក៏ប៉ុន្តែអានេះមិនមែនជាការសំណេះសំណាងរវាងជនរងគ្រោះជាមួយនឹងប្រមុខរដ្ឋទេ ដែលថាមានមនុស្សស្លាប់១លាន៧សែននាក់នោះ។ ថាតើចំពោះលោកនេះ លោកដែលមិនមែនជាជនរងគ្រោះនោះ កាលដែលលោកមិនព្រមនិយាយអំពីបញ្ហាមានមនុស្សនៅពេលហ្នឹងៗ លោកមិនទើសទាល់អារម្មណ៍ ក្បត់សតិសម្បជញ្ញៈខ្លួនឯងទេឬ?

**ឆ៖** ចំពោះខ្ញុំមិនជាមានបញ្ហាអីទេ។ ព្រោះថាខ្ញុំមានរឿងអ្វីផ្សេងទៀតដែលត្រូវនិយាយ ហើយខ្ញុំមកស្នាក់នៅហ្នឹងក៏រយៈពេលខ្លីដែរ។ ហើយមានបញ្ហាបច្ចុប្បន្នពេលនោះជាច្រើនដែលត្រូវដោះស្រាយ។ អ៊ីចឹងគឺថាជាជម្រើសរបស់ខ្ញុំតែម្តង ជាចេតនាខ្ញុំមិនចង់និយាយអំពីបញ្ហាហ្នឹង។

[១៥:៥៥:២៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានខ្ញុំអស់សំណួរហើយ។ ហើយសហភាតាខ្ញុំនឹងចង់ចោទសំណួរខ្លះដែរ។ បន្ទាប់មកទៀតយើងផ្ទេរវេទិកាទៅខាងមេធាវីនាំមុខ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការទាំងមូល។ ជម្រាបសួរលោក ហ្វ្រង្ស្វា ប្ដោប្រ្វែស។ ខ្ញុំឈ្មោះច័ន្ទ តារាស្មី ជាតំណាងមកពីការិយាល័យ សហព្រះរាជអាជ្ញា។ ជាបន្តទៅនេះសូមអនុញ្ញាតឲ្យខ្ញុំសួរសំណួរបន្ថែមមួយចំនួនលើសហការីរបស់ខ្ញុំ ដែលបានសួរអម្បាញ់មិញនេះ។

**ស៖** សូមសួរលោកថា តើលោកធ្លាប់បានដឹងឮអំពីព្រឹត្តិការណ៍ដែលបានកើតមាននៅក្នុងប្រទេសកម្ពុជា នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ដែរឬទេ? បើទោះបីជាលោកមិនបាននៅក្នុងប្រទេសខ្មែរក៏ដោយ ប៉ុន្តែខ្ញុំចង់ដឹងថា តើលោកធ្លាប់បានដឹងឮព័ត៌មានអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅប្រទេសកម្ពុជានេះនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ៧៩ ដែរឬទេ?

[១៥:៥៦:៣៤]

**លោក ហ្វ៊ីលីព ហ្វ្រង្ស្វា ប្ដោប្រ្វែស៖**

**ឆ៖** បាទ ខ្ញុំឮគេនិយាយអំពីកម្ពុជានៅពេលនោះគឺថាប្រទេសកម្ពុជានៅពេលនោះគឺបិទជិត គឺថាមិនមានជនបរទេសនៅទេ។ ហើយនៅឆ្នាំ៧៨ មានអ្នកកាសែតយូហ្គោស្លាវីបានទៅប្រទេសកម្ពុជា

ក៏ប៉ុន្តែនៅពេលនោះគឺថានៅបារាំងនៅអីក៏ដោយគេនិយាយពីកម្ពុជាតិចតួចណាស់។ មានតែអ្នកកាសែតមួយចំនួនគឺថានៅឆ្នាំ៧៥ នោះគឺថារីករាយចំពោះការចូលកាន់អំណាចរបស់ខ្មែរក្រហម។ ហើយខ្ញុំចាំពីអត្ថបទមួយនៅឆ្នាំ៧៥ ដែលមានចំណងជើងថា "ភ្នំពេញត្រូវបានរំដោះហើយ"។ ដូច្នេះមានសមានចិត្តមួយចំនួនពីពួកបញ្ញាជនជាច្រើនចំពោះការចូលកាន់អំណាចរបស់ខ្មែរក្រហម។ គឺមានន័យថា ពួកហ្នឹងគាំទ្រ ហើយនិងគាំទ្រដល់ការទម្លាក់សម្តេចសីហនុ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់ដឹងបន្ថែមទៀតថា អម្បាញ់មិញលោកបានមានប្រសាសន៍ថាសមាជិកក្រុមគ្រួសារខាងភរិយារបស់លោក និងមិត្តភក្តិរបស់លោកបានស្លាប់ បានបាត់ខ្លួនមួយចំនួន។ តើលោកអាចបញ្ជាក់បានទេថា នៅក្នុងសម័យឆ្នាំ១៩៧៥ ដល់១៩៧៩ ហ្នឹងក្រុមគ្រួសារខាងភរិយារបស់លោកធ្លាប់បាននិយាយប្រាប់លោកពីសោកនាដកម្មអ្វីខ្លះនៅក្នុងរបបខ្មែរក្រហមនោះបាទ? ហើយបើសិនជាលោកអាចបញ្ជាក់បាន តើសោកនាដកម្មនោះមានទម្រង់ជាអ្វីបាទ?

[១៥:៥៨:៣៥]

**ឆ៖** គឺនៅឆ្នាំ១៩៧៩ បងថ្លៃរបស់ខ្ញុំអាចចេញពីកម្ពុជាជាមួយគ្រួសាររបស់គាត់ហើយទៅជំរំខាវអ៊ីដាង បន្ទាប់មកទៅដល់ស្រុកបារាំង។ ខ្ញុំបានសន្ទនាជាមួយជនភៀសខ្លួនជាច្រើន ហើយខ្ញុំបានទាញការសន្និដ្ឋានមួយថាស្ថានភាពនៅកម្ពុជានោះវាខុសគ្នាទាំងស្រុងពីតំបន់មួយទៅតំបន់មួយ។ គឺថាខុសគ្នាទៅតាមអ្នកទទួលខុសត្រូវនៅតាមតំបន់នីមួយៗ ឬក៏តាមភូមិភាគនីមួយៗ តំបន់ខ្លះទៅគេធ្វើបាបប្រជាជនខ្លាំង កន្លែងខ្លះទៅក៏មិនសូវធ្វើបាប។ ដូច្នេះគឺគោលដៅគេគឺជំរុញឲ្យប្រជាជនធ្វើការ។ ហើយការងារនោះជួនកាលទៅមានការលំបាកខ្លាំងមែនទែន។ ហើយលទ្ធផលជាចុងក្រោយនេះគឺថាជាលទ្ធផលមួយលំបាកធ្ងន់ធ្ងរគឺអាក្រក់បំផុត។

**ស៖** សូមអរគុណ។ ខ្ញុំបានឃើញសំបុត្ររបស់លោកដែលមានលេខសម្គាល់ឯកសារយោងលេខ E190.2.5, ជាភាសាបារាំងត្រង់ទំព័រទី៤ ដែលមានលេខ ERN 00809025, ជាភាសាខ្មែរត្រង់ទំព័រ៤, ERN 00907758។ នៅក្នុងសំបុត្រនោះលោកបានសរសេរថា នៅឆ្នាំ១៩៩០លោកបានជួបលោក ខៀវ សំផន នៅក្នុងតំបន់ដែលមានក្រុមខ្មែរក្រហមរស់នៅក្នុងទីក្រុងប៉ារីស គឺនៅទីកន្លែង ផ្លាស ដឺ បារសឺឡូន តើនេះជាការពិតមែនទេបាទ?

[១៦:០០:៤៥]

**ឆ៖** ខ្ញុំបានជួប ខៀវ សំផន នៅឆ្នាំ១៩៩០ ខ្ញុំអត់ចាំថ្ងៃខែទេ។ ប៉ុន្តែពេលនុ៎ង គឺថានៅកន្លែងមួយ

នៅ ផ្លាស ដឺ បារសឺឡូន ដែលជាអតីតទីតាំងរបស់ខ្មែរក្រហម ដែលពេលនុ៎ងគេប្រគល់ឲ្យរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ដែលក្រោមអធិបតីភាពរបស់សម្ដេចនរោត្តម សីហនុ នៅកន្លែងនុ៎ងហើយដែលខ្ញុំបានជួបគាត់នោះ។

**ស៖** តើលោកបានជួបគាត់ជាលើកទី១ ហើយការជួបលោក ខៀវ សំផន នៅពេលនោះមានបំណងអ្វីដែរបាទ?

**ឆ៖** បាទ គឺជាលើកដំបូងហើយតាំងពីឆ្នាំ៦៦ មក ពេលនោះយើងនិយាយអំពីគ្រួសារ អំពីអ្វីដែលបានកើតឡើងពាក់ព័ន្ធទៅនឹងបញ្ហាគ្រួសារ ហើយការពិភាក្សានុ៎ងគឺខ្លីទេ មិនវែងប៉ុន្មានទេ។ ហើយពេលនុ៎ងហ្នឹងគាត់រវល់ណាស់ គាត់កំពុងតែត្រៀមរៀបចំកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ ដូច្នេះគាត់ត្រូវជួបណាត់ជួបជាមួយលោក រ៉ូឡង់ ឌុយម៉ាស ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសបារាំងនៅសម័យនោះ។ ដូច្នេះហើយបានជាយើងជជែកគ្នានុ៎ងមិនវែងទេ គាត់រវល់នឹងរឿងរៀបចំកិច្ចព្រមព្រៀងទីក្រុងប៉ារីសនុ៎ង។

[១៦:០២:៣៦]

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់ជូនបាន -- ជូនអង្គតុលាការបានទេថា នៅទីក្រុងប៉ារីស នៅពេលនោះមានការិយាល័យបេសកម្មរបស់រណសិរ្សរួបរួមជាតិកម្ពុជា ហៅកាត់ថា "ហ្វុង" ហើយនិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាហៅកាត់ថា "ហ្គ្រុង" នៅប្រទេសបារាំងនោះ។ តើការិយាល័យបេសកម្មរបស់ ហ្វុង ហើយ ហ្គ្រុង ហ្នឹងបង្កើតឡើងក្នុងបំណងអ្វីដែរ? ហើយអ្នកណាជាអ្នកទទួលខុសត្រូវចំពោះស្ថាប័នទាំងពីរនេះបាទ?

**ឆ៖** ខ្ញុំដឹងថាការិយាល័យនៅ ផ្លាស ដឺ បារសឺឡូន នេះ ត្រូវបានប្រគល់ទៅឲ្យរដ្ឋាភិបាលផ្សេងៗដែលខ្មែរក្រហមចូលរួម។ នេះគឺជា -- មិនដូចជាស្ថានទូតទេបើនិយាយឲ្យចំទៅ វាគ្រាន់តែជាទីស្នាក់ការមួយសម្រាប់ទាក់ទងគ្នាក្រៅផ្លូវការជាមួយអាជ្ញាធរ ឬក៏ឥស្សរជនបារាំង។ នេះជាការស្មានរបស់ខ្ញុំទេ។

**ស៖** សូមអរគុណបាទ។ នៅក្នុងឆ្នាំ១៩៩០ តើលោកបានដឹងព័ត៌មានថា លោក ខៀវ សំផន បានធ្វើដំណើរទៅដល់ទីក្រុងប៉ារីស ទៅដល់ទីកន្លែង ផ្លាស ដឺ បារសឺឡូន។ តើលោកដឹងព័ត៌មាននេះមកពីប្រភពណា? ហើយនៅពេលដែលលោកជួបជាមួយលោក ខៀវ សំផន តើលោក ខៀវ សំផន បាននិយាយប្រាប់អ្វីខ្លះចំពោះលោកនៅក្នុងពេលនោះបាទ?

[១៦:០៤:០៥]

**ឆៈ** ខ្ញុំអត់ចាំថាខ្ញុំដឹងដោយរបៀបណានោះទេ។ ប្រហែលជាអាចតាមរយៈជនជាតិកម្ពុជាផ្សេងទៀត ឬក៏តាមអ្នកកាសែតបារាំង ខ្ញុំដូចជាភ្លេចហើយ។ គឺថានៅពេលនោះ ខ្ញុំចាំថាមានទូរស័ព្ទហើយគេបានណាត់ជួបខ្ញុំ។

**សៈ** អរគុណ។ ខ្ញុំសូមសួរលោកបន្តទៀត នៅអំឡុងឆ្នាំ២០០៥ និងឆ្នាំ២០០៦ លោកបានបញ្ជាក់ជូនអង្គសវនាការថា លោកធ្លាប់បានស្នាក់នៅផ្ទះលោក ខៀវ សំផន និងគ្រួសាររបស់លោក ខៀវ សំផន នៅប៉ៃលិន។ តើលោកបានស្នាក់នៅទីនោះអស់រយៈពេលប៉ុន្មាន? ហើយនៅពេលនោះលោកបានជួបជាមួយនឹងលោក ខៀវ សំផន តើលោកបានសន្ទនា និងលើកប្រធានបទអ្វីជាសំខាន់នៅពេលនោះបាទ?

[១៦:០៦:០៨]

**ឆៈ** ខ្ញុំគិតថា ខ្ញុំបានស្នាក់នៅពីរបីថ្ងៃនៅប៉ៃលិន នៅឆ្នាំ២០០៥។ ហើយ១ថ្ងៃនៅអន្លង់វែង នៅឆ្នាំ២០០៦។ ពេលនោះ យើងបានជជែកគ្នាអំពីបញ្ហាជាច្រើន ជាប្រធានបទជាច្រើន ជារឿងផ្ទាល់ខ្លួន។ យើងនិយាយអំពីលក្ខខណ្ឌជីវភាពរស់នៅប៉ៃលិន អំពីកសិកម្មនៅប៉ៃលិន យើងនិយាយអំពីអន្លង់វែង យើងទៅព្រះវិហារ យើងទស្សនាប្រាសាទព្រះវិហារ។ យើងនិយាយពីបញ្ហាផ្សេងៗទៀត ក៏ប៉ុន្តែដូចជាមិនសូវស៊ីជម្រៅប៉ុន្មានទេ។ លោកដឹងហើយថា ប្រហែលជាជិត ៣០-៤០ឆ្នាំហើយ ដូច្នេះយើងត្រូវតែទំនាក់ទំនងភ្ជាប់ទំនងមិត្តភាពគ្នាឡើងវិញមុននឹងយើងអាចជជែកគ្នាឲ្យបានស៊ីជម្រៅនោះ យើងដំបូងយើងត្រូវធ្វើម៉េចឲ្យយើងស្និទ្ធស្នាលគ្នាសិន ដើម្បីឲ្យយើងឈានទៅជជែកគ្នាឲ្យបានស៊ីជម្រៅនៅពេលក្រោយនោះ។

**សៈ** បាទ អរគុណ។ តើនៅពេលដែលលោកស្នាក់នៅអន្លង់វែង និងប៉ៃលិននៅក្នុងឆ្នាំ២០០៥ និង២០០៦ នោះតើលោកមានបានជួបនឹងមេដឹកនាំខ្មែរក្រហមណាផ្សេងទៀតដែរឬទេ? ហើយបើសិនជាបានជួប តើអ្នកណាខ្លះ? ហើយលោកបានសន្ទនាជាមួយគាត់ទៅលើប្រធានបទអ្វីខ្លះបាទ?

[១៦:០៧:៤៧]

**ឆៈ** អត់ទេ ខ្ញុំអត់បានជួបមេដឹកនាំខ្មែរក្រហមផ្សេងទៀតទេ ខ្ញុំដឹងថានៅប៉ៃលិននោះ លោក អៀង សារី ក៏នៅទីនោះដែរ។ ហើយអភិបាលក្រុងប៉ៃលិនហ្នឹងជាអតីតកងអង្គរក្ស អៀង សារី ក៏ប៉ុន្តែគាត់រស់នៅក្នុងពិភពផ្សេងដាច់ស្រឡះពី ខៀវ សំផន យោងទៅតាមទស្សនៈ។ ជាពិសេសពាក់ព័ន្ធនឹងសម្ភារៈអីជាដើមនោះ។ ដូច្នេះចំពោះខ្ញុំនោះ គឺថាខ្ញុំមិនមានបំណងអីទាក់ទងជាមួយឥស្សរជនខ្មែរក្រហម

អីផ្សេងទៀតទេ។

**ស៖** បាទ សូមអរគុណ។ តើលោកអាចបញ្ជាក់ជូនអង្គសវនាការជ្រាបបានដែរឬទេថា តើមានមូលហេតុអ្វីបានជាលោក ខៀវ សំផន បានចូលរួមក្នុងសកម្មភាពរបស់មេដឹកនាំខ្មែរក្រហម ឬអាចនិយាយម៉្យាងទៀតថា នៅក្នុងរបបអតីតកម្ពុជាប្រជាធិបតេយ្យ។ តើការចូលរួមក្នុងរបបនេះ តើដោយមានមូលហេតុអ្វី? តើគាត់ធ្លាប់បាននិយាយប្រាប់លោកអំពីបញ្ហានេះដែរឬទេ?

**ឆ៖** បាទ ប្រសិនបើលោកអនុញ្ញាតនោះ ខ្ញុំសូមបំពេញចម្លើយរបស់ខ្ញុំទៅនឹងសំណួរមុន ដោយខ្ញុំសូមបន្ថែមថា ក្នុងពេលដែលខ្ញុំស្នាក់នៅប៉ៃលិននោះ ហើយនិងអន្លង់វែងផងដែរនោះ ខ្ញុំបានជួបមន្ត្រីរាជការ កសិករ យោធា គឺទាំងយោធាខ្មែរ និងយោធាថៃ ហើយអ្នកទាំងអស់នោះគឺសុទ្ធតែគោរពលោក ខៀវ សំផន មែនទែន។ ចំពោះបញ្ហាដែលលោកសួរខ្ញុំអម្បាញ់មិញនេះ ខ្ញុំដឹងថាលោក ខៀវ សំផន គាត់មានគំនិតចម្រើននិយម គាត់បានចាកចេញពីរដ្ឋធានីនៅឆ្នាំ៦៧ គាត់ចាកចេញរួមគ្នាទាំងតំណាងរាស្ត្រពីរនាក់ទៀត គឺហ៊ូ នឹម, ហ៊ូ យន់។ អ្នកតំណាងរាស្ត្រទាំងពីរនាក់នោះគឺបាត់ខ្លួនក្នុងចន្លោះឆ្នាំ៧៥-៧៨។ ខ្ញុំគិតថា ខៀវ សំផន មិនទទួលរងជោគវាសនាដូច ហ៊ូ នឹម, ហ៊ូ យន់ នោះគឺដោយសារតែរដ្ឋាភិបាលខ្មែរក្រហមត្រូវការគាត់ គឺថាទុកប្រើគាត់ជាប្រមុខរដ្ឋ។

[១៦:១០:៥៦]

**ស៖** អរគុណលោក ហ្វ្រ៊ុង្សូាន-ហ្គោប្រ៉ែស ខ្ញុំមានបីសំណួរទៀតមុនបញ្ចប់ការសួររបស់ខ្ញុំនៅពេលនេះបាទ។ សំណួរចុងក្រោយមានបីសំណួរ។ សូមសួរបន្តទៀតថា តើលោកធ្លាប់បានស្រាវជ្រាវ ឬក៏បានយល់ដឹង ស្វែងយល់ដឹងអំពីស្ថានភាពលោក ខៀវ សំផន, ថាតើលោកខៀវ សំផន បានពន្យល់អំពីមូលហេតុជាពិសេសអ្វីដែរឬទេ អំពីការព្រមទទួលយកនូវមុខដំណែងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឧទាហរណ៍ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងមុខតំណែងដទៃទៀត ឬក៏ការទទួលខុសត្រូវដទៃទៀតនៅក្នុងរបបខ្មែរក្រហម? តើលោកធ្លាប់បានស្វែងយល់ ឬក៏ធ្លាប់បានស្តាប់ឮការពន្យល់ហេតុផលណាមួយអំពីករណីនេះដែរឬទេបាទ?

[១៦:១១:៥១]

**ឆ៖** បាទ យើងមិនដែលនិយាយអំពីចំណុចនេះទេ។ ក៏ប៉ុន្តែខ្ញុំគិតថា គាត់ទទួលយកឋានៈនេះគឺគាត់គិតថាវាចាំបាច់សម្រាប់ប្រទេសគាត់ និងប្រជាជាតិប្រជាជនរបស់គាត់។

**ស៖** អរគុណ។ សំណួរបន្តទៀត លោកធ្លាប់បាននិយាយអំពីចរិតលក្ខណៈបុគ្គល អំពីឥរិយា

បទផ្ទាល់ខ្លួនរបស់លោក ខៀវ សំផន និងអំពីប្រជាប្រិយភាពរបស់លោក ខៀវ សំផន ពោលគឺគាត់ធ្លាប់បានពន្យល់ជាច្រើននៅក្នុងលិខិត ឬក៏ដូចជាការអត្ថាធិប្បាយអម្បាញ់មិញនៅក្នុងសាលសវនាការថា លោក ខៀវ សំផន គឺជាមនុស្សមានប្រជាប្រិយ៍ភាពបំផុត ជាមនុស្សមានសមត្ថភាព ជាមនុស្សគួរឲ្យគោរព និងទទួលបានការសរសើរពីសំណាក់ប្រជាជន។ ជាពិសេសភាពលេចធ្លោនេះគឺបានកើតឡើងនៅទសវត្សរ៍ឆ្នាំ៦០។ ខ្ញុំសូមសួរលោកថា តើលោកអាចពន្យល់ជូនអង្គសវនាការបានដែរឬទេនៅពេលនេះថា តើនៅក្នុងអំឡុងពេលនៃ៣០ឆ្នាំនៃចលនាតស៊ូនៃរបបខ្មែរក្រហម លោកខៀវ សំផន នៅតែបន្តមានប្រជាប្រិយភាពបន្តទៀតចំពោះការងារនៅក្នុងរបបខ្មែរ និងគំនិតនយោបាយរបស់ខ្លួនគាត់ទៀតដែរឬទេ? ឬក៏មានការប្រែប្រួលយ៉ាងណានោះ? សូមលោកមេត្តាបកស្រាយបំភ្លឺបន្ថែមចំពោះចំណុចនេះបាទ។ --

[១៦:១៤:១៤]

**លោក ច័ន្ទ តារាស្មី៖**

ខ្ញុំបានសួរគាត់ ប៉ុន្តែប្រហែលជាមានបញ្ហាបកប្រែលោកប្រធាន។ ខ្ញុំអាចសួរម្តងទៀតបាទ។

**ប្រធានអង្គជំនុំ៖**

បាទៗ។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោកសាក្សី លោកធ្លាប់បាននិយាយអំពីចរិតលក្ខណៈបុគ្គល អំពីឥរិយាបទផ្ទាល់ខ្លួនរបស់លោក ខៀវ សំផន និងអំពីប្រជាប្រិយភាពរបស់លោក ខៀវ សំផនិ ពោលគឺលោកបានពន្យល់បន្ថែមយ៉ាងច្រើនទាក់ទិនទៅនឹងលោកខៀវ សំផន នេះដោយផ្តោតជាសំខាន់ទៅលើថាគាត់គឺជាមនុស្សមានប្រជាប្រិយភាពបំផុត ជាមនុស្សមានសមត្ថភាព ជាមនុស្សគួរឲ្យគោរព និងទទួលបានការសរសើរពីសំណាក់ប្រជាជន។ ជាពិសេសភាពលេចធ្លោនេះ គឺបានកើតឡើងនៅទសវត្សរ៍ឆ្នាំ១៩៦០ សូមលោកជួយបំភ្លឺជូនអង្គសវនាការនៅពេលនេះថា តើនៅក្នុងអំឡុងពេល៣០ឆ្នាំនៃចលនាតស៊ូនៃរបបខ្មែរក្រហម លោក ខៀវ សំផន នៅតែបន្តមានប្រជាប្រិយភាពចំពោះការនៅក្នុងរបបខ្មែរក្រហម និងចំពោះគោលគំនិតនយោបាយរបស់ខ្លួនគាត់ដែរឬទេ ឬក៏មានការប្រែប្រួលយ៉ាងណានោះ? សូមលោកមេត្តាជួយបំភ្លឺចំពោះចំណុចនេះបាទ។

[១៦:១៥:៣៣]

**ឆ៖** បាទ នៅពេលដែលខ្ញុំនៅប៉ៃលិន ហើយនិងចន្លោះពីអន្លង់វែងនិងទៅព្រះវិហារនោះ ខ្ញុំកត់

សម្គាល់ឃើញថាមានអ្នកដែលខ្ញុំជួបនោះដូចជាមន្ត្រីរាជការ រដ្ឋការដែលជូនខ្ញុំទៅប៉ៃលិន ឬក៏ទាហានថៃ ឬក៏កម្ពុជាដែលខ្ញុំបានជួបនៅជិតព្រំដែននោះ គឺថាពេលនុ៎ងគឺថាខ្ញុំក៏បានជួបកសិករពីអន្លង់វែងទៅដល់ព្រះវិហារ គឺអ្នកទាំងអស់នុ៎ងគឺថាសុទ្ធតែសម្ដែងនូវសមានចិត្តចំពោះលោក ខៀវ សំផន ទាំងអស់។ ខ្ញុំអត់មានស្ដាប់ឮការជេរប្រទេច ខៀវ សំផន ពីសំណាក់អ្នកទាំងអស់នុ៎ងទេ គឺថាពួកគាត់គឺគោរពលោក ខៀវ សំផន។

[១៦:១៦:៣១]

**លោក ច័ន្ទ តារាស្មី៖**

បាទខ្ញុំសូមអរគុណលោក ហ្ស៊ីល្យាន-ហ្គោប្រ៉ៃស ដែលបានឆ្លើយសំណួររបស់ខ្ញុំនៅក្នុងសវនាការនាពេលនេះ។ ខ្ញុំសង្ឃឹម និងជឿជាក់ថាចម្លើយរបស់លោកគឺពិតជាបានចូលរួមចំណែកនៅក្នុងការស្វែងរកការពិត និងយុត្តិធម៌នៅក្នុងរឿងក្ដីនៅក្នុងអ.វ.ត.ក។ បាទសូមជូនពរឲ្យលោកជួបតែសំណាងល្អ និងជោគជ័យនៅក្នុងជីវិត និងការងារ ចំពោះលោកផ្ទាល់ ក៏ដូចជាក្រុមគ្រួសារ។ សូមអរគុណលោក ហ្ស៊ីល្យាន-ហ្គោប្រ៉ៃស សូមជម្រាបលា។ ហើយសូមអរគុណលោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំបាននិយាយសួរសំណួរចំពោះលោក ហ្ស៊ីល្យាន-ហ្គោប្រ៉ៃស សូមជម្រាបបាទ។ សូមអរគុណ។

**លោក ហ្វីលីព ហ្ស៊ីល្យាន-ហ្គោប្រ៉ៃស៖**

បាទសូមអរគុណលោកសហព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ជាបន្តមេធាវីដែលទទួលសិទ្ធិ គឺលោកមេធាវី ឡោ ជុនធី ហើយនិងបន្តទៅនឹងសួរសំណួរដោយលោកស្រីមេធាវី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត។

សូមលោកប្រធានអនុញ្ញាត សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១៦:១៧:៤១]

**លោក ឡោ ជុនធី៖**

បាទ ជាបឋមខ្ញុំបាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម ហើយសូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីនៅក្នុងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ហើយក៏ជាមេធាវីក្នុងជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុង អ.វ.ត.ក នេះ។ នៅពេលនេះខ្ញុំសូមជម្រាបសួរលោក ហ្វ៊ីល្យាន ដែលជាសាក្សីនៅពេលនេះបាទ។ សំណួររបស់ខ្ញុំដែលពាក់ព័ន្ធនឹងលោក គឺលោកបាន--

**លោក ហ្វីលីព ហ្វ៊ីល្យាន-ហ្គោព្រែស៖**

**ឆ៖** បាទ ជម្រាបសួរលោកមេធាវី។

[១៦:១៨:៣២]

**ស៖** សូមអរគុណ។ អំពីលិខិតរបស់លោកដែលបាននិយាយអំពីទំនាក់ទំនងរវាងលោកជាមួយនឹងលោក ខៀវ សំផននោះ គឺថាចាប់ផ្ដើមតាំងពីឆ្នាំ១៩៥៧មកម្ល៉េះ។ ខ្ញុំចង់ដឹងថានៅក្នុងឆ្នាំដែលលោកបានជួបជាមួយគាត់នៅក្នុងទីក្រុងប៉ារីស ដែលក្នុងឱកាសដែលគាត់បានទៅសិក្សាទៅនោះនោះ។ ថាតើគាត់បានសិក្សាយកបានជាសញ្ញាបត្របណ្ឌិតនៅទីនោះ ខ្ញុំចង់ដឹងថាតើសញ្ញាបត្របណ្ឌិតគាត់សរសេរពីបរិបទអ្វីខ្លះ? ហើយលោកបានដឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

បាទ មានបញ្ហាបច្ចេកទេស! អត់មានអ៊ីនធឺណេត លោកមេធាវីអាចសម្រាកសិន!

[១៦:១៩:៣៨]

*(មានបញ្ហាបច្ចេកទេស)*

[១៦:២១:២៥]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវីដំណើរការ។ ហើយចាប់ផ្ដើមសួរសាឡើងវិញ ព្រោះអំមិញអត់មានប្រព័ន្ធអ៊ីនធឺណេតទេ។

**សួរដោយលោក ឡៅ ជុនធី៖**

**ស៖** បាទ សូមអរគុណ។ សូមជម្រាបសួរលោកសាក្សី។ ខ្ញុំបាទ អំបាញ់មិញខ្ញុំបាទ បានលើកឡើងអំពីប្រវត្តិបន្តិចដែលថាលោកបានជួបនឹងគាត់ ខៀវ សំផន នេះ គឺនៅទីក្រុងប៉ារីសតាំងពីឆ្នាំ១៩៥៧ មក។ ហើយនៅកាលនោះគឺគាត់បានទៅធ្វើការសិក្សាយកថ្នាក់បណ្ឌិតនៅទីនោះ។ ខ្ញុំចង់ដឹងថាតើការសិក្សាថ្នាក់បណ្ឌិតរបស់គាត់ពាក់ព័ន្ធនឹងប្រធានបទអ្វីហើយលោកបានពិភាក្សាអំពីបញ្ហាថ្នាក់បណ្ឌិតនេះដែរឬទេបាទ?

**លោក ហ្វីលីព ហ្ស៊ីល្យាន-ហ្គោប្រែហ្វស៖**

**ឆ៖** បាទ ខ្ញុំអត់បានអាននិក្ខេបបទបណ្ឌិតរបស់គាត់ទេ ក៏ប៉ុន្តែខ្ញុំជឿថាជានិក្ខេបបទសេដ្ឋកិច្ចដែលគាត់លើកឡើងអំពីការវិវត្តផ្នែកសេដ្ឋកិច្ចរបស់កម្ពុជាតាមការចង់បានរបស់គាត់នោះ។

**ស៖** បាទអរគុណ។ ចំណុចនេះខ្ញុំចង់ជម្រាបសួរទៅលោកសាក្សីបន្ថែមគឺថាអម្បាញ់មិញលោកបានលើកឡើងថា លោកបានដឹងអំពីបញ្ហានៅឆ្នាំ-- ថ្ងៃទី១៧ មេសា ១៩៧៥ គឺត្រូវបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក៏ដូចទីប្រជុំជនដទៃទៀត។ ហើយលោកបានលើកឡើងថាការជម្លៀសនេះ គឺការដោះស្រាយអំពីបញ្ហាស្បៀង។ ហើយខ្ញុំចោទសំណួរថាតើលោកយល់ឃើញថា អ្វីដែលជាការជម្លៀសនេះវាអាចនឹងមានផលវិបាកធ្ងន់ធ្ងរទៅដល់ប្រជាជននៅពេលដែលជម្លៀសចេញដោយគ្មានការគ្រប់គ្រងដោយគ្មានការដឹកជញ្ជូន ហើយមិនគិតអំពីផលវិបាកដែលប្រជាជនបានទទួលរងតាមផ្លូវរហូតទៅដល់ទីដៅនោះដែរឬទេ?

[១៦:២៤:៥០]

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអ៊ីនធឺណេតដាច់ទៀតហើយ។

*(មានបញ្ហាបច្ចេកទេស)*

[១៦:២៥:២៥]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តការតាំងសំណួរ តាំងសំណួរអម្បាញ់មិញនេះវិញ ហើយសូមរំឭកថា ពេលវេលាមានកំណត់ ពីព្រោះឲ្យតែ១០ -- ១ម៉ោង១៥នាទីទេ។ ហើយការប្រើប្រាស់ដោយតំណាងសហព្រះរាជអាជ្ញាជិតអស់ហើយ។ អ៊ីចឹងប្រហែលជាទំនងមាន*(ឮមិនច្បាស់)* នេះគឺបំពេញបន្ថែមដោយសារ

មានបញ្ហាបច្ចេកទេសនេះ។

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន ខ្ញុំនឹងកាត់ឲ្យបានខ្លីបំផុតបាទ។

[១៦:២៥:៥៧]

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សំណួរអម្បាញ់មិញខ្ញុំចង់លើកឡើងថា អ្វីដែលលោកបានលើកឡើងនោះថាពីការជម្លៀសហ្នឹងជាការដោះស្រាយនឹងបញ្ហាស្បៀង។ ខ្ញុំចង់ដឹងថា អ្វីដែលជម្លៀសហ្នឹងវាពាក់ព័ន្ធនឹងការដែលប្រជាជនចេញទៅ ហើយធ្វើឲ្យមានផលលំបាកលើគាត់។ ថាតើលោកមានជម្រើសណាផ្សេងទេ ដែលអាច -- ជម្រើសណាផ្សេងទេ ដែលថាមិនជម្លៀសប្រជាជនអាចដោះស្រាយស្បៀងបាន។ លោកយល់ថាម៉េចដែរ?

**ឆ៖** ខ្ញុំមិននៅកម្ពុជាទេ នៅឆ្នាំ៧៥ ប៉ុន្តែនៅក្នុងឆ្នាំ៧៤ ខ្ញុំនៅកម្ពុជា ហើយពេលនុ៎ងគឺថាប្រទេសត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមស៊ីវិល ហើយដំណាំដាំដុះផ្សេងហ្នឹងក៏មិនអាចធ្វើទៅបាន ប្រជាជនភៀសខ្លួនទៅនៅទីក្រុងមួយភាគធំនោះត្រូវបានផ្គត់ផ្គង់ស្បៀងតាមកប៉ាល់ហោះ តាមកប៉ាល់ចេញមកពីខាងក្រៅ ជាពិសេសនោះ ដោយពួកអាមេរិក។ ដូច្នេះដំណោះស្រាយមួយផ្សេងទៀតនោះគឺថាពួករុស្ស៊ី ចិន សាំងហ្គាពួរ ...។ល។ ជំនួសពួកអាមេរិកក្នុងការផ្គត់ផ្គង់ស្បៀង ហើយនិងថ្នាំសង្កូវ។ នេះមិនមែនជាដំណោះស្រាយដែលគេរកឃើញពិតប្រាកដនោះទេ។

[១៦:២៧:៥២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមមួយសំណួរចុងក្រោយសម្រាប់ខ្ញុំ ព្រោះពេលវេលាមិនអនុញ្ញាតបាទ។ សំណួរចុងក្រោយរបស់ខ្ញុំនេះ គឺខ្ញុំចង់ដឹងថាលោកដែលមានទំនាក់ទំនងជាមួយនឹងលោកខៀវ សំផន ពីមុន, ពីឆ្នាំ៥៧មក, ហើយក្រោយមកទៀតនៅឆ្នាំ៩០ ដែលជួបគាត់ ហើយក្រោយមកទៀតបានជួបគាត់។ សួរថាតើអ្វីដែលបានជួបហ្នឹងវាមានការផ្លាស់ប្តូរពីអត្តចរិតពីមុនមកឥឡូវដែរអត់? បាទ សូមអរគុណ។

**ឆ៖** ខ្ញុំមិនបានកត់សម្គាល់ឃើញការផ្លាស់ប្តូរខ្លាំងក្លាអីនោះទេ។ ខ្ញុំឃើញថា គាត់នៅតែរក្សាជំនឿរបស់គាត់ដែលថា កម្ពុជានឹងអាចអភិវឌ្ឍបានទៅមុខ ហើយជាតិនិយម មាតុភូមិស្នេហាជាតិនិយមរបស់គាត់ហ្នឹងនៅតែដដែល។ ហើយខ្ញុំគិតថា គាត់ទទួលយកតំណែងជាប្រមុខរដ្ឋនៅឆ្នាំ១៩៧៦

នោះ ពីព្រោះថា ប្រហែលជាមានការបង្ខំចិត្តខ្លះ ឬមួយក៏គាត់គិតថា អាចនឹងរឹតត្បិត ឬក៏កាត់បន្ថយនៅការបំផ្លិញបំផ្លាញដែលគាត់អាចកត់សម្គាល់ឃើញនៅសម័យនោះនោះ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោក ហ្សៀល្យាន។ ហើយសូមអរគុណលោកប្រធាន ហើយសូមផ្ទេរទៅសហការីខ្ញុំ។ បាទសូមអរគុណ។

[១៦:២៩:៥៤]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ សហភាតាទាំងអស់ជាទីគោរព លោកសាក្សីជាទីគោរព។

**ស៖** ខ្ញុំសូមចោទសំណួរមួយចំនួន។ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះគឺតួនាទីរបស់លោក ខៀវ សំផន ហើយនិងអ្វី -- ហើយនិងរយៈ -- អ្វីដែលគាត់ធ្វើនៅចន្លោះ៧៧-៧៩។ ប៉ុន្តែលោកបាននិយាយថា មិនដែលបានឃើញគាត់ទេ ពីឆ្នាំ៦៦ មកដល់ឆ្នាំ៩០នោះ ហើយលោកក៏បានលើកឡើងផងដែរថា ចាប់ពីឆ្នាំ៩០ លោកធ្លាប់បានជួបគាត់ ក៏ប៉ុន្តែលោកទាំងពីរនាក់មិនដែលនិយាយអំពីអ្វីដែលកើតឡើងពី៧៥ ដល់ ៧៩ នោះទេ។ ហើយលោកក៏បានលើកឡើងផងដែរថា លោកមិនបានដឹងអំពីព័ត៌មានលម្អិតទាក់ទងនឹងជីវិតរបស់គាត់ពី៧៥ ដល់ ៧៩នោះដែរ។

[១៦:៣០:៥០]

ដូច្នេះ ខ្ញុំយល់ឃើញថា សក្ខីកម្មរបស់លោកនោះមិនមានប្រយោជន៍អីសម្រាប់តុលាការនេះទេ ដោយសារលោកមិនដឹងអំពីតួនាទីពិតប្រាកដរបស់គាត់ចន្លោះឆ្នាំ៧៥ ដល់ ៧៩។ អ៊ីចឹងខ្ញុំមិនមានសំណួរអ្វីចោទទៅលោកទេ ហើយទន្ទឹមនឹងនោះខ្ញុំសូមអរគុណលោកដែលលោកបានចំណាយពេលវេលាមកផ្តល់សក្ខីកម្មនៅទីនេះ ហើយលោកបាននិយាយថា បើដូច្នេះ -- ក៏ប៉ុន្តែអម្បាញ់មិញនេះ លោកបាននិយាយថាលោកបានដឹងរឿងច្បាស់លាស់មួយពីសវនាការនេះ។ អ៊ីចឹងខ្ញុំក៏សូមរីករាយ អរគុណផងដែរដែលលោកបានដឹងរឿងពីសវនាការវិញនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែសូមធ្វើការកត់សម្គាល់ចំពោះសម្តីរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់មិនបានសួរទៅសាក្សីទេ ប៉ុន្តែគាត់ធ្វើសេចក្តីសន្និដ្ឋានដែលជាការមិនសមរម្យ ពីព្រោះពេលនេះជាពេលសួរសំណួរមិនមែនជាការធ្វើការសន្និដ្ឋានទេ។ សូមអរគុណ។

[១៦:៣២:០៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការកត់សម្គាល់ដ៏ល្អនេះ។ ចុះខាងក្រុមមេធាវីការពារក្តីលោក នួន ជា តើមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ?

**លោក វ៉ិចទ័រ កូប៉េះ៖**

អត់មានទេលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក ហ្វ៊ីល្យាន ហ្គោហ្វ្រូ ហ្វីលីព កិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកដល់ពេលនេះបានចប់ហើយ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងភាគីដទៃទៀតហ្នឹងមិនមានសំណួរអ្វីសួរលោកទៀតទេ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានលះបង់ពេលវេលាដ៏មានតម្លៃ ផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះក្នុងរយៈពេលមួយរសៀលពេញនេះ ដោយអំណត់អត់ធ្មត់ និងខិតខំអស់ពីសមត្ថភាព លទ្ធភាពរបស់ខ្លួន។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ ហើយអង្គជំនុំជម្រះសូមជូនពរលោក ហ្វ៊ីល្យាន ហ្គោហ្វ្រូ ហ្វីលីព មានសុខភាពល្អ ជួបតែសំណាងល្អមានសេចក្តីសុខ សេចក្តីចម្រើន។ ហើយសូមជម្រាបលាលោក ហ្វ៊ីល្យាន។

**លោក ហ្វីលីព ហ្វ៊ីល្យាន ហ្គោហ្វ្រែស៖**

បាទ លោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព លោកព្រះរាជអាជ្ញាជាទីគោរពអស់លោក លោកស្រីមេធាវីជាទីគោរព លោក ខៀវ សំផន បាទ ខ្ញុំសូមអរគុណដែលបានចំណាយពេលវេលា ដើម្បីស្តាប់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ សូមជម្រាបលា។

បាទ បុគ្គលិកផ្នែកសោតទស្សន៍អាចផ្ដាច់ប្រព័ន្ធភ្ជាប់សោតទស្សន៍រវាង អ.វ.ត.ក និងប្រទេសបារាំងបានហើយ។

[១៦:៣៤:១០]

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះសូមប្រកាសនូវសេចក្ដីសម្រេចផ្ទាល់មាត់ស្ដីពីការតាំងសំណួរដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងអំឡុងពេលសវនាការស្ដីពីផលប៉ះពាល់មកលើជនរងគ្រោះ។

កាលពីម្សិលមិញ អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់សារណាផ្ទាល់មាត់ពីគ្រប់ភាគីទាំងអស់ទាក់ទងនឹងសំណើថា តើភាគីដើមបណ្ដឹងរដ្ឋប្បវេណីគួរត្រូវបានសួរដោយសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្ដីដែរឬយ៉ាងណា នៅក្នុងអំឡុងពេលសវនាការស្ដីពីផលប៉ះពាល់មកលើជនរងគ្រោះដែលបានគ្រោងធ្វើចាប់ពីថ្ងៃទី២៧ ខែឧសភា គឺនៅសប្ដាហ៍ក្រោយនេះ?

មានការព្រមព្រៀងគ្នាយ៉ាងច្រើននៅក្នុងចំណោមភាគីទាំងអស់ ហើយអង្គជំនុំជម្រះសម្រេចថាភាគីទាំងអស់អាចតាំងសំណួរដែលពាក់ព័ន្ធទៅនឹងបញ្ហាអង្គហេតុនានាទៅកាន់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីបាន ដោយគោរពទៅតាមពេលវេលាកំណត់ដែលបានប្រកាសជូនរួចមកហើយនោះ។

អង្គជំនុំជម្រះសូមរំឭដល់ភាគីថា ក្របខ័ណ្ឌទូទៅសម្រាប់ការបង្ហាញសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរួមទាំងសេចក្ដីថ្លែងពីការឈឺចាប់ផងនោះត្រូវបានកំណត់នៅក្នុងឯកសារ E267/3 នាពេលថ្មីៗនេះរួចហើយ។

ដោយពិចារណាឃើញថាសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដីនឹងត្រូវបានផ្ដល់ឱកាសឲ្យធ្វើការតាំងសំណួរនោះ អង្គជំនុំជម្រះនឹងមិនផ្ដល់ឱកាសផ្សេងបន្ថែមទៀត ដើម្បីបញ្ចេញគំនិតយោបល់លើសេចក្ដីថ្លែងការណ៍ឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។

[១៦:៣៦:២៩]

សវនាការស្ដីពីផលប៉ះពាល់មកលើជនរងគ្រោះត្រូវបានគ្រោង និងប្រព្រឹត្តទៅនៅថ្ងៃទី២៧, ២៩, ៣០ ខែឧសភា និងថ្ងៃទី៤ ខែមិថុនាខាងមុខនេះ។ ពេលវេលាមួយវគ្គមានន័យថារយៈពេល៧៥នាទីនឹងត្រូវផ្ដល់ជូនភាគីដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ។ ក្នុងនោះសហមេធាវីនាំមុខមានពេលវេលាចំនួនពីរភាគបីនៃពេលវេលាបានកំណត់សម្រាប់វគ្គនោះ។ ហើយពេលវេលាដែលនៅសល់ពីនោះត្រូវបែងចែកក្នុងចំណោមសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដីពីរក្រុមទៀត។

ភាគីដើមបណ្ដឹងរដ្ឋប្បវេណីដែលមានបំណងចោទសួរទៅកាន់ជនជាប់ចោទ ត្រូវសួរនៅក្នុងអំឡុង

ពេលវេលាដែលបានបែងចែកជូនសហមេធាវីនាំមុខនេះ។ នៅក្នុងអំឡុងពេលសវនាការផ្តល់សក្ខីកម្មក្នុងរយៈពេល៤ថ្ងៃខាងមុខនេះ អង្គជំនុំជម្រះនឹងកែសម្រួលពេលវេលាសវនាការបន្តិចបន្តួច ដើម្បីអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ផ្តល់សក្ខីកម្មនៅពេលព្រឹក និងដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ផ្សេងទៀតផ្តល់សក្ខីកម្មនៅពេលរសៀល។ ពេលវេលាស្តាប់សវនាការនេះនឹងត្រូវផ្តល់ជូនភាគីទាំងអស់តាមរយៈអ៊ីម៉ែល។

ដូចដែលបានកត់សម្គាល់កាលពីម្សិលមិញរួចហើយ អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមផ្តល់ពេលវេលាបន្ថែមដើម្បីស្តាប់សក្ខីកម្មអ្នកជំនាញ TCE-12។ អ្នកជំនាញរូបនេះនឹងត្រូវផ្តល់សក្ខីកម្មនៅវេលារសៀលថ្ងៃទី០៥ ខែមិថុនា ខាងមុខនេះ។

[១៦:៣៨:៣០]

សហមេធាវីនាំមុខនឹងទទួលបានពេលវេលាចំនួនពីរភាគបី ហើយពេលវេលានៅសេសសល់ពីនេះនឹងត្រូវផ្តល់ជូនភាគីបីផ្សេងទៀត។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនទទួលបានពេលវេលាបន្ថែមណាផ្សេងទៀតទេ។

បាទនេះគឺជាសេចក្តីសម្រេចប្រកាសផ្ទាល់មាត់លើ ដែលបាន លើសំណើរសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំកាលពីម្សិលមិញ។

បាទ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសម្រាកហើយ។ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកថ្ងៃពុធ ទី២២ ខែឧសភា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីព្រំ ស៊ូ ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្តីពីរក្រុម ដោយចាប់ផ្តើមពីក្រុមមេធាវីការពារក្តីលោក ខៀវ សំផន មុន។ សូមភាគីនៃរឿងក្តី និងសាធារណជនជ្រាប។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ។ និងបង្គាប់ឲ្យខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:៤០ នាទី)*